សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale da Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ដំណើរការរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូង រាជធានីភ្នំពេញ

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ៖
និស្សិតឈ្មោះ៖ **លោក ភាំង សេងហួរ**
**កញ្ញា សាវី ច័ន្ទដាវីន**

សាស្ត្រាចារ្យណែនាំ
**លោក ហោ សុភ័ណ្ឌ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ភាំង សេងឃួរ** និងនាងខ្ញុំ **សាទី ច័ន្ទដាវីន** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី ២០ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា ២០១៦-២០២០។

កូនៗសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅដល់ **លោកឪពុក អ្នកម្តាយ** ទាំងទ្វេដែលបានផ្តល់កំណើតដល់កូនដើម្បីឲ្យកូនបានឃើញពន្លឺថ្ងៃ ចិញ្ចឹមបីបាច់ថែរក្សា អប់រំប្រៀនប្រដៅកូន ផ្តល់ថវិកាដល់កូនសិក្សារហូតមកដល់បច្ចុប្បន្ន ដែលលោកទាំងទ្វេបានពុះពារគ្រប់ឧបសគ្គទាំងហាលភ្លៀងហាលក្តៅ មិនដែលខ្លាចងាយហាត់ដើម្បីឲ្យកូនបានរៀនសូត្រខ្ពង់ខ្ពស់សំរាប់ជាប្រយោជន៍ដល់ក្រុមគ្រួសារ និងសង្គមជាតិផងដែរ។ គុណបំណាច់របស់លោកទាំងពីរ មិនអាចមានអ្វីមកប្រៀបប្រដូចបានឡើយ គឺគុណមួយដ៏មហាសែនធំធូន់ជាងផែនដី ធំជាងមហាសមុទ្រដែលកូនមិនអាចតបស្នងសងទៅវិញអស់បានឡើយ។ កូនសូមលើកម្រាមដៃដប់បួងសួងដល់វត្ថុសក្តិសិទ្ធទាំងពួងឲ្យជួយតាមថែរក្សាដល់អ្នកមានគុណ មានអាយុយឺនយូរ សុខភាពល្អ ប្រកបមុខរបរកាន់តែមានការរីកចម្រើនទៅមុខជានិច្ច និង កុំឲ្យមានជម្ងឺនានាមកបៀតបៀនរូបរាងកាយលោកទាំងពីរ។

យើងខ្ញុំទាំងពីរ សូមថ្លែអំណរគុណដល់លោកសកលវិទ្យាធិការ សកលវិទ្យាធិការរង ព្រឹទ្ធបុរស លោកសាស្ត្រាចារ្យ លោកស្រីសាស្ត្រាចារ្យ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលខិតខំស្វែងរកវិធីសាស្ត្រថ្មីៗសំរាប់បង្ហាត់បង្រៀនផ្តល់ចំណេះដឹងជាច្រើនដល់រូបយើងទាំងពីរ និងមិត្តរួមជំនាន់តាំងពីឆ្នាំទី១ រហូតមកដល់ឆ្នាំទី៤។

ជាពិសេសសូមសម្តែងនូវការថ្លែងអំណរគុណដល់លោកសាស្ត្រាចារ្យ **ហោ សុភ័ណ្ឌា** បានលះបង់ពេលវេលាដ៏មានតម្លៃ ធ្វើការណែនាំតម្រង់ទិសនិងផ្តល់អនុសាសន៍ល្អៗសំរាប់ជាគន្លឹះក្នុងការសរសេរសារណាសំរាប់តំកល់ទុកជាស្នាដៃមួយ។

ជាចុងបញ្ចប់យើងខ្ញុំទាំងពីររូបសូមជូនពរដល់លោកឪពុក អ្នកម្តាយ សាកលវិទ្យាធិការ ព្រឹទ្ធបុរស លោកលោកស្រី សាស្ត្រាចារ្យទាំងអស់ ជួបតែសេចក្តីសុខចម្រើន អាយុ វណ្ណ សុខ ពលៈ និងទទួលជោគជ័យគ្រប់ភារកិច្ចកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ឆ្លងកាត់តាមការសិក្សាផ្នែកនីតិសាស្ត្រ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រយៈពេល៤ឆ្នាំកន្លងមក មុខវិជ្ជានីតិសាស្ត្រជាជំនាញមួយដែលមានសារៈសំខាន់ក្នុងប្រព័ន្ធយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា និងបានផ្តល់ចំណេះដឹងយ៉ាងច្រើនដល់ពួកយើងទាំងពីរនាក់ ទាំងវិធីសាស្ត្រនៃការនិយាយចរចារឿងក្តីក្នុងពេលសវនាការ ព្រមទាំងចេះពីរបៀបនៃការស្វែងរកហេតុនិងផលក្នុងដោះស្រាយរឿងក្តីទាំងក្នុងប្រព័ន្ធតុលាការ និងក្រៅប្រព័ន្ធតុលាការ ឬ ពេលមានវិវាទកើតឡើងចំពោះនរណាម្នាក់។ ម្យ៉ាងវិញទៀតការសិក្សាផ្នែកព្រហ្មទណ្ឌ ជាចំណែកមួយដ៏មានសារៈសំខាន់ដល់ពួកយើង និងបណ្តាមិត្តនិស្សិតរួមជំនាន់ផងដែរ។

នីតិវិធីព្រហ្មទណ្ឌ ជាមុខវិជ្ជាមួយដ៏មានសារៈសំខាន់ដែលមាននៅក្នុងជំនាញនីតិសាស្ត្រ និងបានផ្តល់ពីយុទ្ធសាស្ត្រក្នុងការស្វែងរកភស្តុតាងសំរាប់ដាក់បង្ហាញជូនតុលាការពេលសវនាការ។ ដោយមើលឃើញពីការអនុវត្តនីតិវិធីពេលមានបទល្មើសកើតឡើងនៅក្នុងតុលាការនៃប្រទេសកម្ពុជាមក ពួកយើងទាំងពីក៏បានសម្រេចលើកយកប្រធានបទមួយសំរាប់យកមកសរសេរចងក្រមទុកជាស្នាដៃនៅក្នុងបណ្ណាល័យ «**ដំណើរការរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូងរាជធានីភ្នំពេញ**» ដើម្បីឲ្យ និស្សិតជំនាន់ក្រោយបានយល់ដឹងកាន់តែច្បាស់ពីដំណើរការនៃនីតិវិធីរឿងក្តីព្រហ្មទណ្ឌនៅក្នុងសាលាដំបូង រហូតដល់តុលាការចេញសេចក្តីសម្រេចណាមួយ។ ប្រព័ន្ធតុលាការនីមួយៗតែងមាននីតិវិធីផ្សេងៗគ្នាពេលដោះស្រាយបញ្ហា។ មូលហេតុដែលពួកយើងទាំងពីលើកយកប្រធានបទនេះមកសរសេរជាសារណា ព្រោះដោយមើលឃើញថា មនុស្សទូទៅមិនសូវបានយល់ដឹងពីប្រព័ន្ធច្បាប់ ក៏ដូចជាក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌសព្វថ្ងៃសំរាប់ពន្យល់បង្ហាញដល់មនុស្សទូទៅឲ្យដឹងដំណាក់កាលនីមួយៗនៅពេលមានបទល្មើសណាមួយកើតឡើង។

ចំណុចទាំងអស់នេះ ជាកត្តាមួយដែលជំរុញឲ្យ យើងទាំងពីរចងក្រងឯកសារនៃអត្ថបទនេះ ទុកជាស្នាដៃក្នុងការសិក្សារយៈពេល៤ឆ្នាំកន្លងមក។ យើងខ្ញុំទាំងពីររូបសូមធ្វើការខន្តីអភ័យទោសទុកជាមុនចំពោះអ្នកអានអត្ថបទមួយនេះ ប្រសិនបើពួកយើងទាំងពីរនាក់សរសេរខ្លឹមសារនៃអត្ថបទមិនសូវបានក្បោះក្បាយនិងមានភាពខ្វះចន្លោះណាមួយដោយអចេតនា។ យើងខ្ញុំសង្ឃឹមថាសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រមួយនេះនឹងមាននូវសារៈប្រយោជន៍ដល់សិស្សានុសិស្សជំនាន់ក្រោយព្រមទាំងមិត្តអ្នកអានផងដែរ។ ចុងក្រោយយើងខ្ញុំទាំងពីររូបនឹងរងចាំនូវកាការជួយកែលំអរ និងផ្តល់អនុសាសន៍បន្ថែមលើសារណានេះពីសាស្ត្រាចារ្យ និងបណ្តាអ្នកអានទាំងអស់ដោយក្តីសមនស្សរីករាយផងដែរ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១៖ ប្រព័ន្ធយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា**

**ផ្នែកទី១៖ ស្ថាប័នតុលាការ** ........................................ ៣

១.១.សាលាដំបូង ........................................ ៥

១.២.សាលាឧទ្ធរណ៍ ........................................ ៦

១.៣.តុលាការកំពូល. ........................................ ៧

**ផ្នែកទី២៖ ឯករាជ្យភាពនៃស្ថាប័នតុលាការ** ........................................ ៨

២.១.ឯករាជ្យភាពបុគ្គល ........................................ ៩

២.២.ឯករាជ្យភាពថវិការបស់ស្ថាប័នតុលាការ ........................................ ៩

**ជំពូកទី២៖ ដំណាក់កាលមុននីតិវិធីជំនុំជម្រះ**

**ផ្នែកទី១៖ មន្ត្រីនគរបាលយុត្តិធម៌** ........................................ ១០

១.១.មន្ត្រីនគរបាលយុត្តិធម៌ ........................................ ១០

១.២.បេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ ........................................ ១០

១.២.១.ការទទួលពាក្យបណ្តឹង ........................................ ១១

១.២.២.ការឃាត់ខ្លួនជនសង្ស័យ ........................................ ១១

១.២.៣.ការធ្វើកំណត់ហេតុនៃបទល្មើស ........................................ ១៣

១.២.៤.ការស្តាប់ចម្លើយជនសង្ស័យ ........................................ ១៤

១.២.៥.ការបោះត្រាទៅលើវត្ថុតាង ........................................ ១៤

១.៣.ការបញ្ជូនខ្លួនជនសង្ស័យទៅកាន់ព្រះរាជអាជ្ញា ........................................ ១៥

**ផ្នែកទី២៖ ដំណាក់កាលអយ្យការ** ........................................ ១៥

២.១.ព្រះរាជអាជ្ញា ........................................ ១៥

២.១.១.អំណាចរបស់ព្រះរាជអាជ្ញា ........................................ ១៦

២.២.ការតម្កល់រឿងទុកឥតចាត់ការ ........................................ ១៧

២.៣.ការចោទប្រកាន់ ........ ១៨
២.៤.ការបើកការស៊ើបអង្កេត និងការបញ្ជូនរឿងក្តីទៅជំនុំជម្រះ ........ ១៩
២.៥.នីតិវិធីនៃការបង្ហាញខ្លួន ........ ២០
**ជំពូកទី៣៖ នីតិវិធីជំនុំជម្រះ**
**ផ្នែកទី១៖ ចៅក្រមស៊ើបសួរ** ........ ២១
១.១.ចៅក្រមស៊ើបសួរ ........ ២១
១.១.១.ការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ........ ២១
១.១.២.ដែនសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ........ ២១
១.១.៣.ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ ........ ២១
១.១.៣.១.ការជូនដំណឹងដាក់ឲ្យនៅក្រោមការត្រួតពិនិត្យ ........ ២២
១.១.៣.២.ការសួរចម្លើយជនត្រូវចោទ ........ ២៣
១.១.៣.៣.ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ........ ២៤
១.១.៣.៤.ការស្តាប់ចម្លើយសាក្សី ........ ២៤
១.១.៣.៥.ការឆែកឆេរ និងការចាប់យកវត្ថុតាង ........ ២៥
១.១.៣.៦.ការធ្វើកោសល្យវិច័យ ........ ២៦
១.១.៣.៧.ការស្តាប់ទូរស័ព្ទ ........ ២៧
១.១.៤.ការចាត់ឲ្យស៊ើបសួរជំនួស ........ ២៨
១.២.វិធាននិរន្តរាយ ........ ២៩
១.២.១.ដីកា ........ ២៩
១.២.១.១.ដីកាបង្គាប់ឲ្យចូលខ្លួន ........ ៣០
១.២.១.២.ដីកាបង្គាប់ឲ្យនាំខ្លួន ........ ៣០
១.២.១.៣.ដីកាបង្គាប់ឲ្យចាប់ខ្លួន ........ ៣១
១.៣.ការឃុំខ្លួនបណ្តោះអាសន្ន ........ ៣២
១.៣.១.មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ........ ៣២
១.៣.២.ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ........ ៣៣
១.៣.២.១.ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជន ........ ៣៣
១.៣.២.២.ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នសំរាប់នីតិជន ........ ៣៣

១.៣.៣.ការពន្យាពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ........ ៣៤
១.៤.ការបិទការស៊ើបសួរ ........ ៣៤
១.៤.១.ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ........ ៣៥
១.៤.២.ដីកាដំណោះស្រាយ ........ ៣៥
១.៤.៣.ការប្រគល់វត្ថុដែលចាប់បានឲ្យទៅម្ចាស់ដើមវិញ ........ ៣៦
**ផ្នែកទី២៖ សវនាការ និងការប្រកាសសាលក្រម** ........ ៣៧
២.១.សមាសភាពក្នុងសវនាការ ........ ៣៧
២.២.ការចូលខ្លួនរបស់ភាគី ........ ៣៨
២.២.១.ការចូលខ្លួនរបស់ជនជាប់ចោទ ........ ៣៨
២.២.២.ការចូលខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ........ ៣៩
២.២.៣.ការចូលខ្លួនរបស់អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ........ ៣៩
២.២.៤.ការចូលខ្លួនរបស់សាក្សី ........ ៣៩
២.៣.កិច្ចដេញដោល ........ ៤០
២.៤.សាលក្រម ........ ៤៣
២.៤.១.សាលក្រមចំពោះមុខ ........ ៤៤
២.៤.២.សាលក្រមដែលចាត់ថាចំពោះមុខ ........ ៤៤
២.៤.៣.សាលក្រមកំបាំងមុខ ........ ៤៤
២.៤.៤.ការប្រកាសសាលក្រម ........ ៤៥
២.៤.៥.អានុភាពនៃសាលក្រម ........ ៤៥
**សេចក្តីសន្និដ្ឋាន** ........ ៤៦
**អនុសាសន៍** ........ ៤៧
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

តុលាការមានសារសំខាន់ណាស់នៅក្នុងសង្គមពីព្រោះ ស្ថាប័ននេះបានជួយការពារសិទ្ធិដែលបានធានាដោយរដ្ឋធម្មនុញ្ញ និងក្នុងការការពារស្មើភាពគ្នានិងនីតិវិធីត្រឹមត្រូវតាមច្បាប់។ តាមការសិក្សាស្រាវជ្រាវស្ថាប័នតុលាការគឺជាមែកធាងនៃអំណាចរបស់រដ្ឋមួយដ៏សំខាន់ក្នុងចំណោមស្ថាប័នធំៗទាំងបីដែលមានអំណាចនៅក្នុងការដោះស្រាយវិវាទ ការអនុវត្តច្បាប់ និងផ្តន្ទាទោសទៅលើពិរុទ្ធជនដែលបំពានដល់សិទ្ធិ រូបរាងកាយ សេចក្តីថ្លៃថ្នូរ ទ្រព្យសម្បត្តិ និងអាយុជីវិតរបស់បុគ្គលទាំងឡាយ។ ទាំងតុលាការព្រហ្មទណ្ឌនិងរដ្ឋប្បវេណីផ្តល់នូវឱកាសសម្រាប់ភាគីដើម្បីទទួលបានការដោះស្រាយនូវរឿងក្តីរបស់ពួកគេដោយ ចៅក្រមអព្យាក្រឹត្យដែលគោរពទៅតាមនីតិវិធីដែលមានជាធរមាន។ ដំណើរនៃការដោះស្រាយនូវវិវាទតាមរយៈតុលាការនេះធានាថាគ្រប់ករណីទាំងអស់ត្រូវបានសំរេចដោយត្រឹមត្រូវនិងស្របទៅតាមច្បាប់។ តុលាការគឺជាវេទិកាមួយដែលច្បាប់បានផ្តល់ទៅដល់ពលរដ្ឋទាំងឡាយនៃរដ្ឋមួយក្នុងដោះស្រាយវិវាទព្រមទាំងស្វែងរកនូវយុត្តិធម៌ដល់ពួកគេទៀតផង។

នៅក្នុងប្រទេសកម្ពុជាប្រព័ន្ធតុលាការព្រមទាំងរចនាសម្ព័ន្ធដឹកនាំរដ្ឋផ្សេងៗទៀត ត្រូវបានរលាយហិនហោចនៅក្នុងឆ្នាំ១៩៧៥ ដល់ ១៩៧៩ ដោយពួកតមិឡប៉ុលពតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដោយសែនឃោឃៅ។ នៅក្នុងរយៈកាលនោះ ប្រទេសកម្ពុជាបានក្លាយទៅជាពិភពដ៏ងងឹតនៅក្នុងប្រវត្តិសាស្ត្រ។ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាបានចាប់ផ្តើមធ្វើការរៀបចំនូវរចនាសម្ព័ន និងរបបដឹកនាំរដ្ឋតាមបែបថ្មីដែលតម្រូវឲ្យមាននូវប្រព័ន្ធច្បាប់រួមជាមួយ នឹង ប្រព័ន្ធតុលាការតាមបែបជឿនលឿនឲ្យស្របទៅតាមសម័យកាលផងដែរនៅក្នុងឆ្នាំ១៩៨២។ តុលាការដែលបានបង្កើតដោយរបបដឹកនាំរដ្ឋសម័យនោះត្រូវបានហៅថាតុលាការប្រជាជនដែលមានទីតាំងនៅតាមរាជធានី ខេត្ត ក្រុងនានា នៅប្រទេសកម្ពុជា។ បន្ទាប់ពីរបបសាធារណៈរដ្ឋប្រជាមាណិតកម្ពុជាត្រូវបានដួលរលំទៅ អង្គការសហប្រជាជាតិបានធ្វើការចុះមកជួយធ្វើការរៀបចំការបោះឆ្នោតតាមបែបប្រជាធិបតេយ្យនៅក្នុងឆ្នាំ១៩៩៣ ក្នុងការធ្វើការជ្រើសតាំងរាជរដ្ឋាភិបាលស្របច្បាប់ថ្មីដើម្បីដឹកនាំព្រមទាំងអភិវឌ្ឍព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងឆ្នាំដដែលនេះផងដែរ សភាធម្មនុញ្ញបានធ្វើការអនុម័តនូវរដ្ឋធម្មនុញ្ញថ្មីដើម្បីកសាងនូវរចនាសម្ព័ន្ធដឹកនាំរដ្ឋតាមលិទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងបង្កើតឲ្យមាននូវស្ថាប័នតុលាការឯករាជ្យដោយមានតុលាការទាំង៣ ដែលរួមមាន៖ សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល ក្នុងគោលបំណងរក្សានូវយុត្តិធម៌ និងសន្តិភាពនៅក្នុងសង្គមខ្មែរ។ នៅក្នុងយុគ្គសម័យសត្សវត្សទី២១នេះ ព្រះរាជាណាចក្រកម្ពុជាបានក្លាយទៅជាប្រទេសដែលកំពុងអភិវឌ្ឍមួយនៅក្នុងសហគមអាស៊ាន។ ទាំងផ្នែកសេដ្ឋកិច្ចនិងផ្នែកច្បាប់រដ្ឋអធិបតេយ្យមួយនេះបានធ្វើសកលភាវូបនីយកម្មទៅលើវិស័យផ្សេងៗជាច្រើនផងដែរ។ ដោយសារតែភាពជឿនលឿននៃពិភពលោក ព្រះរាជាណាចក្រកម្ពុជាបានធ្វើការអនុម័តនឹងប្រកាសឲ្យប្រើនូវ

ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងច្បាប់ដ៏ទៃទៀតដើម្បីងាយស្រួលនៅក្នុងការគ្រប់គ្រងរដ្ឋ និងដោះស្រាយនូវវិវាទជូនដល់ប្រជាពលរដ្ឋ។

ងាកមកមើលការដោះស្រាយវិវាទរឿងព្រហ្មទណ្ឌក្នុងសាលាដំបូងរាជធានីភ្នំពេញ ការអនុវត្តនូវដំណើរការរឿងក្តីគឺស្ថិតនៅក្រោមក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌដែលបានប្រកាសឲ្យប្រើជាធរមាននៅក្នុងឆ្នាំ ២០០៧។ ចំពោះក្រមនីតិវិធីព្រហ្មទណ្ឌវិញ គេឃើញមាននូវនីតិវិធីជាច្រើនដំណាក់កាលដើម្បីដោះស្រាយនូវរឿងក្តីព្រហ្មទណ្ឌ។ ក្រមនេះគឺប្រៀបដូចជាត្រីវិស័យក្នុងការចង្អុលបង្ហាញផ្លូវដល់មន្ត្រីតុលាការដើម្បីស្វែងរកនូវយុត្តិធម៌ជូនទៅដល់ប្រជាពលរដ្ឋគ្រប់រូប។ ច្បាប់នេះបានបញ្ញត្តិនូវដំណាក់កាលផ្សេងៗនៅក្នុងរឿងក្តីព្រហ្មទណ្ឌដែលរួមមានទាំងដំណាក់កាលមុនសវនាការរហូតដល់ក្រោយសវនាការ ដើម្បីផ្តន្ទាទោសព្រមទាំងស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះ។

ជាចុងក្រោយ ដើម្បីរក្សានូវ សន្តិសុខ សណ្តាប់ធ្នាប់ ស្ថិរភាព និងសន្តិភាពនៅក្នុងសង្គម យើងត្រូវការប្រព័ន្ធច្បាប់ និងប្រព័ន្ធតុលាការឯករាជ្យដើម្បីឲ្យការគ្រប់គ្រងរដ្ឋរួមជាមួយនិងការដោះស្រាយវិវាទមានលក្ខណៈច្បាស់លាស់ដោយមិនមានភាពលម្អៀងទៅខាងណាឡើយ។ ក្នុងនាមយើងខ្ញុំដែលជានិស្សិតច្បាប់ ដែលកំពុងតែសិក្សាអំពីប្រព័ន្ធច្បាប់និងប្រព័ន្ធតុលាការ ពិតជាមានមោទនភាពណាស់ដែលបានសិក្សាស្រាវជ្រាវអំពីនីតិវិធីព្រហ្មទណ្ឌដ៏សំខាន់មួយនេះ។ យើងខ្ញុំសង្ឃឹមថា ការសិក្សាក្រមនីតិវិធីព្រហ្មទណ្ឌដែលកំណត់អំពីដំណាក់ការរឿងក្តីព្រហ្មទណ្ឌមួយនេះ នឹងនាំមកនូវផលប្រយោជន៍ផ្នែកច្បាប់ជាច្រើនជូនជាតិនិងមាតុភូមិកម្ពុជាទាំងមូល។

# ជំពូកទី១

# ប្រព័ន្ធយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី១

# ប្រព័ន្ធយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា

## ផ្នែកទី១៖ ស្ថាប័នតុលាការ

នៅក្នុងសង្គមរបស់មនុស្សរមែងមានការប្រែប្រួលបន្តិចម្តងៗ ពីសម័យកាលមួយទៅសម័យកាលមួយ ទាំងចិត្តរបស់មនុស្ស ព្រមទាំងផ្នត់គំនិតរបស់ពួកគេ ក៏មានការប្រែប្រួលដូចសង្គមដែលគេរស់នៅដែរ។ ការរស់នៅក្នុងសង្គមនីមួយៗតែងតែមានជម្លោះរឺការប៉ះទង្គិចគ្នាដោយចេតនាក្តីរឺអចេតនាក្តី។ ដោយហេតុនេះហើយ ទើបមនុស្សទាំងឡាយនាំគ្នាបង្កើតនូវប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋឡើងដើម្បីរក្សាសណ្តាប់ធ្នាប់នៅក្នុងសង្គ។ ប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋទាំងនោះ គឺមិនអាចខ្វះបានឡើយនូស្ថាប័នតុលាការដែលជាអង្គការស្វែងរកយុត្តិធម៌ជូនទៅដល់ពលរដ្ឋនៅក្នុងសង្គមនោះ។

ផ្អែកទៅលើទស្សនទានបែបប្រាកដនិយម ការបង្កើតឲ្យមាននូវស្ថាប័នតុលាការនេះឡើង គឺដោយសារតែមានភាពអាណាធិបតេយ្យនៅក្នុងសង្គមដោយសារតែសភាពធម្មជាតិរបស់មនុស្សបាននាំមកនូវសិទ្ធិនិងសេរីភាពមកជាមួយដែលនាំឲ្យមាននូវការរំលោភសិទ្ធិគ្នា និង សកម្មភាពវិជ្ជមានកើតមានឡើងដូចនេះមនុស្សទាំងឡាយបាននាំគ្នារួបរួមគ្នាដើម្បីបំបាត់នូវភាពអវិជ្ជមានទាំងនោះដើម្បីស្វែងរកសន្តិភាពសុវត្ថិភាសណ្តាប់ធ្នាប់ និងស្ថេរភាពនៅក្នុងសង្គម[1]។ ដោយផ្អែកលើទស្សនៈមួយនេះយើងអាចធ្វើការសន្និដ្ឋានបានថាប្រសិនបើគ្មាននូវប្រព័ន្ធតុលាការ រឺស្ថាប័នតុលាការដើម្បីវិនិច្ឆ័យច្បាប់និងដាក់ទណ្ឌកម្មដល់ជនដែលប្រព្រឹត្តខុសនោះទេ សង្គមនោះនឹងមិនអាចជៀសផុតពីភាពអាណាធិបតេយ្យដោយសារតែសិទ្ធិនិងសេរីភាពរបស់មនុស្សជាក់ជាមិនខាន។

លើសពីនេះទៅទៀត យោងតាមទ្រឹស្តីបែងចែកអំណាចនយោបាយរបស់បារាំងបានឲ្យយើងដឹងថាតុលាការត្រូវតែមានឯករាជ្យដោយមិនមានការជ្រៀតជ្រែកពីស្ថាប័ននីតិបញ្ញត្តិនិងនីតិប្រតិបត្តិ[2]។ នៅក្នុងន័យនេះ លោកចង់បញ្ជាក់ថា ស្ថាប័នតុលាការត្រូវមាននូវអំណាចឯករាជ្យពីអំណាចនយោបាយទាំងពីររបស់រដ្ឋដើម្បីធានាឲ្យបាននូវយុត្តិធម៌ដល់ពលរដ្ឋគ្រប់រូបព្រោះថាមានតែតុលាការទេដែលមានសិទ្ធិអំណាចនៅក្នុងការវិនិច្ឆ័យ និងកាត់សេចក្តីប្រកបដោយយុត្តិធម៌។

ស្ថាប័នតុលាការ គឺជាស្ថាប័នមួយក្នុងចំណោមស្ថាប័នធំៗទាំងបីរួមមាន ស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័ននីតិប្រតិបត្តិ (រដ្ឋធម្មនុញ្ញ) និងធានានូវឯករាជ្យរបស់ស្ថាប័ននេះផងដែរ។ នៅក្នុងន័យនេះ តុលាការមិនត្រូវមានការជ្រៀតជ្រែកពីអំណាចដ៏ទៃទៀត នៅពេលដែលចៅក្រមជំនុំជម្រះចេញសាលក្រម រឺសាលដីកា គ្មានអង្គការ

[1] សៀវភៅ ប្រវត្តិគំនិតនយោបាយ ដោយបណ្ឌិត អ៊ុន សកក្កុដា

[2] សៀវភៅ ប្រវត្តិគំនិតនយោបាយ ដោយបណ្ឌិត អ៊ុន សកក្កុដា

ណាមួយអាចរារាំងដោយប្រើអំណាចទៅលើការអនុវត្តច្បាប់របស់មន្ត្រីតុលាការបានឡើយ។ មួយវិញទៀត ដើម្បីធានានូវឯករាជ្យភាពរបស់តុលាការនេះបានអង្គជុំនុំជម្រះរបស់តុលាការ (ចៅក្រមជុំនុំជម្រះ) ត្រូវមានឯករាជ្យភាពបុគ្គល ពោលគឺលោកមាននូវឯករាជ្យភាពនៅក្នុងការសម្រេចសេចក្ដីនិងមាននូវការធានាឲ្យបាននូវមុខងារនិងតួនាទីរបស់ចៅក្រម[3]។ ក្នុងន័យនេះ គឺធ្វើឲ្យចៅក្រមមាននូវទំនុកចិត្តទៅលើមុខងាររបស់ខ្លួន និង ប្រកបនូវវិជ្ជាជីវៈរបស់ខ្លួនឲ្យកាន់តែល្អទៅទៀត។ ម្យ៉ាងវិញទៀតប្រសិនបើចៅក្រមមានភាពភ័យខ្លាចនៅក្នុងការសម្រេចសេចក្ដីរបស់ខ្លួន នោះនឹងនាំមកនូវភាពអគតិដែលមានចែងនៅក្នុងក្រមសីលធម៌និងវិជ្ជាជីវៈរបស់ចៅក្រម និងមិនអាចឲ្យចៅក្រមប្រកបតួនាទីរបស់ខ្លួនបានខ្ជាប់ខ្ជួននោះឡើយ។

អ្វីដែលពិសេសជាងនេះទៅទៀត «អំណាចតុលាការ គ្របដណ្ដប់ទៅលើរឿងក្ដីទាំងអស់ រួមទាំងរឿងក្ដីរដ្ឋបាលផងដែរ»[4]មានន័យថាតុលាការមានយុត្តាធិការដោះស្រាយទាំងរឿងក្ដីព្រហ្មទណ្ឌ រដ្ឋប្បវេណីពាណិជ្ជកម្ម និងរឿងក្ដីរដ្ឋបាលផងដែរព្រោះចៅក្រមចេះច្បាប់មិនអស់[5]។ ក៏ប៉ុន្តែមន្ត្រីតុលាការជាពិសេសចៅក្រមជំនុំជម្រះមានការលំបាកក្នុងការដោះស្រាយដោយសារតែយើងពុំ មាននូវតុលាការពិសេសដូចប្រទេសដ៏ទៃដែលគេមានតុលាការពិសេសតាមរឿងក្ដីនីមួយៗ។

នៅព្រះរាជាណាចក្រកម្ពុជាបានបែងចែកតុលាការចេញជា ២ជាន់ពោលគឺ សាលាជម្រះក្ដីជាន់ខ្ពស់ (តុលាការកំពូល និងសាលាឧទ្ធរណ៍) និងសាលាជម្រះក្ដីជាន់ទាប (សាលាដំបូងរាជធានីខេត្ត និងតុលាការយោធា)ដើម្បីធានាឲ្យបាននូវយុត្តិធម៌និងងាយស្រួលនៅក្នុងការតវ៉ាទៅលើសាលក្រមដែលចេញដោយតុលាការណាមួយ[6]។ លើសពីនេះទៅទៀត តុលាការទាំងពីរជាន់ថ្នាក់មានតួនាទីដោះស្រាយវិវាទគ្រប់រឿងទាំងអស់គួបផ្សំនិងរឿងក្ដីរដ្ឋបាលផងដែរ។

តុលាការ គឺជាស្ថាប័នដ៏សំខាន់ដែលមានតួនាទីនៅក្នុងការដោះស្រាយវិវាទនិងស្វែងរកនូវយុត្តិធម៌ដល់ពលរដ្ឋគ្រប់រូប ហើយអំណាចតុលាការនេះត្រូវបានធានានូវឯករាជ្យដោយរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់រដ្ឋ។ នៅប្រទេសកម្ពុជាយើងច្បាប់កំពូល និងច្បាប់រៀបចំអង្គការតុលាការបានកំណត់ឲ្យមានសាលាជម្រះក្ដីចំនួនពីរជាន់ដែលមានតួនាទីដោះស្រាយវិវាទគ្រប់រឿងក្ដីទាំងអស់។

[3] សៀវភៅ មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់ ដោយ លោក ឥន យឿន

[4] មាត្រា១២៨ថ្មី នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣

[5] សៀវភៅ មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់ ដោយ លោក ឥន យឿន

[6] មាត្រា៣ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ

## ១.១. សាលាដំបូង

សាលាដំបូងត្រូវបានកំណត់ដោយច្បាប់ពិសេសថា ជាសាលាជម្រះក្ដីថ្នាក់ទីមួយ[7]។ រឿងក្ដីទាំងអស់ត្រូវឆ្លងកាត់ការវិនិច្ឆ័យដោយសាលាដំបូងជាមុន ប្រសិនបើមានការមិនពេញចិត្តទៅលើសេចក្ដីសម្រេចរបស់សាលាដំបូង នោះគេអាចប្ដឹងទាស់តទៅសាលាឧទ្ធរណ៍បាន។ សាលាដំបូងមានទីតាំងនៅរាជធានីភ្នំពេញ និងនៅតាមបណ្ដាខេត្ត-ក្រុងនានាទូទាំងព្រះរាជាណាចក្រកម្ពុជា[8]។ សាលាដំបូងរាជធានីខេត្ត ត្រូវបានប្រកាសឲ្យដំណើការតាមព្រះរាជក្រឹត្យដែលជាលិខិតបទដ្ឋានគតិយុត្តចេញដោយព្រះមហាក្សត្រ។ សាលាដំបូងដែលបាននិយាយពីខាងលើនេះត្រូវបានបែងចែកចេញជាតុលាការជំនាញផ្សេងៗ។

សាលាដំបូងមានសមាសភាពដូចជា

- ប្រធានតុលាការ
- អនុប្រធានតុលាការ
- ចៅក្រម
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល

ងាកមកមើលក្នុងបណ្ដឹងព្រហ្មទណ្ឌវិញ សាលាដំបូងធ្វើការជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌដោយចៅក្រមមួយរូប រឺដោយចៅក្រមច្រើនរូបទៅតាមនីតិវិធីព្រហ្មទណ្ឌ[9] ។

ក្រោយពីដឹងអំពីមុខងារខ្លះរបស់សាលាដំបូងរួចមក យើងងាកមកមើលអយ្យការអមសាលាដំបូងវិញដែលជាស្ថាប័នចំណុះឲ្យសាលាដំបូង។

អយ្យការអមសាលាដំបូងគឺសំដៅទៅលើស្ថាប័នមួយ ព្រមទាំងមានសមាសភាពដូចតទៅ៖

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី មន្ត្រីរដ្ឋបាល
- មន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតផងដែរ[10]។

[7] មាត្រា១២ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ

[8] មាត្រា១២ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ

[9] មាត្រា២០ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ

[10] មាត្រា២៩ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ

ព្រះរាជអាជ្ញាគឺសំដៅទៅលើអង្គអវិភាគនៅក្នុងបណ្តឹងព្រហ្មទណ្ឌ។ ក្នុងន័យនេះនៅពេលព្រះរាជអាជ្ញាណាមួយធ្វើបណ្តឹងអាជ្ញា គាត់ត្រូវតែមានវត្តមាននៅក្នុងដំណើរការនៃបណ្តឹងចាប់តាំងពីការធ្វើបណ្តឹងអាជ្ញារហូតដល់ការចេញសេចក្តីសម្រេចផ្តន្ទាទោស។ ព្រះរាជអាជ្ញាម្នាក់នោះមិនអាចផ្ទេរបណ្តឹងរបស់ខ្លួនឲ្យព្រះរាជអាជ្ញាដ៏ទៃទៀតដើម្បីធ្វើការចោទប្រកាន់នោះទេ។ដូចនេះហើយព្រះរាជអាជ្ញាពិតជាមានសារសំខាន់ណាស់នៅក្នុងរឿងក្តីព្រហ្មទណ្ឌ។ សាលាដំបូង គឺជាតុលាការជាន់ទាបដែលទទួលដោះស្រាយគ្រប់បណ្តឹងទាំងអស់បូករួមទាំងរឿងក្តីរដ្ឋបាល។ លើសពីនេះសាលាដំបូងមានសមត្ថកិច្ចដោះស្រាយបណ្តឹងទៅតាមច្បាប់និងនីតិវិធីដែលមានជាធរមាន ហើយតុលាការនេះត្រូវតែមានស្ថាប័នចំណុះមួយដែលជាអ្នកធ្វើបណ្តឹងអាជ្ញានិងជាអ្នកតំណាងឲ្យជនរងគ្រោះម្ចាស់បណ្តឹងព្រហ្មទណ្ឌ។

### ១.២. សាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍ត្រូវបានច្បាប់កំណត់ថាជាសាលាជម្រះក្តីថ្នាក់ទីពីរ[11]។ ប្រសិនបើភាគីនៃបណ្តឹងមិនពេញចិត្តក្នុងការសម្រេចសេចក្តីរបស់សាលាដំបូង គេអាចធ្វើការប្តឹងទាស់ទៅសាលាឧទ្ធរណ៍បានដែលមានទីតាំងនៅភ្នំពេញនិងនៅតាមតំបន់ផ្សេងៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា។សាលាឧទ្ធរណ៍មិនខុសពីសាលាដំបូងទេគឺមុននឹងបង្កើតគឺត្រូវមានព្រះរាជអនុញ្ញាតពីព្រះមហាក្សត្រជាមុនតាមរយៈព្រះរាជក្រឹត្យ។

សាលាឧទ្ធរណ៍ មានសមត្ថកិច្ចដោះស្រាយរឿងក្តីដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួនតែប៉ុណ្ណោះ[12]។ សាលាឧទ្ធរណ៍មិនអាចអនុវត្តនូវសិទ្ធិក្នុងការជម្រះក្តីលើសពីដែនសមត្ថកិច្ចរបស់ខ្លួនទេលើកលែងតែមានការប្តឹងទាស់ពីភាគីណាមួយនៃរឿងក្តីដែលគេមិនពេញចិត្ត និងមិនយល់ស្របទៅតាមសាលក្រមសាលាដំបូង។ គួរបញ្ជាក់ផងដែរថានៅក្នុងរឿងក្តីព្រហ្មទណ្ឌសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍មានសមត្ថកិច្ចក្នុងការដោះស្រាយបណ្តឹងទៅតាមនីតិវិធីនៃច្បាប់ដែលមានជាធរមានពោលគឺអនុវត្តទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌដែលមានជាធរមាន[13]។ សាលាឧទ្ធរណ៍ត្រូវគោរពនិងអនុវត្តយ៉ាងម៉ឺងម៉ាត់ទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌមុននឹងឈានទៅរកការសម្រេចសេចក្តីក្នុងបណ្តឹងណាមួយដើម្បីស្វែងរកយុត្តិធម៌ទៅតាមនីតិវិធី។ លើសពីនេះទៅទៀតសាលាឧទ្ធរណ៍សម្រេចសេចក្តីដោយផ្អែកទៅលើអង្គហេតុនិងអង្គច្បាប់[14]។

តុលាការនេះមាននូវមហាអយ្យការអមសាលាឧទ្ធរណ៍។ មហាអយ្យការនេះសំដៅទៅលើក្រុមប្រឹក្សាព្រះរាជអាជ្ញាដែលក្នុងនោះរួមមាន អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា និងក្រឡាបញ្ជី បូករួមទាំងម

[11] មាត្រា៣៥ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

[12] មាត្រា៤១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

[13] មាត្រា៤៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

[14] មាត្រា៤២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

ន្ត្រីរដ្ឋបាលទៀតផង[15]។ សាលាឧទ្ធរណ៍គឺជាសាលាជម្រះក្តីថ្នាក់ទីពីដែលមានសមត្ថកិច្ចជំនុំជម្រះបណ្តឹងដោយផ្អែកទៅលើអង្គហេតុ និងអង្គច្បាប់មុននឹងឈានទៅរកការចេញនូវសេចក្តីសម្រេចដោយសមស្របមួយបាន។

### ១.៣. តុលាការកំពូល

តុលាការកំពូលនេះជាតុលាការដែលមានទីតាំងតែមួយគត់នៅរាជធានីភ្នំពេញ[16]។ តុលាការកំពូលនេះទៀតសោធត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៤។

តុលាការកំពូលមានសមាសភាពដូចតទៅ:

- ប្រធាន អនុប្រធានតុលាការ
- ចៅក្រម
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអ្នកជំនាញការផ្នែកច្បាប់ថែមទៀត។

មិនត្រឹមតែប៉ុណ្ណោះតុលាការកំពូលមាននូវសភាជំនាញដូចសាលាជម្រះក្តីឯទៀតដែរ ដើម្បីជំនុំជម្រះបណ្តឹងតាមនីតិវិធីច្បាប់។ ដូចនេះសភានីមួយៗត្រូវទទួលខុសត្រូវនិងមានសមត្ថកិច្ចជម្រះក្តីទៅតាមជំនាញរបស់ខ្លួន។

នៅក្នុងតុលាការកំពូលនេះមាននូវស្ថាប័នមួយហៅថាមហាអយ្យការ ដែលមុខងារក្នុងការដាក់បណ្តឹងអាជ្ញាទៅតុលាការកំពូលបាន។ មុខងាររបស់មហាអយ្យការត្រូវបានប្រគល់ឲ្យព្រះរាជអាជ្ញាអមតុលាការកំពូលដែលជាអង្គអវិភាគដើម្បីតែងតាំង ព្រះរាជអាជ្ញាទៅចូលរួមនៅក្នុងសវនាការព្រហ្មទណ្ឌដែលពាក់ព័ន្ធជាមួយនិងការដកហូតសិទ្ធិសេរីភាពរបស់ជនត្រូវចោទ[17]។ អគ្គព្រះរាជអាជ្ញាមានអំណាចក្នុងការគ្រប់គ្រងលើព្រះរាជអាជ្ញានិងព្រះរាជអាជ្ញារងនៃតុលាការកំពូលដែលជាហេតុនាំឲ្យលោកមានអំណាចតែងតាំង ព្រះរាជអាជ្ញាឲ្យទៅតំណាងនៅក្នុងរឿងក្តីព្រហ្មទណ្ឌ[18] ព្រោះព្រះរាជអាជ្ញាត្រូវមានមុខនៅគ្រប់សវនាការទាំងអស់លើកលែងតែពេលលោកមានជម្ងឺឬមានធុរៈផ្សេងៗ។ នៅពេលនោះអគ្គព្រះរាជអាជ្ញានៃតុលាការកំពូលត្រូវចាត់តាំងព្រះរាជអាជ្ញាមួយរូបទៀតដើម្បីតំណាងម្ចាស់បណ្តឹងអាជ្ញានៅក្នុងរឿងព្រហ្មទណ្ឌព្រោះ ថាគ្រប់រឿងក្តីព្រហ្មទណ្ឌមិនអាចអវត្តមានព្រះរាជអាជ្ញាបានឡើយ។

[15] មាត្រា៤៩ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

[16] មាត្រា៥៥ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

[17] មាត្រា៦៩ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

[18] មាត្រា៧០ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

## ផ្នែកទី២ ៖ ឯករាជ្យភាពនៃស្ថាប័នតុលាការ

យើងបានដឹងហើយថាតុលាការនៅព្រះរាជាណាចក្រកម្ពុជាគឺជាស្ថាប័នឯករាជ្យមួយដែលមានអំណាចនៅក្នុងការបណ្តឹងទាំងឡាយណាដែលស្ថិតក្រោមសមត្ថកិច្ចដែនដីរបស់ខ្លួន។ នៅពេលដែលនិយាយអំពីឯករាជ្យភាពរបស់តុលាការមនុស្សជាច្រើនតែងតែមានចម្ងល់ចាក់ស្រេះនៅក្នុងចិត្តរបស់ខ្លួន។ តើឯករាជ្យភាពរបស់តុលាការនោះជាអ្វី? ហើយមានអ្វីដែលអាចវាស់នូវឯករាជ្យភាពរបស់តុលាការបាន?

ដើម្បីបកស្រាយនូវចម្ងល់ទាំងអស់នេះយើងគួរតែស្វែងយល់អំពីពាក្យថា «ឯករាជ្យភាពរបស់តុលាការ» ជាមុនសិន។ ផ្អែកតាមការស្រាវជ្រាវគេបានឲ្យនិយមន័យដល់ ឯករាជ្យភាពរបស់តុលាការថាជាភាពដែលឲ្យតុលាការ រឺ ចៅក្រមធ្វើការសម្រេចសេចក្តីទៅលើរឿងក្តីមួយដោយមិនមានការជ្រៀតជ្រែកពីរដ្ឋាភិបាលនិងស្ថាប័នរដ្ឋឬឯកជនណាមួយឡើយ[19]។

ការបកស្រាយខាងលើនេះមានន័យថារាល់សម្រេចសេចក្តីរបស់តុលាការមិនស្ថិតក្រោមសម្ពាធ រឺ ការគម្រាមកំហែងពីសំណាក់ស្ថាប័នរដ្ឋនិងស្ថាប័នឯកជនណាមួយឡើយ។ ពោលគឺចៅក្រមសម្រេចសេចក្តីដោយខ្លួនឯងដោយពឹងផ្អែកទៅលើនីតិវិធីនិងច្បាប់ដែលមានជាធរមាន ដើម្បីរក្សានូវយុត្តិធម៌ជូនពលរដ្ឋ។

ជាការពិតណាស់ ឯករាជ្យភាពរបស់តុលាការពិតជាគ្មាននូវរង្វាស់ជាឯកត្តាលក្ខណៈអន្តរជាតិណាមួយឡើយ។ ក៏ប៉ុន្តែអង្គការសហប្រជាជាតិដែលជាអង្គការអន្តរជាតិថ្នាក់កំពូលមួយបានធ្វើការកំណត់នូវឯករាជ្យភាពរបស់តុលាការតាមរយៈការអនុម័តនូវលិខិតតូបករណ៍ដើម្បីឲ្យរដ្ឋជាសមាជិកអនុវត្តតាម។ យោងតាមគោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការដើម្បីធានារក្សានូវឯករាជ្យរបស់តុលាការបាន រដ្ឋមួយត្រូវកំណត់អំពីឯករាជ្យរបស់តុលាការនៅក្នុងរដ្ឋធម្មនុញ្ញ រឺច្បាប់កំពូលរបស់រដ្ឋនោះ។ លើសពីនេះទៅទៀតតុលាការត្រូវដើរតួជាអ្នកដោះស្រាយរឿងក្តីជូនប្រជាពលរដ្ឋចំពោះមុខរបស់ខ្លួន ដោយមិនមានភាពលម្អៀងទៅខាងណាមួយ រឺធ្វើការសម្រេចសេចក្តីដោយមិនមានការជ្រៀតជ្រែកពីអំណាចកំពូលរបស់រដ្ឋណាមួយឡើយ។

យោងតាមការបកស្រាយខាងលើស្ថាប័នតុលាការ គឺជាស្ថាប័នមួយក្នុងចំណោមស្ថាប័នធំៗទាំងបីរួមមាន ស្ថាប័ននីតិបញ្ញាត្តិ និងស្ថាប័ននីតិប្រតិបត្តិ និងធានានូវឯករាជ្យរបស់ស្ថាប័ននេះផងដែរ[20]។ ស្ថាប័នតុលាការនេះទៀតសោធត្រូវតែមាននូវអំណាចឯករាជ្យដាក់លាក់គឺ អំណាចតុលាការ ជាអំណាចឯករាជ្យ។ នៅក្នុងន័យនេះតុលាការមិនត្រូវមានការជ្រៀតជ្រែកពីអំណាចដ៏ទៃឡើយ នៅពេលដែលចៅក្រមជំនុំជម្រះចេញ

[19] Law. (n.d.). judicial independence | Definition, Scope, & Facts | Britannica.ទទួលបាន August 14, 2020, ពី https://www.britannica.com/topic/judicial-independence

[20] សៀវភៅ មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់ ដោយ លោក ឥន យឿន

សាលក្រម រឺ សាលដីកាគ្មានអង្គការណាមួយអាចរារាំងដោយប្រើអំណាចទៅលើការអនុវត្តច្បាប់របស់មន្ត្រីតុលាការបានឡើយ។

### ២.១. ឯករាជ្យភាពបុគ្គល

ដើម្បីធានានូវឯករាជ្យភាពរបស់តុលាការនេះបានអង្គជំនុំជម្រះរបស់តុលាការ (ចៅក្រមជំនុំជម្រះ) ត្រូវមានឯករាជ្យភាពបុគ្គលពោល គឺសមាសភាពនីមួយៗត្រូវមាននូវឯករាជ្យភាពនៅក្នុងការសម្រេចសេចក្ដីនិងមានការធានាឲ្យបាននូវមុខងារ និងតួនាទីរបស់ចៅក្រម[21] ។ ក្នុងន័យនេះគឺធ្វើឲ្យចៅក្រមមាននូវទំនុកចិត្តទៅលើមុខងាររបស់ខ្លួននិងប្រកបនូវវិជ្ជាជីវៈរបស់ខ្លួនឲ្យកាន់តែល្អទៅទៀត។ ម្យ៉ាងវិញទៀតប្រសិនបើចៅក្រមមានភាពភ័យខ្លាចនៅក្នុងការសម្រេចសេចក្ដីរបស់ខ្លួននោះ នឹងនាំមកនូវភាពអគតិដែលមានចែងនៅក្នុងក្រមសីលធម៌ និងវិជ្ជាជីវៈរបស់ចៅក្រមមិនអាចឲ្យចៅក្រមប្រកបតួនាទីរបស់ខ្លួនបានខ្ជាប់ខ្ជួននោះឡើយ។ ក្រៅពីតុលាការគ្មានអង្គការកំពូលណាអាចទទួលដោះស្រាយ និងសម្រេចសេចក្ដីជំនួសស្ថាប័នតុលាការបានឡើយមានតែអង្គការតុលាការទេដែលមានអំណាចក្នុងការទទួលយករឿងក្ដីមកដោះស្រាយដោយអនុលោមតាមច្បាប់ និងនីតិវិធី។

### ២.២. ឯករាជ្យភាពថវិការរបស់ស្ថាប័នតុលាការ

ជាការពិតណាស់ ដើម្បីឲ្យស្ថាប័នមួយមាននូវឯករាជ្យមិនពឹងផ្អែកទៅលើស្ថាប័នដ៏ទៃស្ថាប័ននោះត្រូវតែមាននូវថវិកាដោយឡែកដើម្បីប្រើប្រាស់នៅក្នុងក្របខណ្ឌរបស់ខ្លួន។ចំពោះស្ថាប័នតុលាការនៅព្រះរាជាណាចក្រកម្ពុជាវិញច្បាប់បានកំណត់យ៉ាងជាក់លាក់ថា សាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់ និងអយ្យការអមតុលាការទាំងអស់នោះមានកញ្ចប់ថវិការដោយឡែកនៅឯក្រសួងយុត្តិធម៌។ នៅក្នុងករណីនេះផងដែរប្រធានតុលាការគ្រប់ជាន់ថ្នាក់មានសិទ្ធិនៅក្នុងការស្នើថវិការពីដែលផ្ទេរមកពីរដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌ [22]។

[21] សៀវភៅ មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់ ដោយ លោក ឥន យឿន

[22] មាត្រា៧៩ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ

# ជំពូកទី២

# ដំណាក់កាលមុននីតិវិធីជំនុំជម្រះ

# ជំពូកទី២

# ដំណាក់កាលមុននីតិវិធីជំនុំជម្រះ

## ផ្នែកទី១៖ មន្ត្រីនគរបាលយុត្តិធម៌

### ១.១. មន្ត្រីនគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ គឺជាជំនួយការរបស់ស្ថាប័នតុលាការដែលមានភារកិច្ចនៅក្នុងការត្រួតពិនិត្យនូវបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់នូវអត្តសញ្ញាណជនសង្ស័យនិងជនរងគ្រោះចាប់ជនដៃដល់ដែលប្រព្រឹត្តបទល្មើស និងប្រមូលទឡ្ហីករផងដែរ [23]។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែរៀនជំនាញឯកទេសច្បាស់លាស់នៅជំនាញវិជ្ជាជីវៈជាពិសេសចេះពីនីតិវិធីព្រហ្មទណ្ឌសំរាប់យកទៅអនុវត្តនៅពេលបំពេញមុខងារ។

មន្ត្រីនគរបាលយុត្តិធម៌ចេញជា បីដូចជា៖

- មន្ត្រីនគរបាលយុត្តិធម៌
- ភ្នាក់ងារនគរបាលយុត្តិធម៌
- មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ។

ទោះបីជាច្បាប់បានកំណត់នូវសមត្ថកិច្ចរបស់នគរបាលយុត្តិធម៌នៅក្នុងការត្រួតពិនិត្យ និងធ្វើការឃាត់ខ្លួនក៏ពិតមែនក៏ការអនុវត្តនូវនីតិវិធីទាំងនោះគឺស្ថិតនៅក្រោមអំណាច និងការឃ្លាំមើលរបស់ព្រះរាជអាជ្ញាផងដែរ។

### ១.២.បេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ គឺជាភ្នាក់ងារជំនួយដ៏សំខាន់របស់អង្គការតុលាការនៅក្នុងបទល្មើសព្រហ្មទណ្ឌនៅក្រោមការបង្គាប់បញ្ជារបស់ព្រះរាជអាជ្ញានិងចៅក្រមស៊ើបសួរ។

ក្រៅពីកិច្ចការទាំងអស់ខាងលើនេះមន្ត្រីនគរបាលយុត្តិធម៌មានបេសកកម្ម និង ភារៈកិច្ចមួយចំនួនទៀតរួមមាន៖

- ទទួលបណ្តឹងទាមទារ និងបណ្តឹងបរិហារកេរ្តិ៍
- ពិនិត្យបទល្មើសទាំងឡាយ
- សសេរពាក្យបណ្តឹង
- បោះត្រាលើវត្ថុតាង
- ត្រួតពិនិត្យទីកន្លែងមានបទល្មើសកើតឡើង
- សួរចម្លើយជនសង្ស័យ

[23] មាត្រា៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

- ធ្វើការស៊ើបអង្កេតបទល្មើសជាក់ស្តែង
- ធ្វើការស៊ើបអង្កេតបឋម និងការអនុវត្តនូវដីការចាត់ឲ្យស៊ើបសួរផងដែរ។

### ១.២.១.ការទទួលពាក្យបណ្តឹង

នីតិវិធីដំបូងដែលមានវត្តមានរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺការទទួលពាក្យបណ្តឹង។ ជាក់ស្តែងនៅពេលដែលប្រជាពលរដ្ឋបានជួបប្រទះទៅនឹង បទល្មើសព្រហ្មទណ្ឌពួកគាត់រមែងធ្វើការដាក់ពាក្យបណ្តឹងមកកាន់ អង្គភាពនគរបាលយុត្តិធម៌នៅតាមមូលដ្ឋានដើម្បីធ្វើការចុះទៅបង្ក្រាបបទល្មើសដែលកំពុងតែកើតមានឡើង។ ការទទួលពាក្យបណ្តឹងនោះ គឺតម្រូវឲ្យនគរបាលយុត្តិធម៌ដែលពលរដ្ឋដាក់ពាក្យបណ្តឹងធ្វើការកសាងនូវសំណុំរឿង រឺធ្វើកំណត់ហេតុនៃបទល្មើសដើម្បីបញ្ជូនទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។

នៅក្នុងការដាក់ពាក្យបណ្តឹងមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែតម្រូវឲ្យបំពេញនូវលក្ខខណ្ឌមួយចំនួនដូចតទៅ៖

- បំពេញឈ្មោះ និងឋានៈរបស់នមន្ត្រីនគរបាលយុត្តិធម៌
- អង្គភាពរបស់នគរបាលយុត្តិធម៌ និងកាលបរច្ឆេទនៃពាក្យបណ្តឹង។

ក្រៅពីលក្ខខណ្ឌខាងលើនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការចុះហត្ថលេខាជាមួយអ្នកដាក់ពាក្យបណ្តឹងនៅក្នុងពាក្យបណ្តឹងនោះផងដែរនៅលើទំព័រនីមួយៗនៃពាក្យបណ្តឹងដែលបានដាក់នោះ។ អ្វីដែលគួរឲ្យកត់សម្គាល់ជាងនេះទៅទៀតមុនធ្វើការចុះហត្ថលេខា រឺផ្តិតមេដៃនៅលើពាក្យបណ្តឹងនោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែឲ្យអ្នកប្តឹងនោះអាននូវពាក្យបណ្តឹងនោះឡើងវិញម្តងទៀត ដើម្បីរក្សានូវសុក្រឹត្យភាពនៅក្នុងពាក្យបណ្តឹងជៀសវាងមានការខុសឆ្គងនៅកន្លែងណាមួយនៃពាក្យបណ្តឹង។ក្នុងករណីដែលអ្នកដាក់ពាក្យបណ្តឹងមិនចេះអានអក្សរខ្មែរ រឺមួយជាជនបរទេស មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានពាក្យបណ្តឹងនោះឲ្យលឺៗ ដើម្បីឲ្យម្ចាស់បណ្តឹង រឺអ្នកបកប្រែបានលឺដើម្បីងាយស្រួលក្នុងការកែប្រែអត្ថន័យព្រមទាំងងាយស្រួលយល់ផងដែរ[24]។

### ១.២.២.ការឃាត់ខ្លួនជនសង្ស័យ

នៅពេលដែលមានបទល្មើសកើតមានឡើងអាជ្ញាធរមូលដ្ឋានរឺនគរបាលយុត្តិធម៌នៃមូលដ្ឋាននោះត្រូវតែធ្វើការចុះទៅបង្ក្រាប និងត្រួតពិនិត្យនូវបទល្មើសព្រហ្មទណ្ឌដែលកំពុងកើតមានឡើងនៅទីតាំងនោះ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការឃាត់ខ្លួនជនសង្ស័យនៅនឹងកន្លែងតែម្តងនៅក្នុងករណីបទល្មើសជាបទល្មើសជាក់ស្តែង។ ការឃាត់ខ្លួនជនសង្ស័យនោះផងដែរក្នុងករណីដែលបទល្មើសនោះបានកើតរួចហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការស្រាវជ្រាវ និងស៊ើបអង្កេតស្វែងរកជនសង្ស័យដែលប្រព្រឹត្តបទល្មើសនោះ។ ប្រសិនបើ

[24] សៀវភៅគោលការណ៍ទូទៅនៃក្រមទាំងបួន (មេរៀនសង្ខេប)

នគរបាលយុត្តិធម៌ទទួលបាននូវព័ត៌មានស្តីពីបទល្មើសព្រហ្មទណ្ឌ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការផ្តល់ដំណឹងទៅដល់ព្រះរាជអាជ្ញាដើម្បីឲ្យព្រះរាជអាជ្ញាចេញនូវដីកាឃាត់ខ្លួន[25]។

ក៏ប៉ុន្តែតាមការអនុវត្តជាក់ស្តែងនៅក្នុងករណីបន្ទាន់ ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវធ្វើការឃាត់ខ្លួនជនសង្ស័យភ្លាមៗ រួចទើបផ្តល់ដំណឹងឲ្យព្រះរាជអាជ្ញាដើម្បីឲ្យព្រះរាជអាជ្ញាចេញដីកាឃាត់ខ្លួនតាមក្រោយក៏បាន។ នៅក្នុងករណីមានបទល្មើសព្រហ្មទណ្ឌកម្រិតធ្ងន់រឺបទឧក្រិដ្ឋ នគរបាលយុត្តិធម៌ត្រូវធ្វើការផ្តល់ដំណឹងទៅព្រះរាជអាជ្ញាដើម្បីឲ្យព្រះរាជអាជ្ញាធ្វើការចេញនូវលិខិតពន្យាពេលនៃការឃាត់ខ្លួនជនសង្ស័យនោះ លិខិតស្នើសុំនិងលិខិតអនុញ្ញាត្តិឲ្យពន្យាពេលនៃការឃុំខ្លួនជនសង្ស័យត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។

នៅក្នុងការឃាត់ខ្លួនជនសង្ស័យត្រូវបានកំណត់យ៉ាងច្បាស់លាស់អំពីថេរវេលានៃការឃាត់ខ្លួន ពោលគឺមិនឲ្យលើសពី៤៨ម៉ោងនោះទេដែលថិរវេលានេះ គឺគេគិតតាំងពីឃាត់ខ្លួនជនសង្ស័យមកដល់ទីស្នាក់ការនគរបាលយុត្តិធម៌ដែលនៅមូលដ្ឋាន រឺមួយនៅកន្លែងកងរាជអាវុធហត្ថតែម្តង។ ក្នុងករណីខ្លះការឃាត់ខ្លួននេះអាចបន្តដល់២៤ម៉ោងបន្ថែមពីលើនេះទៅទៀត ប្រសិនបើមានការស្នើរសុំពីព្រះរាជអាជ្ញាដើម្បីស្វែងរកនូវតម្រុយបន្ថែមពាក់ព័ន្ធទៅនឹងជនដែលមានពិរុទ្ធភាពនោះ។ គួរបញ្ជាក់ផងដែរថាក្រមនីតិវិធីព្រហ្មទណ្ឌបានបែងចែកនូវថេរវេលាជាក់លាក់បន្ថែមទៀតពាក់ព័ន្ធនឹងប្រភេទនៃជនបទល្មើសទៀតផង។

| ប្រភេទនៃបទល្មើស | អាយុ | ថិរវេលាកំណត់ |
|---|---|---|
| បទឧក្រិដ្ឋ | ពី១៤ឆ្នាំ- ១៦ ឆ្នាំ | ៣៦ ម៉ោង |
| បទមជ្ឈិម | ពី១៤ ឆ្នាំ- ក្រោម១៦ ឆ្នាំ | ២៤ ម៉ោង |
| បទឧក្រិដ្ឋ | ពី១៦ ឆ្នាំ - ក្រោម១៨ ឆ្នាំ | ៤៤ ម៉ោង |
| បទមជ្ឈិម | ពី១៦ ឆ្នាំ - ក្រោម១៨ ឆ្នាំ | ៣៦ ម៉ោង |

ការឃាត់ខ្លួនដែលបានជម្រាបជូនខាងលើនេះត្រូវបានធ្វើឡើងដោយមានការកសាងនូវលិខិតមួយដែលគេហៅថា កំណត់ហេតុនៃការឃាត់ខ្លួន។ កំណត់ហេតុនេះត្រូវតែមានជាដាច់ខាតនៅពេលធ្វើការឃាត់ខ្លួនជនសង្ស័យណាម្នាក់ទៅទីកន្លែងនគរបាលមានសមត្ថកិច្ច។ នៅក្នុងលិខិតនោះត្រូវតែមានកត់ត្រានូវអត្តសញ្ញាណសំខាន់ៗដូចតទៅ៖

- ឈ្មោះ និងឋានៈរបស់នគរបាលនោះ
- អត្តសញ្ញាណរបស់ជនសង្ស័យដែលត្រូវបានឃាត់ខ្លួន
- មូលហេតុជាក់លាក់នៃការឃាត់ខ្លួន

[25] មាត្រា៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជាណាចក្រកម្ពុជា

- ថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការចាប់ផ្តើមអនុវត្តការឃាត់ខ្លួន
- ការផ្តល់នូវព័ត៌មានទៅដល់មេធាវីការពារសិទ្ធិជនដែលត្រូវឃាត់ខ្លួនក្រោយឃាត់ខ្លួនបាន២៤ម៉ោង។

កំណត់ហេតុនៃការឃាត់ខ្លួនត្រូវធ្វើការផ្តិតមេដៃដោយជនឃាត់ខ្លួនក្រោយពេលអាននូវលិខិតនោះចប់។ ករណីដែលជនសង្ស័យមិនចេះអក្សរមន្ត្រីនគរបាលយុត្តិធម៌ ត្រូវអានកំណត់ហេតុនោះឲ្យខ្លាំងៗដើម្បីឲ្យជនដែលត្រូវបានគេឃាត់ខ្លួននោះលឺ។ ក្នុងករណីជនបរទេសនគរបាលយុត្តិធម៌ត្រូវអានលិខិតនោះឲ្យខ្លាំងៗដើម្បីឲ្យអ្នកបកប្រែបានលឺនិងបកប្រែលិខិតនោះឲ្យជនត្រូវបានគេឃាត់ខ្លួន [26]។

### ១.២.៣.ការធ្វើកំណត់ហេតុនៃបទល្មើស

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបានច្បាប់កំណត់នូវបេសកកម្មមួយចំនួនដែលក្នុងនោះរួមមានការធ្វើកំណត់ហេតុនៃបទល្មើសព្រហ្មទណ្ឌផងដែរ។នៅក្នុងរឿងព្រហ្មទណ្ឌគេបានបែងចែងបណ្តឹងចេញជា ៤ដំណាក់កាលពេលគឺ៖

- ដំណាក់កាលស៊ើបអង្កេត រឺមួយកំណត់ហេតុ
- ដំណាក់កាលចោទប្រកាន់
- ដំណាក់កាលស៊ើបសួរ
- ដំណាក់កាលជំនុំជម្រះ[27]

នៅក្នុងដំណាក់កាលដំបូងដែលជាដំណាក់កាលស៊ើបអង្កេតឬកសាងកំណត់ហេតុនៃបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ ជាអ្នកទទួលពាក្យបណ្តឹងបរិហារពីប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានឬទទួលពាក្យបណ្តឹងពីស្ថាប័នពាក់ព័ន្ធនានាដែលធ្វើការប្តឹងបរិហារពីបទល្មើសព្រហ្មទណ្ឌ។ ក្រោយពីបានទទួលពាក្យបណ្តឹងមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការត្រួតពិនិត្យនូវបទល្មើសដែលគេបានដាក់ពាក្យប្តឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះទៅពិនិត្យនៅកន្លែងកើតហេតុ និង ឃាត់ខ្លួនជនល្មើសនៅក្នុងករណីដែលភ្នាក់ងារនគរបាលយុត្តិធម៌បានឃើញបទល្មើសដោយផ្ទាល់ទើបកសាងសំណុំរឿងបញ្ជូនបន្តទៅខាងថ្នាក់លើ(ចៅក្រមស៊ើបសួរ) ដើម្បីត្រួតពិនិត្យដែលគេច្រើនហៅថា ការស៊ើបអង្កេតបឋម[28]។ ការស៊ើបអង្កេតបឋមនេះត្រូវធ្វើឡើងក្នុងក្របខណ្ឌបទល្មើស(បទឧក្រិដ្ឋ និងបទមជ្ឈិម) ដែលកំពុងប្រព្រឹត្ត[29]។ ឧទាហរណ៍៖ នៅពេលដែលមានជនសង្ស័យណាម្នាក់កំពុងធ្វើទារុណកម្ម

[26] មាត្រា៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[27] សៀវភៅនីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល

[28] មាត្រា៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[29] មាត្រា៨៦ ចំណុចទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ទៅលើជនរងគ្រោះ។ មន្ត្រីនគរបាលយុត្តិធម៌បានឃើញហើយក៏ឃាត់ខ្លួនជនសង្ស័យនិងប្រមូលនូវភស្តុតាងទៅអង្គភាពរបស់ខ្លួនដើម្បីកសាងកំណត់ហេតុបញ្ជូនទៅចៅក្រមស៊ើបសួរ[30] ។

### ១.២.៤.ការស្តាប់ចម្លើយរបស់ជនសង្ស័យ

ក្រោយពីបានឃើញជាក់ស្តែងនូវបទល្មើសព្រហ្មទណ្ឌណាមួយ នគរបាលយុត្តិធម៌ត្រូវតែហៅឲ្យបុគ្គលដែលមានការពាក់ព័ន្ធជាមួយ នឹងបទល្មើសដើម្បីធ្វើការស្តាប់ចម្លើយពីជនទាំងនោះសំរាប់ធ្វើជាកំណត់ហេតុបន្ថែមទៅលើបទល្មើសនោះ។ មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិនៅក្នុងការស្តាប់ចម្លើយពីជនដែលខ្លួនបានហៅមកដើម្បីសួរចម្លើយ។ នៅក្នុងកំណត់ហេតុនោះទៀតសោធមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែកត់ត្រានូវសេចក្តីរាយការណ៍ពីបុគ្គលនោះឲ្យបានច្បាស់លាស់ទៅតាមអង្គហេតុនៃបទល្មើសដែលបានកើតឡើង។ នៅក្នុងករណីជននោះជាជនជាតិដើមភាគតិច រឺមួយជនបរទេសដែលមិនអាចសន្ទនាជាភាសាខ្មែរបានមន្ត្រីនគរបាលយុត្តិធម៌ត្រូវស្វែងរកអ្នកបកប្រែ ដើម្បីឲ្យមកជួយសម្រួលនៅការធ្វើការស្តាប់ចម្លើយនិងធ្វើកំណត់ហេតុនៃបទល្មើសនោះ។

អ្វីដែលគួរឲ្យកត់សម្គាល់ជាងនេះទៅទៀត គឺថាអ្នកបកប្រែនោះត្រូវតែធ្វើសម្បថស្របទៅតាមសាសនានិងជំនឿរបស់ខ្លួនថានឹងនិយាយតែការពិតមិនកុហក ហើយអ្នកបកប្រែនោះត្រូវតែមិនមែនជាបុគ្គលដែលជ្រើសរើសចេញពីមន្ត្រីនគរបាលយុត្តិធម៌កងរាជអាវុធហត្ថ រឺជនដែលពាក់ព័ន្ធជាមួយរឿងក្តីនោះបានទេ។ ក្រោយពីស្តាប់ចម្លើយនិងសរសេរកំណត់ហេតុរួចនៅលើទំព័រនីមួយៗ នៃកំណត់ហេតុដែលបានកត់ត្រានូវអង្គហេតុនោះត្រូវតែមានស្នាមមេដៃរបស់ម្ចាស់នៃចម្លើយទុកជា ភស្តុតាងថាជាចម្លើយដែលចេញមកពីមាត់របស់ជននោះយ៉ាងពិតប្រាកដមិនមានការក្លែងបន្លំ។ មុននឹងធ្វើការផ្តិតមេដៃទៅលើកំណត់ហេតុ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឲ្យជននោះអាននូវកំណត់ហេតុនោះឡើងវិញ។

មួយវិញទៀតនៅក្នុងករណីដែលជនរងគ្រោះមិនចេះអានអក្សរខ្មែរ នគរបាលយុត្តិធម៌ត្រូវតែអាននូវអង្គហេតុដែលបានកត់ត្រាឲ្យខ្លាំងដើម្បីជាសក្ខីកម្ម និងជាការបញ្ជាក់នូវអង្គហេតុនោះឲ្យម្ចាស់ចម្លើយបានដឹង។ ក្នុងករណីខ្លះតម្រូវឲ្យមន្ត្រីនគរបាលយុត្តិធម៌ ត្រូវអាននូវកំណត់ហេតុនោះឲ្យខ្លាំងៗដើម្បីឲ្យអ្នកបកប្រែនោះធ្វើការបកប្រែឲ្យម្ចាស់ចម្លើយនោះស្តាប់ដើម្បីងាយស្រួលកែតម្រូវប្រសិនបើមានការខុសឆ្គងនៅកន្លែងណាមួយ[31]។

### ១.២.៥.ការបោះត្រាទៅលើវត្ថុតាង

ជាធម្មតានៅពេលប្រតិបត្តិការមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះទៅផ្ទាល់នៅកន្លែងកើតហេតុដើម្បីឃាត់ខ្លួនជនសង្ស័យធ្វើការប្រមូលនូវសក្ខីកម្មនៃបទល្មើសនិងធ្វើការប្រមូលវត្ថុតាងផងដែរ។ មន្ត្រីនគរបាលយុត្តិធម៌ដែលចុះទៅកន្លែងកើតហេតុដើម្បីពិនិត្យ និងបង្ក្រាបបទល្មើសដែលកំពុងតែកើតឡើង។ មន្ត្រីនគរបាលយុត្តិធម៌ មាន

---

[30] គោលការណ៍ទូរទៅនៃនីតិក្រមទាំងបួនរបស់សាស្ត្រាអាត ច័ន្ទដារា និងសុង ប៊ុនឃៀង

[31] មាត្រា៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

សិទ្ធអំណាចក្នុងការចាប់យកវត្ថុតាងដើម្បីទុកជាទឡ្ហីករបាន។ មួយវិញទៀតដើម្បីរក្សានូវភាពច្បាស់លាស់នៅលើវត្ថុតាងនោះភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវធ្វើការបោះត្រាទៅលើវត្ថុតាងទាំងឡាយណា ដែលប្រមូលបាន រឺចាប់បានពីកន្លែងកើតហេតុ។

ក្រោយពីការចាប់និងបោះត្រាទៅលើវត្ថុតាងរួច មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការបង្ហាញវត្ថុតាងទាំងនោះទៅដល់ម្ចាស់ទីតាំង រឺបង្ហាញទៅសាក្សីចំនួនពីររូបផងដែរដើម្បីធ្វើកំណត់ហេតុនៃការចាប់យកវត្ថុតាងព្រមទាំងបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលបានចាប់យកផងដែរ។ បន្ទាប់មកទៀតមន្ត្រីនគរបាលយុត្តិធម៌ត្រូវឲ្យជនដែល

ជាម្ចាស់នៃទីកន្លែងកើតហេតុ រឺសាក្សីពីររូបនោះធ្វើការចុះហត្ថលេខារឺផ្តិតស្នាមមេដៃដើម្បីបញ្ជាក់ថាភស្តុតាងនេះពិតជាប្រមូលពីកន្លែងកើតហេតុពិតប្រាកដមែន ។

### ១.៣. ការបញ្ជូនខ្លួនជនសង្ស័យទៅកាន់ព្រះរាជអាជ្ញា

បន្ទាប់ពីការឃាត់ខ្លួនជនសង្ស័យទៅតាមថេរវេលាដែលច្បាប់បានកំណត់រួចមក នគរបាលយុត្តិធម៌ត្រូវធ្វើកានាំខ្លួនជននោះទៅប្រគល់ឲ្យព្រះរាជអាជ្ញារឺមួយដោះលែង នៅក្នុងករណីដែលជនដែលត្រូវបានគេឃាត់ខ្លួននោះត្រូវបានរកឃើញថាមិនមាននូវពិរុទ្ធភាពនោះទេ។ សេចក្តីសម្រេចដែលត្រូវដោះលែងរឺបញ្ជូនខ្លួនបន្តទៅកាន់ព្រះរាជអាជ្ញានេះត្រូវធ្វើឡើងដោយព្រះរាជអាជ្ញាតែម្នាក់ប៉ុណ្ណោះ ប្រសិនបើមិនមានការយល់ព្រមទេនគរបាលយុត្តិធម៌ពុំមានសិទ្ធិក្នុងការដោះលែងរឺបញ្ជូនបន្តទៅព្រះរាជអាជ្ញាទេ [32]។

ការបញ្ជូនខ្លួនជនសង្ស័យទៅកាន់ព្រះរាជអាជ្ញាត្រូវមានពេលវេលាជាក់លាក់។ នៅពេលដែលព្រះរាជអាជ្ញា បានអនុញ្ញាតឲ្យនគរបាលយុត្តិធម៌ធ្វើការបញ្ជូនខ្លួនជននោះទៅកាន់ព្រះរាជអាជ្ញាភ្លាមៗតែម្តង។ នៅក្នុងករណីដែលពិបាកធ្វើការដឹកជញ្ជូនជនសង្ស័យទៅកាន់ព្រះរាជអាជ្ញារឺមួយមានករណីពិសេសណាមួយ ព្រះរាជអាជ្ញានឹងត្រូវបានផ្តល់ពេលវេលាបន្ថែមដើម្បីធ្វើការបង្ហាញខ្លួនរបស់ជនសង្ស័យ។

## ផ្នែកទី២៖ ដំណាក់កាលអយ្យការ

### ២.១. ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា គឺសំដៅទៅដល់ អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងដែលស្ថិតនៅក្នុងស្ថាប័នអយ្យការ [33]។ គួរឲ្យដឹងផងដែរថាព្រះរាជអាជ្ញាត្រូវតែបំពេញមុខងាររបស់ខ្លួនទៅតាមស្ថាប័នអយ្យការអមតុលាការគ្រប់ជាន់ថ្នាក់។ ព្រះរាជអាជ្ញាត្រូវប្រតិបត្តិការងាររបស់ខ្លួននៅតាមអង្គអយ្យការអម

[32] មាត្រា១០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[33] មាត្រា៣ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា

សាលាជម្រះក្តីជាន់ខ្ពស់ ព្រោះថាមិនថាសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូលសុទ្ធតែមានអយ្យការអមសាលាជម្រះក្តីទាំងនោះព្រោះព្រះរាជអាជ្ញាគឺមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងរឿងព្រហ្មទណ្ឌ។

### ២.១.១. អំណាចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាមានអំណាចក្នុងការដឹកនាំ និងសម្របសម្រួលកិច្ចការ និងសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនដើម្បីឲ្យដំណើរការនៅក្នុងការស៊ើបអង្កេត និងការកសាងសំណុំរឿងមានលក្ខណៈងាយស្រួលព្រមទាំងមានភាពត្រឹមត្រូវទៅតាមបញ្ញត្តិច្បាប់។ លើកលែងតែនៅក្នុងពេលដែលដំណើរការបណ្តឹង ទៅដល់ចៅក្រមស៊ើបសួរតែប៉ុណ្ណោះទើបនគរបាលយុត្តិធម៌ស្ថិតក្រោមការបង្គាប់បញ្ជារបស់ចៅក្រមស៊ើបសួរ។

បន្ទាប់ពីដំណាក់កាលនគរបាលយុត្តិធម៌ចប់សព្វគ្រប់នគរបាលយុត្តិធម៌ នឹងកសាងសុំណុំរឿងទៅឲ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ បណ្តឹងព្រហ្មទណ្ឌនឹងធ្លាក់ទៅលើដៃព្រះរាជអាជ្ញាដែលជាតួអង្គសំខាន់មួយនៅក្នុងរឿងព្រហ្មទណ្ឌដែលពុំអាចខ្វះបានព្រោះព្រះរាជអាជ្ញា ជាអ្នកតំណាងឲ្យម្ចាស់បណ្តឹងព្រហ្មទណ្ឌដែលគេហៅថាបណ្តឹងអាជ្ញាដោយហេតុថាព្រះរាជអាជ្ញាជាអ្នកចោទប្រកាន់ទៅជនសង្ស័យ។

អំណាចមួយចំនួនទៀតដែលច្បាប់បានកំណត់ឲ្យព្រះរាជអាជ្ញាមានដូចតទៅ៖

- ដឹកនាំអង្គភាពនគរបាលយុត្តិធម៌ដើម្បីជួយសម្រួលនូវចុះរបស់អង្គភាពនគរបាល និងមន្ត្រីនគរបាល[34]
- ព្រះរាជអាជ្ញាដែលជាអង្គមិនអាចបំបែកបាននេះ មានអំណាចនៅក្នុងការចុះទៅកន្លែងស៊ើបអង្កេតនិងដឹកនាំសមត្ថកិច្ចមន្ត្រីនគរបាលយុត្តិធម៌ដើម្បីធ្វើការស៊ើបអង្កេត ព្រមទាំងដកសិទ្ធិមន្ត្រីនគរបាលយុត្តិធម៌ នឹងតែងតាំងមន្ត្រីថ្មីមកជំនួសតំណែងមន្ត្រីនគរបាលយុត្តិធម៌ដែលបានដកហូតសិទ្ធិនោះផងដែរ។ដោយឡែកនៅពេលដំណាក់កាលចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញាពុំមានអំណាចនៅក្នុងការគ្រប់គ្រងទៅលើមន្ត្រីនគរបាលយុត្តិធម៌ដោយហេតុថាចៅក្រមស៊ើបសួរ ត្រូវបានច្បាប់កំណត់ឲ្យខ្លួនគ្រប់គ្រងលើនគរបាលយុត្តិធម៌នៅក្នុងការអនុវត្តដីកាសម្រេចឲ្យស៊ើបសួររួចទៅហើយ[35]។
- ព្រះរាជអាជ្ញាត្រូវបានច្បាប់អនុញ្ញាតឲ្យធ្វើអធិការកិច្ច រឺ ចុះត្រួតពិនិត្យគ្រប់ពេលវេលានៅតាមអង្គភាពរបស់នគរបាលយុត្តិធម៌ដើម្បីត្រួតពិនិត្យ និងតាមដានសំណុំរឿងព្រមទាំងជនសង្ស័យ។ លើសពីនេះទៅទៀតព្រះរាជអាជ្ញាអាចធ្វើការបង្ហាញខ្លួននៅក្នុងពេលស្តាប់ចម្លើយរបស់ជនសង្ស័យ និងត្រួតពិនិត្យទៅលើនីតិវិធីនៃការឃាត់ខ្លួនឲ្យអនុវត្តទៅលើជនសង្ស័យបានត្រឹមត្រូវតាម នីតិវិធីដែលមានជាធរមាន

[34] មាត្រា៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[35] មាត្រា៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

ដើម្បីកុំឲ្យមានការខុសឆ្គងតាមច្បាប់ជៀសវាង មានការរំលោភបំពានទៅលើសិទ្ធិរបស់ជនសង្ស័យនៅក្នុងប្រការណាមួយ[36]។

- ព្រះរាជអាជ្ញាដែលស្ថិតនៅក្រោមស្ថាប័នអយ្យការអមសាលាដំបូងគឺជាអង្គដែលមិនអាចបំបែកបាន និងជាតួអង្គដ៏សំខាន់ក្នុងការតំណាងនៅក្នុងបណ្តឹងអាជ្ញា។ ព្រះរាជអាជ្ញាអាចអនុវត្តនូវអំណាចរបស់ខ្លួនយ៉ាងពេញទំហឹងនៅក្នុងការគ្រប់គ្រង និង តាមដានទៅលើការអនុវត្តច្បាប់របស់មន្ត្រីនគរបាលយុត្តិធម៌ ហើយព្រះរាជអាជ្ញាក៏មានអំណាចនៅក្នុងការដឹកនាំមន្ត្រីនគរបាលយុត្តិធម៌ដើម្បីស៊ើបអង្កេតនៅក្នុងកន្លែងកើតហេតុផងដែរ។ ជារឿយៗព្រះរាជអាជ្ញាអាចធ្វើការចុះទៅត្រួតពិនិត្យនៅទីស្នាក់ការមន្ត្រីនគរបាលយុត្តិធម៌ដើម្បីត្រួតពិនិត្យទៅលើនីតិវិធីក្នុងការឃាត់ខ្លួន និង ធ្វើការត្រួតពិនិត្យទៅលើជនសង្ស័យផងដែរ។

## ២.២.ការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការនេះ គឺជានីតិវិធីមួយនៃក្រមនីតិវិធីព្រហ្មទណ្ឌដែលមានប្រភពមកពីគោលការណ៍កាលានុវត្តភាពនៃបណ្តឹងអាជ្ញា។ ប្រសិនបើរឿងក្តីនោះមិនមាននូវធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌគ្រប់គ្រាន់ទេ នោះព្រះរាជអាជ្ញាអាចធ្វើការតំកល់រឿងទុកឥតចាត់ការបានដោយសំអាងច្បាប់ និងសំអាងហេតុព្រោះថាព្រះរាជអាជ្ញាជាអ្នកតំណាងឲ្យម្ចាស់បណ្តឹងព្រហ្មទណ្ឌតែមួយមុខប៉ុណ្ណោះ មិនអាចធ្វើបណ្តឹងនៅក្នុងរឿងអ្វីផ្សេងបានទេ[37]។ ប្រសិនបើរឿងក្តីណាមួយមិនមាននូវធាតុផ្សំទាំងបីរួមមាន ធាតុសត្យានុម័ត នីត្យានុកូល និងអត្តនោម័តនោះរឿងក្តីនោះមិនត្រូវបានចាត់ចូលជារឿងក្តីព្រហ្មទណ្ឌនោះទេ។ កាលណាបណ្តឹងមួយត្រូវបានតម្កល់ទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវតែឲ្យដំណឹងទៅដល់អ្នកប្តឹងអំពីសេចក្តីសម្រេចរបស់ខ្លួននៅក្នុរយៈពេលខ្លីបំផុត ហើយយ៉ាងយូររយៈពេល២ខែគិតពីថ្ងៃចុះពាក្យបណ្តឹង។ ចំពោះបទល្មើសដែលព្រះរាជអាជ្ញាអាចតម្កល់រឿងទុកឥតចាត់ការដោយសារព្រះរាជអាជ្ញាយល់ឃើញថាអំពើដែលបានប្តឹងឬការបរិហារនោះជាបទល្មើសព្រហ្មទណ្ឌក៏ដោយប្រសិនបើព្រះរាជអាជ្ញារកឃើញថាអំពើនោះ មិនមានការប៉ះពាល់ដល់ភាពរីករាំក្នុងសង្គមឬសណ្តាប់ធ្នាប់ធ្ងន់ធ្ងរ។ ការតម្កល់រឿងទុកឥតចាត់ការត្រូវធ្វើឡើងក្រោមមូលហេតុសំខាន់ៗដូចជា៖

- មិនអាចកំណត់ពីអត្តសញ្ញាណរបស់ចារី ឬពុំមានបន្ទុកគ្រប់គ្រាន់សំរាប់បង្ហាញពីពិរុទ្ធភាពរបស់ចារី ឬការស្រាវជ្រាវបន្ថែមរបស់មន្ត្រីនគរបាលយុត្តិធម៌មិនមានផលប្រយោជន៍នៃធាតុផ្សំផ្សេងៗ សំរាប់ធ្វើការចោទប្រកាន់បាន

---

[36] មាត្រា៣៧ នៃក្រមនិតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[37] ជំនួយស្មារតី៖ ការតម្កល់រឿងទុកឥតចាត់ការ ដោយ ផុន វណ្ណា ឆ្នាំ២០១៦

- អំពើដែលបានកើតឡើងមិនបានបង្ហាញចេញជាបទល្មើសព្រហ្មទណ្ឌ
- បទល្មើសតូចតាចដែលមិនគួរចោទប្រកាន់ និងមានព្យសនកម្មតិចតួចនិងជនរងគ្រោះមិនធ្វើការប្តឹងទៅខាងមន្ត្រីមានសមត្ថកិច្ចដូចជាបទល្មើសហឹង្សាក្នុងគ្រួសារដែលមានកម្រិតស្រាលជាដើម
- បទល្មើសព្រហ្មទណ្ឌដែលមិនអាចធ្វើការចោទប្រកាន់បាន។ ចំពោះករណីនេះផងដែរបទល្មើសដែលមិនអាចចោទប្រកាន់បានគឺសំដៅទៅលើបទល្មើសមិនមានភាពជាក់លាក់ឬមិនមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ (អនីតិជនក្រោម១៨ឆ្នាំ)
- ធាតុផ្សំនៃបទល្មើសមិនគ្រប់គ្រាន់
- បុគ្គលដែលពាក់ព័ន្ធជាជនដែលមានអភ័យឯកសិទ្ធិ
- អនិយ័តភាពនៃនីតិវិធី
- ការមិនស្គាល់អត្តសញ្ញាណរបស់ជនល្មើស
- ការចោទប្រកាន់មិនមានផ្តល់ផលប្រយោជន៍អ្វីទាំងអស់
- ការរំលត់បណ្តឹងអាជ្ញា។

### ២.៣.ការចោទប្រកាន់

នៅក្នុងបណ្តឹងព្រហ្មទណ្ឌព្រះរាជអាជ្ញាជាបុគ្គលដ៏សំខាន់នៅក្នុងការធ្វើបណ្តឹងអាជ្ញា។ ចំពោះបណ្តឹងអាជ្ញានេះទៀតសោតត្រូវបានក្រមនីតិវិធីព្រហ្មទណ្ឌកំណត់ថា ជាបណ្តឹងដែលមានគោលបំណងពិនិត្យទៅលើអត្ថិភាពនៃបទល្មើសស្វែងរកនូវពិរុទ្ធភាពរបស់ជនដែលប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌនិងផ្តន្ទាទោសជននោះដោយអនុទ្បោមទៅតាមច្បាប់ដែលបានកំណត់[38]។

លើសពីនេះទៅទៀតបណ្តឹងអាជ្ញាត្រូវបានអនុវត្តទៅលើគ្រប់បុគ្គលទាំងអស់បូករួមទាំងរូបវន្តបុគ្គល និងនីតិបុគ្គលផងដែរដោយមិនបានប្រកាន់នូវពូជសាសន៍ពណ៌សម្បុរ ភេទ សាសនា និន្នាការនយោបាយ កំណើតជាតិឋានៈសង្គម ធនធាន រឺស្ថានភាពឯទៀតឡើយ[39]។ នៅពេលដែលឈានចូលមកដល់ការអនុវត្តនូវបណ្តឹងអាជ្ញា ជនសង្ស័យដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌត្រូវតែទទួលនូវការចោទប្រកាន់ពីព្រះរាជអាជ្ញាដែលជាអ្នកតំណាងឲ្យជនរងគ្រោះ រឺគូរក្តីដើមនៅក្នុងសវនាការដោយមិនគិតអំពីស្ថានភាពនៅក្នុងសង្គមណាមួយទេ។

ក្នុងបណ្តឹងព្រហ្មទណ្ឌ ព្រះរាជអាជ្ញាជាអ្នកចាត់ចែងក្នុងការធ្វើបណ្តឹងអាជ្ញាចំពោះបទល្មើសព្រហ្មទណ្ឌដោយខ្លួនឯង រឺ តាមរយៈការកសាងសុំណុំរឿងរបស់នគរបាលយុត្តិធម៌ដែលបានមកពីកំណត់ហេតុនៃបទ

[38] មាត្រា២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[39] មាត្រា៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

ល្មើស[40]។ ព្រះរាជអាជ្ញាមានសិទ្ធិនៅក្នុងការប្តឹងបរិហារនូវបទល្មើសដោយខ្លួនឯងក៏បាន រឺមួយទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ដើម្បីធ្វើបណ្តឹងអាជ្ញាក៏បានព្រោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបានច្បាប់កំណត់ឲ្យមាននូវអំណាចក្នុងការឃាត់ខ្លួនជនល្មើសនៅកន្លែងកើតហេតុដើម្បីធ្វើយកមកធ្វើកំណត់ហេតុរួច បញ្ជូនកំណត់ហេតុនៃបទល្មើសទៅកាន់ព្រះរាជអាជ្ញា។ ក្នុងដំណាក់កាលធ្វើបណ្តឹងអាជ្ញានេះព្រះរាជអាជ្ញាមានសិទ្ធិនៅក្នុងជ្រើសរើសការចោទប្រកាន់ទៅលើជនសង្ស័យ រឺមួយតំកល់រឿងទុកឥតចាត់ការ។ គោលការណ៍នេះត្រូវបានគេហៅថាកាលានុវត្តភាពនៃការចោទប្រកាន់ ព្រោះព្រះរាជអាជ្ញាមានសិទ្ធិក្នុងការប្តឹងក៏បានមិនប្តឹងក៏បានអាស្រ័យទៅលើទំហំព្យសកម្មនៃបទល្មើស។ បើបទល្មើសតូចតាចព្រះរាជអាជ្ញាអាចឲ្យជនរងគ្រោះនិងជនដៃដល់ធ្វើការសម្រុះសម្រួលគ្នាតាមរយៈការបង់ថ្លៃការខូចខាត និងទាមទាសំណងជម្ងឺចិត្តដោយមិនចាំបាច់ធ្វើបណ្តឹងអាជ្ញាទេ។ ដោយឡែកចំពោះករណីបទល្មើសព្រហ្មទណ្ឌកម្រិតធ្ងន់ ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋមដើម្បីស្វែងរកនូវទឡ្ហីករក្នុងការចោទប្រកាន់ និងធ្វើការស្រាវជ្រាវបន្ថែមទៅលើបទល្មើសមុននឹងឈានទៅធ្វើបណ្តឹងអាជ្ញាដើម្បីឲ្យការប្តឹងមានលក្ខណៈត្រឹមត្រូវតាមគោលការណ៍ច្បាប់ព្រហ្មទណ្ឌ[41]។

មួយវិញទៀតនៅក្នុងពេលដែលមានបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវធ្វើការរាយការណ៍ដល់អគ្គព្រះរាជអាជ្ញានៃសាលាឧទ្ធរណ៍ដើម្បីឲ្យអគ្គព្រះរាជអាជ្ញារាយការណ៍បន្តទៅកាន់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បីតែងតាំងព្រះរាជអាជ្ញាណាមួយ ឲ្យទៅស្រាវជ្រាវ និងកាន់សំណុំរឿងនោះព្រោះថាបទល្មើសខ្លះត្រូវការឲ្យមាន ការស៊ើបអង្កេតជាលក្ខណៈទ្រង់ទ្រាយធំ និងងាយស្រួលក្នុងការទំនាក់ទំនងជាមួយក្រសួងពាក់ព័ន្ធព័ន្ធផងដែរ[42]។

## ២.៤.ការបើកការស៊ើបសួរ និងការបញ្ជូនរឿងក្តីទៅជំនុំជម្រះ

នៅក្នុងដំណាក់កាលស៊ើបសួរ ជាពិសេសនៅក្នុងបទឧក្រិដ្ឋព្រះរាជអាជ្ញាត្រូវធ្វើការបើកការស៊ើបសួរដើម្បីស្វែងរកនូវទិន្នន័យថ្មីៗដើម្បីធ្វើការកំណត់ និងស្រាវជ្រាវនូវទឡ្ហីករបន្ថែមដើម្បីដាក់បន្ទុកទៅលើជនត្រូវចោទ។ លើសពីនេះទៅទៀតនៅក្នុងដំណាក់កាលបើកការស៊ើបសួរ ព្រះរាជអាជ្ញាត្រូវការផ្តល់ដំណឹងទៅចៅក្រមស៊ើបសួរដើម្បីឲ្យចៅក្រមស៊ើបសួរសម្រេចការចេញដីកាអនុញ្ញាតឲ្យបើកការស៊ើបសួរ។

ការបញ្ជូនរឿងទៅជំនុំជម្រះ គឺជានីតិវិធីនៃការសម្រេចការចោទប្រកាន់របស់ព្រះរាជអាជ្ញា។ ការបញ្ជូនខ្លួនទៅជំនុំជម្រះអាចធ្វើបានតែចំពោះបទមជ្ឈិម និងបទលហុ ហើយការបញ្ជូនខ្លួនទៅជំនុំជម្រះត្រូវធ្វើតាមដីកាកោះហៅសំរាប់ឲ្យជនជាប់ចោទចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ។

---

[40] មាត្រា៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[41] មាត្រា៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជាណាចក្រកម្ពុជា

[42] មាត្រា៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

## ២.៥.នីតិវិធីនៃការបង្ហាញខ្លួន

ព្រះរាជអាជ្ញាអាចបង្គាប់ឲ្យនាំជនជាប់ចោទណាម្នាក់ចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការ តែការចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ លុះត្រាករណីមួយចំនួនដូចជា៖

- បទល្មើសជាក់ស្តែង
- ប្រភេទបទល្មើសដែលត្រូវផ្តន្ទាទោសរយៈពេល១ឆ្នាំ ហើយយ៉ាងច្រើន៥ឆ្នាំ
- ជនជាប់ចោទជានីតិជន
- រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ក្នុងការជំនុំជម្រះ

ព្រះរាជអាជ្ញាត្រូវធ្វើការប្រាប់ជនជាប់ចោទ អាចមានសិទ្ធិនៅក្នុងការជ្រើសរើសមេធាវីសំរាប់ការពារក្តី។ ប្រធានតុលាការសាលាដំបូងត្រូវទទួលបណ្តឹងតាមកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។ នៅក្នុងករណីនេះជនជាប់ចោទត្រូវបានបង្ខាំងទុកដោយកងកម្លាំងការពាររហូតដល់ សាមីខ្លួនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ។ ពេលដែលបានបង្ហាញខ្លួននៅចំពោះមុខតុលាការតុលាការត្រូវតែធ្វើការផ្ទៀងផ្ទាត់មើលអត្តសញ្ញាណរបស់ជនជាប់ចោទឲ្យបានច្បាស់លាស់។ តុលាការត្រូវរាយការណ៍ពីអង្គហេតុដែលត្រូវបានចោទប្រកាន់ហើយត្រូវប្រាប់ពីរយៈពេលបានច្បាស់សំរាប់ឲ្យសាមីខ្លួនបានត្រៀមខ្លួន។ ករណីបើតុលាការយល់ថារឿងក្តីមិនអាចធ្វើការជំនុំជម្រះបានភ្លាមៗនោះសំណុំរឿងត្រូវលើកពេលសវនាការពេលក្រោយ។ ក្នុងករណីពិសេសបើតុលាការដែលទទួលពាក្យបណ្តឹងយល់ឃើញថាលក្ខខណ្ឌនៃការបង្ហាញខ្លួន មានភាពរញ៉េរញ៉ៃឬភាពមិនច្បាស់លាស់ណាមួយត្រូវធ្វើការសិក្សាស្រាវជ្រាវបន្ថែម នោះតុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីធ្វើការស៊ើបសួរបន្ថែមតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅកាន់ចៅក្រមស៊ើបសួរ។

# ជំពូកទី៣

# នីតិវិធីជំនុំជម្រះ

# ជំពូកទី៣
# នីតិវិធីជំនុំជម្រះ

## ផ្នែកទី១៖ ចៅក្រមស៊ើបសួរ

### ១.១.ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរ ជាចៅក្រមអសនៈដែលបំពេញមុខងារជាចៅក្រមស៊ើបសួរនៅសាលាដំបូង។ ចៅក្រមអសនៈបានបែងចែកជាពីរ គឺចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ។

#### ១.១.១.ការស៊ើបសួររបស់ចៅក្រមស៊ើបសួរ

ការស៊ើបសួរត្រូវតែធ្វើការស៊ើបសួរជាសម្ងាត់ដើម្បីរក្សាសេចក្ដីថ្លៃថ្នូរ និងសិទ្ធិរបស់បុគ្គលម្នាក់ៗ។ ការស៊ើបសួររបស់ចៅក្រមស៊ើបសួរត្រូវតែធ្វើដោយខកខានពុំបានចំពោះបទល្មើសជាបទឧក្រិដ្ឋ។តែបើបទល្មើសនោះជាប្រភេទបទមជ្ឈិម ឬបទលហុការស៊ើបសួរអាចធ្វើក៏បាន ឬមិនចាំបាច់ធ្វើក៏បានដែរ[43]។ ការស៊ើបសួរត្រូវបើកការស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយដោយគ្មាន ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាបាននោះទេ។

#### ១.១.២.ដែនសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរ មានដែនសមត្ថកិច្ចអនុវត្តអំណាចរបស់ខ្លួនចំពោះរឿងក្តីបទល្មើសព្រហ្មទណ្ឌលុះត្រាតែបទល្មើសនោះកើតមានឡើងនៅក្នុងដែនដីរបស់ខ្លួន។ ករណីមួយចំនួនដែលចៅក្រមមានសមត្ថកិច្ចនៅក្នុងការចាត់ចែងបទល្មើសមានដូចជា៖

- បទល្មើសកើតមាននៅក្នុងដែនសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ
- ទីលំនៅរបស់ជនសង្ស័យស្ថិតក្នុងដែនសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ
- ចៅក្រមស៊ើបសួរស្គាល់ពីទីកន្លែងដែលជនសង្ស័យបានប្រព្រឹត្តបទល្មើស

#### ១.១.៣.ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

នៅពេលសំណុំបានធ្លាក់ទៅដល់ដៃចៅក្រមស៊ើបសួរនោះចៅក្រមស៊ើបសួរ នឹងបើកការត្រួតពិនិត្យដោយខ្លួនឯង ឬក៏ចេញដីកាចាត់ឲ្យមានការស៊ើបសួរជំនួស។ បើក្នុងករណីដែលចៅក្រមចាត់ឲ្យមានការស៊ើបសួរជំនួសនោះ ត្រូវចាត់ទៅឲ្យចៅក្រមផ្សេងទៀតដែលនៅក្នុងតុលាការជាមួយគ្នា ឬចៅក្រមនៃតុលាការផ្សេងទៀតក៏បានដែរ។

[43] មាត្រា១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

ការស្រាវជ្រាវរបស់ចៅក្រមស៊ើបត្រូវធ្វើឡើងតាមលក្ខខណ្ឌជាច្រើនដូចជា៖

- ការជូនដំណឹងដាក់ឲ្យនៅក្រោមការត្រួតពិនិត្យ
- ការសួរចម្លើយជនត្រូវចោទ
- ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ការស្តាប់ចម្លើយរបស់សាក្សី
- ការឆែកឆេរនិងការចាប់យកវត្ថុតាង
- ការធ្វើកោសល្យវិច័យ
- ការស្តាប់ទូរស័ព្ទ។

### ១.៣.១.១.ការជូនដំណឹងឲ្យដាក់នៅក្រោមការត្រួតពិនិត្យ

នៅពេលដែលចូលបង្ហាញខ្លួនលើកដំបូងចៅក្រមស៊ើបសួរត្រូវតែពិនិត្យពីអត្តសញ្ញាណជនត្រូវចោទនោះ ប្រាប់ឲ្យជនដ៏ទៃបានដឹងរឿងរ៉ាវដែលបានចោទប្រកាន់ និង ប្រាប់ពីឈ្មោះបទល្មើសដែលត្រូវបានចោទប្រកាន់។ ចៅក្រមស៊ើបសួរត្រូវប្រាប់ដល់ជនសង្ស័យ ឲ្យបានដឹងពីសិទ្ធិដែលជនសង្ស័យអាចដឹងពីសិទ្ធិរបស់ខ្លួននៅក្នុងការជ្រើសរើសមេធាវី ឬក្នុងការសុំតុលាការចាត់តាំងមេធាវីដើម្បីមកការពារខ្លួនក្នុងពេលសវនាការ។

ចំពោះជនត្រូវចោទ ជាអនីតិជននៅពេលចូលបង្ហាញខ្លួនត្រូវតែមានមេធាវីអមជានិច្ច តែបើគ្មានលទ្ធភាពក្នុងការជួលមេធាវីសំរាប់ការពារត្រូវតែធ្វើការស្នើសុំតុលាការឲ្យចាត់តាំងមេធាវីសំរាប់ការពារខ្លួន។ ពេលដែលចូលបង្ហាញខ្លួនលើកទី១ ជនត្រូវចោទត្រូវតែប្រាប់ពីទីលំនៅដែលខ្លួនបានស្នាក់នៅទៅកាន់ចៅក្រមស៊ើបសួរ។ ក្នុងករណីដែលជនត្រូវចោទមានបំណងចង់ផ្លាស់ប្តូរទីលំនៅ ត្រូវធ្វើការជូនដំណឹងទៅកាន់ចៅក្រមស៊ើបសួរជាមុនសិនជាហេតុនាំឲ្យមានការងាយស្រួលសំរាប់នីតិវិធី បន្ទាប់ពីបានផ្លាស់ទីលំនៅរួចរាំហើយត្រូវធ្វើការរាយការណ៍ដល់ចៅក្រមស៊ើបសួរពីទីលំនៅចុងក្រោយរបស់ខ្លួន។ ការផ្លាស់ប្តូរទីលំនៅរបស់ជនត្រូវចោទត្រូវតែធ្វើការកត់ចូលទៅក្នុងកំនត់ហេតុស្តីពីកំនត់ហេតុនៃការចូលបង្ហាញខ្លួនលើកដំបូង។

ក្នុងករណីពិសេសប្រសិនបើជនជាប់ចោទជាជនបរទេសហើយមិនអាចនិយាយភាសាខ្មែរបាន ចៅក្រមស៊ើបសួរត្រូវតែរកអ្នកជំនួយការក្នុងការបកប្រែ ដើម្បីមានភាពងាយស្រួលដល់ជនជាប់ចោទក្នុងការផ្តល់ចម្លើយដល់ចៅក្រមស៊ើបសួរ តែចំពោះអ្នកបកប្រែត្រូវតែធ្វើការស្បថតាមបែបសាសនា និងជំនឿរបស់ខ្លួន មុនពេលដែលបកប្រែឲ្យជនជាប់ចោទស្តាប់ហើយត្រូវនិយាយរាល់ការពិតដែលចៅក្រមស៊ើបសួរបាន សួរដល់ជនជាប់ចោទព្រមទាំងនិយាយរាល់ពាក្យពិតដែលជនជាប់ចោទបានផ្តល់ចម្លើយមកឲ្យចៅក្រមស៊ើបសួរវិញ។ ក្នុងករណីនេះអ្នកបកប្រែភាសាមិនអាចរើសចេញពី ចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ សាក្សីឬភាគីជាដើម។

### ១.១.៣.២.ការសួរចម្លើយជនត្រូវចោទ

នៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរត្រូវពិនិត្យអត្តសញ្ញាណជនត្រូវចោទហើយត្រូវប្រាប់ជនត្រូវចោទឲ្យបានដឹងពីរឿងរ៉ាវដែលត្រូវបានចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើស។ ហើយចៅក្រមស៊ើបសួរអាចប្រាប់ជនត្រូវចោទថាខ្លួនអាចឆ្លើយឬមិនឆ្លើយបានដោយសេរីប៉ុន្តែត្រូវនិរទ្ទេសស្តីអំពីការប្រាប់នេះចុះទៅក្នុងកំនត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង។ ការសួរចម្លើយជនត្រូវចោទ គឺដើម្បីទទួលបានពត៌មានពាក់ពាក់ព័ន្ធទៅនឹងបទល្មើសហើយ ជាដំណាក់កាលមួយក្នុងការបំភ្លឺឲ្យឃើញកាន់តែច្បាស់នូវអង្គហេតុណាមួយ។ មុននឹងធ្វើការសួរចម្លើយជនត្រូវចោទ ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីរបស់ជនត្រូវចោទ មកសួរចម្លើយមុនរយៈពេលយ៉ាងតិច៥ថ្ងៃមុនពេលសួរចម្លើយ។ ចៅក្រមស៊ើបសួរមិនអាចធ្វើការសួរចម្លើយជនត្រូវចោទដោយគ្មានមេធាវីការពារខ្លួនរបស់ជនត្រូវចោទនោះបានទេ។ ក្នុងករណីដែលចៅក្រមស៊ើបសួរបានកោះហៅមេធាវីការពារសិទ្ធរបស់ជនត្រូវចោទតាមពេលកំណត់ដែរ តែមេធាវីការពាររបស់ជនត្រូវចោទមិនចូលខ្លួនតាមការកំណត់នោះចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទដោយគ្មានមេធាវីការពារសិទ្ធិបាន ហើយចៅក្រមស៊ើបសួរត្រូវចុះនិរន្ទេសទៅលើកំណត់សួរចម្លើយរបស់ជនត្រូវចោទដោយ មូលហេតុអវត្តមានមេធាវីការពារសិទ្ធិជនត្រូវចោទ។ នៅក្នុងនោះមានករណីពិសេសមួយចំនួនទៀតដែលចៅក្រម អាចធ្វើការសួរចម្លើយជនត្រូវចោទបានដោយមិនចាំបាច់មានមេធាវីការពារសិទ្ធិ ដោយមូលហេតុជនត្រូវចោទបានបោះបង់ចោលនូវសិទ្ធិទទួលបានការការពារពីមេធាវី។ នៅពេលដែលសួរចម្លើយជនត្រូវចោទ មានសំណួរមួយចំនួនមិនអាចធ្វើការសួរទៅលើជនត្រូវចោទបានឡើយ ហើយចំពោះសំនួរដែលមិនត្រូវបានអនុញ្ញាតឲ្យសួរនោះត្រូវចុះនៅលើកំណត់ហេតុសួរចម្លើយ។ព្រះរាជអាជ្ញាព្រមទាំង មេធាវីក៏អាចលើកសំនួរមកសួរជនត្រូវចោទបានដែរនៅពេលដែលចៅក្រមស៊ើបសួរបានសួរចម្លើយបានចប់។

មេធាវីរបស់ជនត្រូវចោទដែលជាប់ឃុំ ក៏អាចប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្តីរបស់ខ្លួននៅក្នុងពន្ធនាគារ ឬនៅក្នុងមណ្ឌលឃុំខ្លួន។ ការសន្ទនារបស់មេធាវី និងជនត្រូវចោទមិនអាចត្រូវបានគេស្តាប់ ឬថតបាននោះទេ។ មេធាវីអាចអាលិខិតសំណុំរឿងឲ្យកូនក្តីស្តាប់បាន ប៉ុន្តែមិនអាចឲ្យលិខិតថតចម្លងពីលិខិតសំណុំរឿងដល់កូនក្តីឡើយ[44]។

[44] មាត្រា១៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

### ១.១.៣.៣.ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ដើមបណ្តឹងរដ្ឋប្បវេណី អាចជាជនរងគ្រោះឬអាចជាជនទាំងឡាយណាដែលបានទទួលរងនូវអំពើល្មើសហើយព្យសនកម្មនៃការខូចខាតមានពិតប្រាកដ ឬអាចជាអាណាព្យាបាលរបស់ជនរងគ្រោះ។ ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺដើម្បីទទួលបាននូវព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងបទល្មើស ឬអំពើនៃព្យសនកម្មផ្សេងៗដែលជាហេតុបណ្តាលមកពីការប្រព្រឹត្តបទល្មើសនិងការទាមទារសំណងការខូចខាត។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី ជាជនរងគ្រោះនៃបទល្មើស ការស្តាប់ចម្លើយពិតជាមានសារៈប្រយោជន៍ណាស់ក្នុងការស្រាវជ្រាវពីជនរងគ្រោះដែលបានជួបហេតុការផ្ទាល់ដែលខ្លួនទទួលបានការរំលោភបំពានពីសំណាក់ចារី ឬសហចារី។ ដើមបណ្តឹងរដ្ឋប្បវេណីអាចពឹងពាក់មេធាវី ដើម្បីការពារប្រយោជន៍ខ្លួនបាន។ ជាដំបូងចៅក្រមស៊ើបសួរត្រូវធ្វើការកោះហៅមេធាវីភាគីខាងដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងតិច ៥ថ្ងៃមុនពេលសួរចម្លើយដើមបណ្តឹងរដ្ឋប្បវេណីសំរាប់ពិនិត្យសំណុំរឿងឡើងវិញ។ ការសួរចម្លើយដល់ដើមបណ្តឹងត្រូវតែមានមេធាវីការពារសិទ្ធិទើបចៅក្រមស៊ើបសួរអាចសួរចម្លើយបាន ប៉ុន្តែមានករណីពិសេសប្រសិនបើមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនបានចូលបង្ហាញខ្លួនតាមដីកាកោះរបស់ចៅក្រមនោះ ចៅក្រមអាចសួរចម្លើយចំពោះដើមបណ្តឹងបានដោយគ្មានមេធាវី។ ការសួរចម្លើយដោយគ្មានមេធាវីនោះទេ ចៅក្រមស៊ើបសួរត្រូវតែចុះនិរទ្ទេសពីការអវត្តមានមេធាវីរបស់ដើមបណ្តឹងលើកំណត់ហេតុនៃការសួរចម្លើយ។

នៅពេលដែលសួរចម្លើយដើមបណ្តឹង ព្រះរាជអាជ្ញា និងមេធាវីក៏អាចសួរសំណួរបានដែរតែជាសំណួរមានការអនុញ្ញាតពីចៅក្រម។ នៅពេលដែលសួរចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវធ្វើការសួរអំពីបញ្ហាទាំងឡាយដែលជនល្មើសបានប្រព្រឹត្តទៅលើជនរងគ្រោះ។ ម្យ៉ាងវិញទៀតចៅក្រមស៊ើបសួរត្រូវសួរពីអំពើទាំងឡាយព្រមទាំងរាល់វត្ថុទាំងឡាយដែលជនល្មើសបានយកមកធ្វើជាឧបករណ៍សំរាប់ប្រព្រឹត្តបទល្មើស។ ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែឆ្លើយដោយស្មោះត្រង់រាល់សកម្មភាពទាំងឡាយដែលជនល្មើសបានប្រព្រឹត្តមកលើខ្លួនពេលដែលមានបទល្មើស។

ដើមបណ្តឹងរដ្ឋប្បវេណីត្រូវនិយាយពីគោលបំណងដែលបានខូចខាតជាព្យសនកម្មពីជនត្រូវចោទ និងនិយាយប្រាប់ពីមូលហេតុមុនពេលមានបទល្មើសកើតឡើងជាមួយជនត្រូវចោទ។ ដើមបណ្តឹងត្រូវឆ្លើយរាល់សកម្មភាពដែលជនល្មើសបានប្រព្រឹត្តចំពោះខ្លួននៅពេលដែលចៅក្រមស៊ើបសួរបានសួរចម្លើយផ្ទាល់។

### ១.១.៣.៤.ការស្តាប់ឆ្លើយសាក្សី

សាក្សី គឺជាបុគ្គលដែលបានដឹងឬបានឃើញហេតុការណ៍ណាមួយជុំវិញការប្រព្រឹត្តបទល្មើសនៅទីកន្លែងកើតហេតុ។ ចៅក្រមស៊ើបសួរត្រូវចេញបញ្ជាដាក់សំរាប់បញ្ជាឲ្យសាក្សីត្រូវតែបង្ហាញខ្លួន តាមដីកាដែល

បានកោះឲ្យចូលបំភ្លឺក្នុងនាមជាសាក្សីដែលបានឃើញព្រឹត្តការណ៍កើតឡើងស្តែងៗ ហើយនៅក្នុងបញ្ជីនោះត្រូវមាន៖

- អត្តសញ្ញាណរបស់សាក្សី
- ចុះកាលបរិច្ឆេទ ហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងមានបោះត្រា។

ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយបុគ្គលគ្រប់រូប រាល់ចម្លើយដែលមាន សារៈប្រយោជន៍នៅការសំដែងឲ្យឃើញពីការពិត។ ការសួរចម្លើយសាក្សីត្រូវតែធ្វើដាច់ពីគ្នាដោយគ្មានដើមបណ្តឹងរដ្ឋប្បវេណី និងគ្មានវត្តមានជនត្រូវចោទនៅចំពោះមុខ។

មុនពេលផ្តល់ចម្លើយសាក្សីត្រូវធ្វើការស្បថតាមរបៀបសាសនា ឬ តាមជំនឿតាមរបៀបរាងខ្លួន។ សាក្សីត្រូវតែឆ្លើយតាមសំនួរដែលចៅក្រមស៊ើបសួរបានសួរ ហើយត្រូវនិយាយតាមការពិតរាល់សកម្មភាពដែលបានឃើញនៅអំឡុងពេលមានបទល្មើសកើតមានឡើង។ ម្យ៉ាងទៀតសាក្សីត្រូវតែឆ្លើយបំភ្លឺគ្រប់ទង្វើដែលជនត្រូវចោទបានប្រព្រឹត្តបទល្មើសទៅលើជនរងគ្រោះដែលបង្កឲ្យមានព្យាសនកម្មទៅលើជនរងគ្រោះ ឬបានបំផ្លាញដល់ទ្រព្យសម្បត្តិសាធារណៈ។ ផ្ទុយទៅវិញចៅក្រមស៊ើបសួរក៏អាចសួរចម្លើយសាក្សីតទល់គ្នាជាមួយដើមបណ្តឹងរដ្ឋប្បវេណី និងជនត្រូវចោទបានផងដែរ។ បន្ទាប់ពីបានស្តាប់ចម្លើយរបស់សាក្សីរួចមក ចៅក្រមស៊ើបសួរនឹងបន្តនីតិវិធីផ្សេងៗ ទៀតសំរាប់ពន្លឿនដល់ការដាក់បន្ទុកទៅលើជនត្រូវចោទបន្ថែម។

### ១.១.៣.៥.ការឆែកឆេរ និងការចាប់យកវត្ថុតាង

មុននឹងចុះទៅកន្លែងដែលមានបទល្មើសកើតមានត្រូវ ឆែកឆេរនោះចៅក្រមស៊ើបសួរត្រូវតែធ្វើកំណត់ហេតុមួយស្តីពីការចុះឆែកឆេរ ដោយមានចុះហត្ថលេខាដោយចៅក្រមស៊ើបសួរនិងក្រឡាបញ្ជី។ ចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរ និងចាប់យកវត្ថុដែលជាវត្ថុតាងបាននៅកន្លែងដែលកើតមានបទល្មើសជាក់ស្តែង។ ចំពោះកន្លែងដែលមានបទល្មើសកើតឡើង ត្រូវបិទមិនអនុញ្ញាតឲ្យជនសាមញ្ញចេញចូលតាមអំពើចិត្តនោះទេ ត្រូវមានអ្នកកាន់កាប់ទីកន្លែង តែករណីដែលគ្មានអ្នកកាន់កាប់ទីកន្លែងទេត្រូវធ្វើការឆែកឆេរនៅចំពោះមុខសាក្សី២រូប ប៉ុន្តែត្រូវចុះនិរទ្ទេសពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗឲ្យបានច្បាស់លាស់នៅលើកំណត់ហេតុស្តីពីការឆែកឆេរ។

នៅក្នុងដំណាក់កាលឆែកឆេរ សាក្សីមិនអាចជាមន្ត្រីនគរបាល ឬកងរាជអាវុធហត្ថបាននោះទេ។ ការឆែកឆេរមិនអាចធ្វើមុនម៉ោង៦ព្រឹក និងក្រោយម៉ោង១៨ល្ងាចបាននោះទេ។ តែករណីដែលជនត្រូវចោទជាមេធាវី ហើយការឆែកឆេរត្រូវនៅកន្លែងមេធាវី ត្រូវធ្វើនៅចំពោះមុខ ប្រធានគណៈមេធាវី ឬ មុខបណ្តាប្រតិភូរបស់គណៈមេធាវី បន្ទាប់មកត្រូវចុះពីវត្តមានរបស់ប្រធានគណៈមេធាវី ឬប្រតិភូរបស់គណៈមេធាវីនៅលើកំនត់ហេតុ។

ការឆែកឆេរត្រូវតែធ្វើឲ្យគ្រប់ទីកន្លែងដែលជនត្រូវចោទបានយកធ្វើជាកន្លែងប្រព្រឹត្តបទល្មើស ឬយកធ្វើជាកន្លែងសំរាប់លាក់ឧបករណ៍ដែលបានប្រព្រឹត្តបទល្មើស។ កន្លែងដែលត្រូវឆែកឆេរអាចជាលំនៅដ្ឋាន ទីកន្លែងធ្វើការ ទីកន្លែងលាក់ខ្លួនរបស់ជនត្រូវចោទជាដើម។ ឧបករណ៍មួយចំនួនដែលជនត្រូវចោទយកធ្វើជាឧបករណ៍នៅក្នុងការប្រព្រឹត្តបទល្មើស ពេលចៅក្រមស៊ើបសួររកឃើញនៅពេលដែលចុះទៅឆែកឆេរ ចៅក្រមស៊ើបសួរអាចចាប់យកជាវត្ថុតាង និងបោះត្រាលើវត្ថុតាងសំរាប់ធ្វើជាកំនត់ហេតុ ព្រមទាំងត្រូវបង្ហាញវត្ថុដែលចាប់បានដល់អ្នកកាន់កាប់ទីកន្លែង។ បន្ទាប់មកយើងត្រូវធ្វើកំណត់ហេតុមួយទៀតស្តីពីការចាប់បានវត្ថុតាង ហើយត្រូវចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីព្រមទាំងអ្នកដែលបានកាន់កាប់ទីកន្លែង។

### ១.១.៣.៦.ការធ្វើកោសល្យវិច័យ

ភាពចាំបាច់នៃការធ្វើកោសល្យវិច័យ សំរាប់ធ្វើឲ្យយើងរកឃើញឬឲ្យយើងអាចប្រើប្រាស់សញ្ញាសម្គាល់មួយចំនួន ឬភស្តុតាងផ្សេងៗដោយមធ្យោបាយបច្ចេកទេស និងវិទ្យាសាស្ត្រមួយចំនួន។ ក្នុងដំណាក់កាលនៃការស៊ើបសួរ ដើម្បីជាប្រយោជន៍នៅក្នុងស្វែងរកការពិត ច្បាប់បានអនុញ្ញាតឲ្យចៅក្រមស៊ើបសួរបញ្ជាឲ្យមន្ត្រីជំនាញធ្វើកោសល្យវិច័យសំរាប់បង្ហាញពីការពិតនៃបទល្មើសណាមួយ។ ក្នុងពេលដែលមានបញ្ហាបច្ចេកទេសណាមួយចៅក្រមស៊ើបសួរអាចបង្គាប់មន្ត្រីជំនាញឲ្យ ធ្វើកោសល្យវិច័យម្តងទៀត។ ចំពោះការធ្វើកោសល្យវិច័យធ្វើឡើងដោយឆន្ទៈមួយចំនួនដូចជា៖

- ចៅក្រមស៊ើបសួរបង្គាប់ឲ្យធ្វើកោសល្យវិច័យដោយឯកឯង
- តាមពាក្យសុំរបស់ព្រះរាជអាជ្ញា
- តាមពាក្យសុំរបស់ជនត្រូវចោទ
- តាមពាក្រសុំរបស់ដើមបណ្តឹង

ហើយចៅក្រមស៊ើបសួរត្រូវចេញដីកាចាត់តាំងអ្នកជំនាញបញ្ជាក់ពីបេសសកម្មរបស់ អ្នកជំនាញ និងរយៈពេលនៃការបំពេញបេសសកម្មតែអ្នកជំនាញក្នុងការធ្វើកោសល្យវិច័យ[45]។

ករណីដែលត្រូវប្រគល់វត្ថុទៅឲ្យក្រុមជំនាញធ្វើកោសល្យវិច័យ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការចាប់បានវត្ថុប្រគល់ទៅឲ្យក្រុមជំនាញសំរាប់បើកការធ្វើកោសល្យវិច័យ។ មុនការបំពេញបេសសកម្មរបស់ខ្លួនក្រុមជំនាញត្រូវតែធ្វើការស្តាប់ចម្លើយគ្រប់បុគ្គលទាំងអស់ដែលបានពាក់ព័ន្ធនឹងបទល្មើស ប៉ុន្តែមិនចាំបាច់នៅក្នុងការស្តាប់ចម្លើយរបស់ជនត្រូវចោទ បើមានករណីពិសេសណាមួយដែលក្រុមជំនាញបានស្តាប់ចម្លើយពី

45 មាត្រា១៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

បុគ្គលទាំងអស់នោះមិនបានច្បាស់ ក្រុមជំនាញអាចស្តាប់ចម្លើយរបស់ភាគីជនត្រូវចោទបានដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ បន្ទាប់ពីទទួលបាន ការរាយការណ៍របស់ក្រុមជំនាញចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា រួចកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ជនត្រូវចោទ មេធាវីដើម្បីប្រាប់ពីការសន្និដ្ឋាននៃការធ្វើកោសល្យវិច័យ។ ប្រសិនបើភាគីទាំងអស់មិនពេញចិត្តក្រោយពីបានដឹងពីការសន្និដ្ឋាននៃការធ្វើកោសល្យវិច័យក្នុងរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរ តែរយៈពេលនេះមិនតិចជាង១០ថ្ងៃនោះទេ។

តែបើករណីនេះមិនមានការស្នើសុំនេះចៅក្រមស៊ើបសួរត្រូវតែចេញដីកាសំអាងហេតុ ក្នុងរយៈពេល៥ថ្ងៃបើពាក្យសុំចេញពីព្រះរាជអាជ្ញា និងរយៈពេល១ខែប្រសិនបើពាក្យសុំនោះចេញពីជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី[46]។ ក្រោយពីបំពេញបេសសកម្មចប់ អ្នកជំនាញត្រូវធ្វើការរាយការណ៍ពីភស្តុតាងដែលបានមកពីការធ្វើកោសល្យវិច័យជូនចៅក្រមស៊ើបសួរ[47]។

### ១.១.៣.៧.ការស្តាប់ទូរស័ព្ទ

ការស្តាប់ទូរស័ព្ទ ជាអាទិ៍ដែលបង្គាប់ដោយចៅក្រមស៊ើបសួរត្រូវធ្វើឡើងដើម្បីតម្រូវចាំបាច់ក្នុងការសំដែងឲ្យឃើញនូវការពិត ឬជាប្រយោជន៍ចំពោះបទល្មើសទាំងឡាយណាដែលមានការពាក់ព័ន្ធនឹងបណ្តាញទូរស័ព្ទដែលចៅក្រមស៊ើបសួរបង្គាប់ឲ្យស្តាប់ព្រមទាំងថតការសន្ទនាតាមទូរស័ព្ទបាន។ ឧទាហរណ៍៖ករណីស៊ើបអង្កេតពីបទល្មើសគម្រាមនិងសម្លាប់ដែលជនរងគ្រោះបានអះអាងថាជនត្រូវចោទបានទូរស័ព្ទមកគម្រាមជនរងគ្រោះជាច្រើនលើកច្រើនសារ។ ចំពោះបញ្ហានេះចៅក្រមស៊ើបសួរអាចបង្គាប់បញ្ជាឲ្យមន្ត្រីដែលមានជំនាញថតរាល់សកម្មដែលជនទាំងពីរបានសន្ទនាគ្នាសំរាប់ទុកជាភស្តុតាង។

នៅក្នុងករណីពិសេស ប្រសិនបើចៅក្រមស៊ើបសួររកអស់គ្រប់មធ្យោបាយគ្រប់បែបយ៉ាងហើយតែមិនអាចតាមចាប់ជនត្រូវចោទសំរាប់យកមកសួរចម្លើយបាននោះទេ ចំពោះបញ្ហានេះប្រសិនបើចៅក្រមស៊ើបសួរមានលេខទំនាក់ទំនងជនត្រូវចោទចៅក្រមស៊ើបសួរអាចធ្វើការទាក់ទងទៅជនជាប់ចោទសំរាប់ផ្តល់ជាចម្លើយ ដល់ចៅក្រមបានដើម្បីឲ្យជននោះផ្តល់ចម្លើយតាមប្រព័ន្ធអេឡិចត្រូនិច។ ការស្រាវជ្រាវចៅក្រមស៊ើបសួរអាចធ្វើការស្តាប់ចម្លើយពីជនដែលពាក់ព័ន្ធតាមរយៈទូរស័ព្ទបាន។ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យចាប់ជនត្រូវចោទ និងថតគ្រប់សកម្មភាពឆ្លើយឆ្លងគ្នាតាមមធ្យោបាយមួយចំនួនដូចជា សារតាមអ៊ីនធើណេត សារជាសម្លេងតាមទូរស័ព្ទជាដើម។ ការស្តាប់ទូរស័ព្ទជាកត្តាមួយដែលជំរុញការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ឲ្យកាន់តែទៅមុខបានឆាប់

[46] មាត្រា១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[47] មាត្រា១៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

រហ័ស ចៅក្រមស៊ើបសួរអាចសុំឲ្យគ្រប់អង្គភាពដែលពាក់ព័ន្ធឬគ្រប់មន្ត្រីរាជការជំនាញតាំងឧបករណ៍បច្ចេកទេស សំរាប់ថតរាល់សកម្មភាពដែលបានទំនាក់ទំនងរវាងជនទាំងអស់នោះធ្វើជាភស្តុតាង សំរាប់ក្នុងការស្វែងរកជនត្រូវចោទ។

គ្រប់អង្គភាពសាធារណៈ មន្ត្រីរាជការដែលបានចាត់តាំងត្រូវបំពេញតាមពាក្យសុំរបស់ចៅក្រមស៊ើបសួរ នៅពេលអនុវត្តបេសកកម្មរបស់ខ្លួនត្រូវធ្វើការរាយការណ៍ជូនចៅក្រមស៊ើបសួររាល់សកម្មភាព ឬ ការជួបបញ្ហាលំបាករបស់ខ្លួននៅក្នុងពេលបំបេញបេសសកម្មរបស់ខ្លួន។ ចំពោះបេសសកម្មដែលបានបំពេញរួចហើយត្រូវធ្វើការចម្លងជាលាយលក្ខណ៍អក្សរនូវគ្រប់សម្លេងដែលបានថតបាន។ កាលណាបេសកកម្មត្រូវបានបំពេញចប់ហើយ អង្គភាពសារណៈ ឬមន្ត្រីរាជការដែលមានជំនាញត្រូវចម្លងរាល់សម្លេងដែលថតបានជាលាយលក្ខណ៍អក្សរហើយសម្លេងដែលថតបានត្រូវប្រគល់ជូនទៅកាន់ចៅក្រមស៊ើបសួរព្រមទាំងបិទស្លាកសម្គាល់ផងដែរ។

### **១.១.៤.ការចាត់ឲ្យស៊ើបសួរជំនួស**

នៅក្នុងករណីដែលបន្ទាន់ណាមួយ ចៅក្រមស៊ើបសួរបានកាន់សំណុំរឿងនៃបទល្មើសនោះមិនអាចចុះទៅធ្វើការស៊ើបសួរបានដោយមាន ភារកិច្ចផ្សេងដែលសំខាន់ជាងរឿងក្តីមួយនេះត្រូវដោះស្រាយនោះចៅក្រមដែលបានកាន់សំណុំរឿងមួយនេះត្រូវប្រគល់សិទ្ធិការស៊ើបសួរ ឲ្យចៅក្រមផ្សេងនៃតុលាការរបស់ខ្លួន ឬតុលាការផ្សេងទៀត មន្ត្រីនគរបាលយុតិធម៌ឬជាភ្នាក់ងារនគរបាលយុត្តិធម៌បំពេញកិច្ចស៊ើបសួរជំនួសខ្លួន។

ចៅក្រមស៊ើបសួរត្រូវពិនិត្យ ណែនាំឲ្យបានច្បាស់លាស់លើដីកាស៊ើបសួរដល់ចៅក្រមដែលបានសិទ្ធិគ្រប់គ្រងជំនួស។ ចៅក្រមស៊ើបសួរត្រូវតែកំណត់ពីថិរវេលានៃកិច្ចស៊ើបសួរឲ្យបានច្បាស់លាស់ដែលត្រូវអនុវត្តដីកាឲ្យមានការស៊ើបសួរជំនួស។ ចៅក្រមស៊ើបសួរត្រូវតែ៖

- ចុះកាលបរិច្ឆេទ
- ចុះហត្ថលេខា បោះត្រាលើដីកាស៊ើបសួរជំនួសនៅពេលដែលត្រូវប្រគល់សិទ្ធិឲ្យចៅក្រមផ្សេង។

ចៅក្រមស៊ើបសួរបានប្រគល់សិទ្ធឲ្យចៅក្រមណាម្នាក់ទទួលសិទ្ធស៊ើបសួរជំនួសហើយចៅក្រមស៊ើបសួរក៏អាចមានសិទ្ធ ដកហូតអំណាចពីចៅក្រមស៊ើបសួរជំនួសនោះមកវិញផងដែរ។ កាលណាដែលដីកាចាត់ឲ្យស៊ើបសួរជំនួសត្រូវបានចេញឲ្យចៅក្រមណាម្នាក់ នោះចៅក្រមនោះត្រូវប្រើសិទ្ធអំណាចទាំងអស់របស់ចៅក្រមស៊ើបសួរ សំរាប់ធ្វើនីតិវិធីនៃការស៊ើបសួរទៅលើអង្គហេតុនោះ។

ការស៊ើបសួរជំនួស ត្រូវតែមានថិរវេលាមួយយ៉ាងពិតប្រាកដសំរាប់ការស៊ើបសួរឲ្យចប់អង្គហេតុនោះ ហើយមិនត្រូវធ្វើការអូសបន្លាយពេលវេលានោះទេ។ នៅពេលដែលដីកាស៊ើបសួរជំនួសបានប្រគល់ទៅឲ្យមន្ត្រីនគរបាលយុត្តិធម៌នោះហើយមន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិត្រឹមតែត្រួតពិនិត្យតែប៉ុណ្ណោះ។

តែករណីមួយចំនួនចៅក្រមស៊ើបសួរមិនអាចប្រគល់ភារកិច្ច ទៅឲ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើតែឯងបាននោះទេដូចជា៖

- ការសួរចម្លើយជនត្រូវចោទ
- ការស្តាប់ចម្លើយភាគីដើមបណ្តឹងរដ្ឋប្បវេណីការឆែកឆេរក្នុងការិយាល័យមេធាវី ឬក្នុងសហគ្រាសសារព័ត៌មានជាដើម។ ចៅក្រមស៊ើបសួរបានប្រគល់ភារកិច្ចឲ្យមន្ត្រីនគរបានលយុត្តិធមស៊ើបសួរជនួសតែពាក់កណ្តាលតែប៉ុណ្ណោះ។

ចំពោះដីកាស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ ហើយត្រូវរាយការណ៍ ជូនចៅក្រមស៊ើបសួរគ្រប់សកម្មភាពដែលខ្លួនបានធ្វើកិច្ចស៊ើបសួរតាំងពីបើកការស៊ើបសួររហូតដល់ពេលដែលបិទការស៊ើបសួរ។

### ១.២.វិធាននិរន្តរាយ

ក្នុងវិធាននិរន្តរាយ ចៅក្រមស៊ើបសួរមានសិទ្ធិចេញដីកាទៅលើជនត្រូវចោទដោយឈរលើមូលដ្ឋាននៃការបង្គាប់ទៅលើជនត្រូវចោទប្រកាន់។ បន្ថែមម៉្យាងទៀតអាចបង្គាប់បញ្ជាឲ្យមន្ត្រីនគរបាលយុត្តិធម៌កងកម្លាំងសាធារណៈសំរាប់ជាជំនួយក្នុងការចាត់វិធានការចាំបាច់ទៅលើជនត្រូវចោទដូចជា ការនាំខ្លួនជនត្រូវចោទដើម្បីបញ្ជូនទៅចំពោះមុខតុលាការសំរាប់នីតិវិធីជំនុំជម្រះ។

#### ១.២.១.ដីកា

ដីកា ជាសេចក្តីសម្រេចដែលចៅក្រមស៊ើបសួរចេញសំរាប់បញ្ជាដល់ភាគីដែលពាក់ព័ន្ធចូលខ្លួននៅចំពោះមុខតុលាការ។ ចៅក្រមស៊ើបសួរអាចមានសិទ្ធិចេញដីកាចំនួនបីប្រភេទដូចជា៖

- ដីកាបង្គាប់ឲ្យចូលខ្លួន
- ដីកាបង្គាប់ឲ្យនាំខ្លួន
- ដីកាបង្គាប់ឲ្យចាប់ខ្លួន[48]។

ចំពោះដីកាទាំងអស់នេះចៅក្រមស៊ើបសួរចេញទៅតាមស្ថានភាពរបស់ជនត្រូវចោទ មានលក្ខណៈដាច់ដោយឡែកពីគ្នា។

[48] មាត្រា១៨៥នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

### ២.១.១.ដីកាបង្គាប់ឲ្យចូលខ្លួន

ដីកាបង្គាប់ឲ្យចូលខ្លួន ជាការបញ្ជារបស់ចៅក្រមស៊ើបសួរឲ្យបុគ្គលណាម្នាក់ដែលជាចារីឬជាសហចារីឲ្យចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ មានតែចៅក្រមស៊ើបសួរតែប៉ុណ្ណោះដែលមានសមត្ថកិច្ចចេញដីកាបង្គាប់ឲ្យចូលខ្លួនបាន។ ដីកាបង្គាប់ឲ្យចូលខ្លួន អាចចេញទៅលើជនត្រូវចោទឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព[49]។

ដីកាបង្គាប់ឲ្យចូលខ្លួន ជាដំណាក់កាលមួយសំរាប់ឲ្យជនសង្ស័យចូលបង្ហាញខ្លួនមុនពេលបើកសវនាការ។ ប្រសិនបើជនសង្ស័យមិនបានចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរនៅដំណាក់កាលដំបូងនេះទេ ចៅក្រមស៊ើបសួរនឹងចេញដីកាបង្គាប់ឲ្យនាំខ្លួនជនសង្ស័យ។ មន្ត្រីនគរបាលយុត្តិធម៌ឬភ្នាក់ងារនគរបាលយុត្តិធម៌ ឬអាជ្ញាសាលាត្រូវបញ្ជូនដីកាបង្គាប់ឲ្យចូលខ្លួនធ្វើជាសេចក្តីជូនដំណឹងដល់បុគ្គលដែលបានពាក់ព័ន្ធ ជាមួយនឹងបទល្មើស[50]។

នៅក្នុងដីកាបង្គាប់ឲ្យចូលខ្លួន ត្រូវមាននិរទ្ទេសដូចជា៖

- អត្តសញ្ញាណជនដែលបានពាក់ព័ន្ធ
- បទល្មើសដែលត្រូវធ្វើការចោទប្រកាន់
- អត្ថបទច្បាប់បានកំណត់ការបង្ក្រាបបទល្មើស
- ថ្ងៃ ខែ ឆ្នាំ ម៉ោង ទីកន្លែងដែលត្រូវចូលបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា[51]។

### ១.២.១.២.ដីកាបង្គាប់ឲ្យនាំខ្លួន

ដីកាបង្គាប់ឲ្យនាំខ្លួន ជាការបញ្ជាដល់កងកម្លាំងសាធារណៈឲ្យធ្វើការចាប់ខ្លួន និងនាំខ្លួនបុគ្គលដែលជាចារីចូលខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកាបង្គាប់ឲ្យនាំខ្លួន ត្រូវបានចេញចំពោះជនត្រូវចោទឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព[52]។ មានន័យថាការចេញដីកានេះ គឺចាំបាច់ដើម្បីបង្ខំឲ្យជនត្រូវចោទ ឬជនដែលមានតម្រុយពិរុទ្ធភាពឲ្យចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួ រដោយតាមរយៈការប្រើប្រាស់កងកម្លាំង

[49] មាត្រា១៨៦នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[50] មាត្រា១៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[51] មាត្រា១៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
[52] មាត្រា១៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

សាធារណៈឲ្យចាប់និងនាំយកបុគ្គលនោះមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ មន្ត្រីនគរបាលយុត្តិធម៌ជាអ្នកអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន។

ចំពោះដីកាបង្គាប់ឲ្យនាំខ្លួននេះ ត្រូវធ្វើការផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយសំរាប់តាមស្វែងរកជនត្រូវចោទមកអនុវត្តអំពើទោសកំហុសរបស់ខ្លួន ដើម្បីយកមកផ្តន្ទាទោសតាមផ្លូវច្បាប់។ ចំពោះដីកានេះត្រូវធ្វើការប្រគល់ជូនទៅជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកអនុវត្តដីកាឲ្យបានដឹងមុនដើម្បីងាយស្រួលក្នុងធ្វើការស្វែងរកជនត្រូវចោទ។

មន្ត្រីនគរបាលយុត្តិធម៌ មិនត្រូវចូលក្នុងលំនៅដ្ឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង៦ព្រឹក និងក្រោយម៉ោង៦ល្ងាចបាននោះទេ។ ប្រសិនបើមន្ត្រីដែលបានអនុវត្តដីកាមានបញ្ហាលំបាកនៅក្នុងការបំពេញបេសកកម្មរបស់ខ្លួនត្រូវធ្វើការជូនដំណឹងទៅឲ្យចៅក្រមស៊ើបសួរ[53]។

### ១.២.១.៣.ដីកាបង្គាប់ឲ្យចាប់ខ្លួន

ដីកាបង្គាប់ឲ្យចាប់ខ្លួនជាការបញ្ជា ដល់កងកម្លាំងសាធារណៈឲ្យធ្វើការស្រាវជ្រាវរកចាប់និងនាំខ្លួនជនសង្ស័យទៅដាក់ពន្ធនាគារឬយកទៅឃុំខ្លួន។ ដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវបានចេញដោយចៅក្រមស៊ើបសួរហើយដីកានេះចេញចំពោះជនជាប់ចោទ ឬបុគ្គលណាដែលត្រូវបានរកឃើញតម្រុយពីពិរុទ្ធភាពនៃបុគ្គលនោះ។

ចៅក្រមស៊ើបសួរអាចចេញ ដីកាចាប់ខ្លួនបានទាល់តែបទល្មើសដែលបានចោទប្រកាន់ជាបទឧក្រិដ្ឋ បទមជ្ឈិមដែលត្រូវដាក់ពន្ធនាគារបុគ្គលដែលពាក់ព័ន្ធបានគេចខ្លួនមិនដឹងថាស្ថិតនៅទីកន្លែងណាឬស្ថិតនៅក្រៅដែនដីព្រះរាជាណាចក្រកម្ពុជា[54]។ មុនពេលដែលចៅក្រមស៊ើបសួរអាចធ្វើការសម្រេចចិត្តចេញដីកាបង្គប់ឲ្យចាប់ខ្លួន លុះត្រាតែមានការយល់ព្រមពីយោបល់នោះពីព្រះរាជអាជ្ញាផងដែរប៉ុន្តែក្នុងករណីដែលមិនមានការយល់ព្រមពីព្រះរាជអាជ្ញានោះចៅក្រមស៊ើបសួមិនអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនសង្ស័យបាននោះទេ។ ម្យ៉ាងវិញទៀតដីកាបង្គាប់ឲ្យចាប់ខ្លួនធ្វើឡើងដោយមានការនិរន្ទេស កាលបរិច្ឆេទ ព្រមទាំងចុះហត្ថលេខានិងបោះត្រាដោយចៅក្រមស៊ើបសួរ សំរាប់បញ្ជាឲ្យកងកម្លាំងសាធារណៈស្វែងរកជនត្រូវចោទ ឬជនដែលជាប់ពាក់ព័ន្ធ ឬជនដែលមានពិរុទ្ធភាពមកចំពោះមុខចៅក្រមស៊ើបសួរដើម្បីធ្វើការសាកសួរយកចម្លើយ ឬស្តាប់ចម្លើយពាក់ព័ន្ធនឹងការចោទប្រកាន់របស់ព្រះរាជអាជ្ញា។

[53] មាត្រា១៩២ នៃក្រមនីតិវិធីព្រហទណ្ឌព្រះរាជណាចក្រកម្ពុជា

[54] មាត្រា១៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

## ១.៣.ការឃុំខ្លួនបណ្តោះអាសន្ន

ជាទូទៅ ជនត្រូវចោទពុំអាចត្រូវបានឃុំខ្លួនជាបណ្ដោះអាសន្ននោះទេប្រសិនបើចៅក្រមស៊ើបសួរមិនទាន់រកឃើញពីពិរុទ្ធភាព។ តែទោះជាយ៉ាងណាចៅក្រមស៊ើបសួរ អាចចេញដីកាសំរាប់ឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្ននៅមុននីតិវិធីជំនុំជម្រះបាន។

ការឃុំខ្លួនបណ្ដោះអាសន្ន អាចធ្វើការអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលច្បាប់បានចែងដាក់ពន្ធនាគារស្មើឬលើស១ឆ្នាំតែប៉ុណ្ណោះ។ តែករណីបើជនត្រូវចោទត្រូវបានចាប់ខ្លួននិងផ្អែកទៅលើដីកាបញ្ជូនខ្លួននោះថិរវេលានៃការឃុំខ្លួនគិតចាប់ពីកាលបរិច្ឆេទនៃការចាប់ខ្លួន ហើយត្រូវគិតបញ្ចូលក្នុងថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន។

### ១.៣.១.មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន

មានមូលហេតុមួយចំនួនដែលនាំឲ្យមានការឃុំខ្លួនបណ្ដោះអាសន្នដូចជា៖

- សំរាប់បញ្ឈប់បទល្មើសដែលបានកើតមាន ឬកុំឲ្យមានបទល្មើសកើតឡើងសារជាថ្មីម្តងហើយម្តងទៀត
- ដើម្បីទប់ស្កាត់កុំឲ្យមានបទល្មើសនេះកើតមានចំពោះជនរងគ្រោះម្តងហើយម្តងទៀត
- ដើម្បីកុំឲ្យមានការត្រូវរូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចង់បំផ្លាញភស្តុតាងឬចង់រត់គេចខ្លួនពីការទទួលខុសត្រូវ
- ងាយស្រួលក្នុងការស៊ើបសួរ
- កុំឲ្យមានការគំរាមកំហែងដល់បុគ្គលដែលបានពាក់ព័ន្ធនៅកន្លែងកើតមានបទល្មើស
- រារាំងកុំឲ្យមានការប្រើប្រាស់លុយ ដើម្បីលុបបំបាត់ភស្តុតាងនៅអំឡុងពេលមានបទល្មើស
- ជៀសវាងកុំឲ្យមានការបំផ្លាញទ្រព្យសម្បត្តិប្រជាពលរដ្ឋ
- ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់ចំពោះជនរងគ្រោះ ឬសាក្សីកុំឲ្យនិយាយការពិតដែលសាក្សីនៅកន្លែងកើតហេតុបានឃើញ
- ដើម្បីរក្សាភស្តុតាង និងតម្រុយជាសម្ភារៈ ទុកសំរាប់ធ្វើជាភស្តុតាងនៅក្នុងការដាក់ពាក្យបណ្តឹង
- សំរាប់ធ្វើការការពារសុវត្ថិភាពជូនជនត្រូវចោទ កុំមានអំពើហិង្សាកើតមានពីប្រជាពលរដ្ឋ
- ដើម្បីរក្សាសណ្តាប់ធ្នាប់ជូនសាធារណៈ កុំឲ្យមានភាពចលាចលដែលបង្កឡើងដោយជនត្រូវចោទដោយប្រការណាមួយ។

### ១.៣.២.ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវកំណត់ទៅតាមអាយុរបស់ជនត្រូវចោទ និងអាស្រ័យថាបទល្មើសនោះពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិម។ ការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងតែចំពោះបទល្មើសជាប្រភេទបទល្មើសជាក់ស្ដែងតែប៉ុណ្ណោះ។

### ១.៣.២.១.ថិរវេលានៃការឃុំបណ្តោះអាសន្នចំពោះអនីតិជន

ចំពោះនីតិជនដែលមានអាយុតិចជាង១៤ឆ្នាំ មិនអាចត្រូវបានដាក់ឃុំខ្លួនជាបណ្ដោះអាសន្ននោះទេ ទោះបីបានប្រព្រឹត្តបទល្មើសអ្វីក៏ដោយ។ ចៅក្រមស៊ើបសួរត្រូវប្រគល់អនីតិជននោះទៅឪពុកម្ដាយឬអាណាព្យាបាល តែករណីបើអនីតិជនរូបនោះពុំមានឪពុកម្ដាយ ឬអាណាព្យាបាលត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្ដោះអាសន្នសិនសំរាប់ថែរក្សាកុំឲ្យមានការបំពានពីមជ្ឈដ្ឋានជុំវិញខ្លួន ទុករងចាំសេចក្ដីសម្រេចរបស់តុលាការ។

ចំពោះបទល្មើសជាបទមជ្ឈិម អនីតិជនដែលមានអាយុចាប់១៤ឆ្នាំ ដល់១៦ឆ្នាំ មិនអាចឃុំខ្លួនឲ្យលើស ២ខែនោះទេ។ ចំណែកឯអនីតិជនដែលមានអាយុចាប់ពី១៦ឆ្នាំដល់ក្រោម១៨ឆ្នាំត្រូវធ្វើការឃុំខ្លួនមិនឲ្យលើសពី ៤ខែនោះទេ។ ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះអនីតិជនមិនអាចធ្វើការឃុំខ្លួនលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សំរាប់អនីតិជននោះទេ។

ចំពោះបទល្មើសជាបទឧក្រិដ្ឋ អនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំដល់ក្រោម១៦ឆ្នាំ មិនអាចឃុំខ្លួនឲ្យលើសពី៤ខែនោះទេ។ តែសំរាប់អនីតិជនដែលមានអាយុចាប់ពី១៦ឆ្នាំដល់ក្រោម១៨ឆ្នាំមិនអាចឃុំខ្លួនឲ្យលើសពី៦ខែបាននោះ។

| ប្រភេទនៃបទល្មើស | អាយុ | រយៈពេលនៃការឃុំខ្លួន |
|---|---|---|
| បទមជ្ឈិម | ១៤ឆ្នាំដល់១៦ឆ្នាំ | មិនឲ្យលើស២ខែ |
| បទមជ្ឈិម | ១៦ឆ្នាំដល់១៨ឆ្នាំ | មិនឲ្យលើស៤ខែ |
| បទឧក្រិដ្ឋ | ១៤ឆ្នាំដល់១៦ឆ្នាំ | មិនឲ្យលើស៤ខែ |
| បទឧក្រិដ្ឋ | ១៦ឆ្នាំដល់១៨ឆ្នាំ | មិនឲ្យលើស៦ខែ |

### ១.៣.២.២.ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះនីតិជន

បទមជ្ឈិមដែលបានប្រព្រឹត្តដោយនីតិជន ការឃុំខ្លួនបណ្ដោះអាសន្នមិនឲ្យលើសពី៤ខែបានទេ។ នៅពេលដែលផុតចិរវេលានៃការឃុំខ្លួន ចៅក្រមស៊ើបសួរអាចពន្យាពេលនៃការឃុំខ្លួននេះបានម្ដងទៀតប៉ុន្តែការពន្យាពេលនៃការឃុំខ្លួននេះបានរយៈពេលតែ២ខែប៉ុណ្ណោះដោយ មានដីកាសំអាងហេតុត្រឹមត្រូវហើយច្បាស់លាស់។

ការឃុំខ្លួនបណ្ដោះអាសន្នចំពោះបទមជ្ឈិម មិនត្រូវឲ្យលើសពីពាក់កណ្ដាលនៃបរមានៃទោសដែលច្បាប់បានកំណត់នោះទេ។

នីតិជនដែលបានចោទប្រកាន់បទល្មើសជាបទឧក្រិដ្ឋ ការឃុំបណ្ដោះអាសន្នសំរាប់នីតិជនមិនអាចឃុំខ្លួនឲ្យលើសពី៦ខែនោះទេ។ នៅពេលដែលផុតថរិវេលានៃការឃុំខ្លួននេះចៅក្រមស៊ើបសួរអាចពន្យាពេលការឃុំខ្លួនបណ្ដោះអាសន្នម្ដងទៀតបានរយៈពេល៦ខែ ដោយមានសំអាងហេតុត្រឹមត្រូវហើយច្បាស់លាស់ផងដែរ។ ចៅក្រមស៊ើបសួរមិនអាចពន្យាពេលនៃការឃុំខ្លួនចំពោះនីតិជនឲ្យលើស២ដងបាននោះទេ។

| ប្រភេទនៃបទល្មើស | រយៈពេលនៃការឃុំខ្លួន | រយៈពេលពន្យាការឃុំខ្លួន |
|---|---|---|
| បទមជ្ឈិម | មិនឲ្យលើស៤ខែ | ២ខែ |
| បទឧក្រិដ្ឋ | មិនឲ្យលើស៦ខែ | ៦ខែ |

### ១.៣.៣.ការពន្យាពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន

នៅពេលដែលចៅក្រមស៊ើបសួរសម្រេចថាពន្យាពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរត្រូវឲ្យដំណឹងទៅកាន់ជនដែលត្រូវចោទ។ កាលណាដែលជនត្រូវចោទមានមេធាវីអម មេធាវីការពារសិទ្ធិជនត្រូវចោទត្រូវតែបង្ហាញមធ្យោបាយការពារកូនក្ដីរបស់ខ្លួន[55]។ចៅក្រមស៊ើបសួរពន្យាពេលនៃការឃុំខ្លួនបណ្ដោះអាសន្នត្រូវធ្វើតាមដីកាដែលមានសំអាងហេតុត្រឹមត្រូវ។

## ១.៤.ការបិទការស៊ើបសួរ

ប្រសិនបើចៅក្រមស៊ើបសួរ យល់ឃើញថាដំណាក់កាលស្រាវជ្រាវរបស់ខ្លួនមានលក្ខណៈគ្រប់គ្រាន់សមស្របសម្រាប់បញ្ចប់នោះចៅក្រមស៊ើបសួរនឹងធ្វើការបិទការស៊ើបសួរដើម្បីបិទសំណុំរឿង។ នៅពេលបញ្ចប់ការស៊ើបសួរចៅក្រមស៊ើបសួរត្រូវតែធ្វើនីតិវិធីនៃការបិទការសួរស៊ើប ហើយចៅក្រមស៊ើបសួរត្រូវបញ្ជូនរឿងទៅព្រះរាជអាជ្ញាតាមរយៈដីកាបញ្ជូនលិខិត(សំណុំរឿង)[56]។ ព្រះរាជអាជ្ញា ជាអ្នកសរសេរដីកាសន្និដ្ឋានស្ថាពរដែលត្រូវបញ្ជូនទៅឲ្យចៅក្រមស៊ើបសួរដើម្បីសម្រេចចេញដីកាដំណោះស្រាយ[57]។

[55] មាត្រា២១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[56] មាត្រា២៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[57] សៀវភៅនីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល

### ១.៤.១.ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា

នៅពេលដែលចៅក្រមស៊ើបសួរយល់ឃើញថាចំពោះការស៊ើបសួរ ត្រូវបានបញ្ចប់នោះ ចៅក្រមស៊ើបសួរត្រូវបញ្ជូនពត៌មានអំពីការស៊ើបសួរទៅកាន់ព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី មេធាវី និងជនត្រូវចោទ។ បន្ទាប់ពីបានជូនពត៌មានទៅភាគីទាំងអស់ហើយ ២ថ្ងៃក្រោយចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងទៅកាន់ព្រះរាជអាជ្ញាសំរាប់ធ្វើការត្រួតពិនិត្យ។ នៅពេលដែលព្រះរាជអាជ្ញាបានពិនិត្យរួចហើយករណីដែលព្រះរាជអាជ្ញាយល់ឃើញថា ត្រូវធ្វើការស៊ើបសួរសារជាថ្មីទៀតនោះព្រះរាជអាជ្ញានឹងធ្វើការស្នើសុំទៅកាន់ចៅក្រមស៊ើបសួរដើម្បីធ្វើការងារស៊ើបសួរបន្តទៅទៀត។

ប្រសិនបើព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី មេធាវីធ្វើការស្នើសុំឲ្យបំពេញកិច្ចនៃការស៊ើបសួរបន្ថែម នោះចៅក្រមស៊ើបសួរត្រូវតែសម្រេចគិតពីបញ្ហានេះម្តងទៀត។ នៅពេលដែលចៅក្រមស៊ើបសួរបានស៊ើបសួរបន្ថែមចប់សព្វគ្រប់អស់ហើយ នោះចៅក្រមស៊ើបសួរត្រូវតែជូនពត៌មានពីការបិទការស៊ើបសួរទៅកាន់ព្រះរាជអាជ្ញាម្តងទៀត។ បើព្រះរាជអាជ្ញាយល់ឃើញថាការស៊ើបសួរពុំមានប្រភពច្បាស់លាស់នៃភស្តុតាងនោះព្រះរាជអាជ្ញានឹងអាចបង្វិលសំណុំរឿងទៅកាន់ចៅក្រមស៊ើបសួរវិញ ដោយមានភ្ជាប់ជាមួយដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផងដែរ ក្នុងរយៈពេល១៥ថ្ងៃ បើជនត្រូវចោទបានឃុំខ្លួន និង១ខែបើជនត្រូវចោទនៅក្រៅឃុំគិតពីថ្ងៃដែលព្រះរាជអាជ្ញាបានឃុំខ្លួន។

ដីកាសន្និដ្ឋានស្ថាពរត្រូវធ្វើជាលាយលក្ខណ៍អក្សរនឹងមានសំអាងហេតុច្បាស់លាស់។ នៅក្នុងដីកាសន្និដ្ឋានស្ថាពរព្រះរាជអាជ្ញាអាចធ្វើការសុំប្តឹងឲ្យចៅក្រមស៊ើបសួរ បញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការដើម្បីធ្វើការជំនុំជម្រះ ឬក៏លើកលែងការចោទប្រកាន់។

### ១.៤.២.ដីកាដំណោះស្រាយ

ដីកាដំណោះស្រាយ ជាដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬប្រភេទដីកាដែលបានលើកលែងការចោទប្រកាន់។ ចៅក្រមស៊ើបសួរអាចបិទការស៊ើបសួរតាមដីកាដំណោះស្រាយ។ នៅពេលដែលចៅក្រមស៊ើបសួរ ចេញដីកាដំណោះស្រាយដោយមានសំអាងហេតុច្បាស់លាស់ហើយត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី។

ដីកាដំណោះស្រាយអាចជាដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ នៅពេលត្រូវបញ្ជូនជនត្រូវចោទទៅតុលាការសំរាប់ជំនុំជម្រះពីបទល្មើសណាមួយដោយ ចៅក្រមស៊ើបសួរត្រូវរៀបរាប់អំពើដែលត្រូវបានចោទប្រកាន់ព្រមទាំងបទល្មើសតាមច្បាប់បានកំណត់។

ចៅក្រមស៊ើបសួរអាចចេញ ដីកាដំណោះស្រាយជាប្រភេទដីកាលើកលែងការចោទប្រកាន់នៅពេលដែលចៅក្រមស៊ើបសួរបានដឹងច្បាស់ថា៖

- អំពើដែលជនត្រូវចោទបានប្រព្រឹត្តមិនជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬលហុ
- ជនដែលបានប្រព្រឹត្តអំពើនោះនៅតែមិនស្គាល់អត្តសញ្ញាណ
- គ្មានភស្តុតាងគ្រប់គ្រាន់សំរាប់ដាក់បន្ទុកបន្ថែមទៅលើជនត្រូវចោទ
- ករណីដែលបណ្តឹងអាជ្ញាបានរលត់។

មានករណីអំពើនៃបទល្មើស បានផុតអាជ្ញាយុកាលនៃទោសដែលមិនអាចធ្វើការចោទប្រកាន់ទៅលើជនត្រូវចោទបាននោះទេ។ នៅក្នុងករណីដែលសំណុំរឿងស៊ើបសួរពាក់ព័ន្ធនឹងអង្គហេតុច្រើនចៅក្រមស៊ើបសួរក៏អាចចេញដីកាដំណោះស្រាយចំពោះអង្គហេតុដែលបានស៊ើបសួរចំពោះអង្គហេតុមួយបានចប់សព្វគ្រប់ ព្រមទាំងធ្វើការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ។ បន្ទាប់ចៅក្រមស៊ើបសួរបានធ្វើសួរបទល្មើសនោះហើយចៅក្រមស៊ើបសួរ នឹងបន្តការស៊ើបសួរអង្គហេតុផ្សេងទៀតចំពោះជនត្រូវចោទនោះតែជាបទល្មើសថ្មី។

ម៉្យាងវិញប្រសិនបើចៅក្រមសម្រេចលើកលែងការចោទប្រកាន់ដោយមូលហេតុ មិនស្គាល់អត្តសញ្ញាណរបស់ជនល្មើស ឬក៏ជនល្មើសបានទទួលមរណៈភាព ចៅក្រមស៊ើបសួរអាចប្តឹងទៅតុលាការព្រហ្មទណ្ឌដើម្បីសម្រេចរឹបអូសឧបករណ៍ សម្ភារៈដែលពាក់ព័ន្ធទៅនឹងបទល្មើស ហើយតុលាការនឹងធ្វើការសម្រេចអំពីការរឹបអូសនេះដោយមាននៅក្នុងសាលក្រមពេលប្រកាសជាសាធារណៈដោយមានការចូលរួមពី តំណាងអយ្យការ និងបុគ្គលដែលពាក់ព័ទ្ធ។ ចំពោះសាលក្រមដែលសម្រេចអំពីការរឹបអូសត្រូវបិទផ្សាយនៅទីកន្លែងដែលតុលាការចេញសាលក្រម និងត្រូវផ្សាយជាសាធារណៈ។

### ១.៤.៣.ការប្រគល់វត្ថុដែលចាប់យកឲ្យទៅម្ចាស់ដើមវិញ

បន្ទាប់ពីចៅក្រមស៊ើបសួរបានពិនិត្យលើអង្គហេតុ និងព្រមទាំងចេញដីកាដំណោះស្រាយរួចរាល់ហើយអស់ហើយ ចៅក្រមស៊ើបសួរ នឹងត្រូវបានគិតសម្រេចអំពីការប្រគល់នូវវត្ថុដែលត្រូវបានចាប់បាននៅអំឡុងពេលស៊ើបសួរសងត្រឡប់ទៅកាន់ម្ចាស់ដើមវិញ។

ករណីនេះយើងមិនអាចធ្វើការទុកនូវវត្ថុដែលយើងបានរកឃើញនៅពេលមានបទល្មើសនោះទេ ព្រោះវត្ថុទាំងអស់នោះជារបស់ជនរងគ្រោះឬក៏អាចជាវត្ថុរបស់ជនត្រូវចោទផង។ នៅពេលដែលចៅក្រមស៊ើបសួរបានបញ្ចប់នៃការបើកការស៊ើបសួរចប់សព្វគ្រប់អស់ ចៅក្រមមិនអាចធ្វើការរក្សាទុកនូវវត្ថុដែលជាកម្មសិទ្ធិរបស់ជនដែលបានពាក់ព័ន្ធនោះទេ។

ចៅក្រមស៊ើបសួរ មិនអាចរក្សាទុកនូវវត្ថុដែលពាក់ព័ន្ធទៅនឹងបទល្មើសយកធ្វើជាកម្មសិទ្ធិរបស់បុគ្គលឯកជនបានឡើយ។ ចៅក្រមស៊ើបសួរត្រូវតែប្រគល់នូវរាល់វត្ថុទាំងអស់របស់ជនត្រូវចោទដែលបានដកហូតនៅពេលស៊ើបសួរនោះនឹងត្រូវប្រគល់ទៅឲ្យម្ចាស់ដើមវិញនៅពេលដែលចប់នីតិវិធីស៊ើបសសួរ។ ចំពោះឯវត្ថុដែលជារបស់ជនរងគ្រោះក៏ត្រូវប្រគល់ទៅឲ្យម្ចាស់ដើមផងដែរ។

## ផ្នែកទី២៖ សវនាការ និងការប្រកាសសាលក្រម

### ២.១.សមាសភាពក្នុងសវនាការ

នៅក្នុងសវនាការមានសមាភាពភាគីដូចជា៖

- ដើមបណ្ដឹងរដ្ឋប្បវេណី គឺជាអាចជាជនរងគ្រោះផ្ទាល់ដែលបានកើតមាននៅកន្លែងកើតហេតុឬអ្នកតំណាងឲ្យភាគីខាងជនរងគ្រោះនៅពេលនីតិវិធីដំណើរការរឿងក្ដី។ ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវតែជាអ្នកតំណាងដោយស្របច្បាប់នឹងមាននូវការយល់ពីជនរងគ្រោះក្នុងការផ្ទេរសិទ្ធរបស់ជនរងគ្រោះផងដែរ។
- ជនជាប់ចោទ គឺជាបុគ្គលដែលតុលាការយល់ឃើញតម្រុយនៃពិរុទ្ធភាព ឬបុគ្គលដែលពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តបទល្មើសដោយមានភស្តុតាងច្បាស់ណាមួយមកបញ្ជាក់។
- ជនរងគ្រោះ ជាបុគ្គលដែលទទួលរងដោយផ្ទាល់នូវព្យសនកម្មដែលបណ្ដាលមកពីបទល្មើសព្រហ្មទណ្ឌ ឬជាបុគ្គលដែលទទួលរងនូវការឈឺចាប់ដោយអំពើខុសច្បាប់ដែលនាំឲ្យខូចសេចក្ដីថ្លៃថ្នូរ កិត្តិយស បញ្ញាស្មារតី រូបរាងកាយ ទ្រព្យសម្បត្តិផ្ទាល់ខ្លួន[58]។
- សាក្សី គឺជាបុគ្គលទាំងឡាយណាដែលបានឃើញរាល់សកម្មភាពទាំងឡាយដែលជនជាប់ល្មើសបានប្រព្រឹត្តទៅលើជនរងគ្រោះនៅក្នុងហេតុការណ៍ជាក់ស្ដែង ឬបទល្មើសជាក់ស្ដែងហើយព្រមចូលខ្លួនមកស្រាយបំភ្លឺរាល់សកម្មភាពដែលខ្លួនបានឃើញពេលកើតហេតុ។
- អ្នកជំនាញ អ្នកបកប្រែ គឺជាអ្នកជំនួយការនៅក្នុងនិយាយបន្តពីជនរងគ្រោះ ឬជនជាប់ចោទ ប្រសិនបើភាគីទាំងពីមិនចេះនិយាយភាសាជាតិរបស់ប្រទេសយើង ឬមិនអាចស្ដាប់ភាសាជាតិបាន។
- អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ជាអ្នកតំណាងឲ្យជនជាប់ចោទក្នុងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីទាំងព្យនកម្មនៃការខូចខាតមានចំពោះជនរងគ្រោះ។
- មេធាវី គឺជាអ្នកតំណាងឲ្យភាគីណាមួយដូចជាអ្នកការពារសិទ្ធឲ្យជនជាប់ចោទ។ មេធាវីមិនមែនជាមន្ត្រីរាជការដែលទទួលបានប្រាក់បៀវត្សន៍ពីរដ្ឋនោះទេ មេធាវីគ្រាន់តែជាអ្នកប្រឹក្សាយោបល់ ជាអ្នកផ្សះផ្សារ

[58] សទ្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំងក្រមព្រហ្មទណ្ឌ ឆ្នាំ២០១១

អ្នកសម្រុះសម្រួលឲ្យភាគីណាម្ខាងឡើយ និងតាក់តែងលិខិតស្នាមនៅក្នុងវិស័យច្បាប់តែប៉ុណ្ណោះ។ម្យ៉ាងវិញទៀតមេធាវីមិនអាចតាំងខ្លួនជាដើមបណ្ដឹងអាជ្ញា ឬក៏ជាអាជ្ញាកណ្ដាលបាននោះទេ។ នៅក្នុងរឿងក្ដីព្រហ្មទណ្ឌមេធាវីមានសិទ្ធិត្រឹមតែជាអ្នកការពារក្ដីឲ្យជនជាប់ចោទនិង ជាអ្នកតំណាងឲ្យអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណីតែប៉ុណ្ណោះ។ មេធាវីមិនអាចធ្វើការឆ្លើយជំនួស ឬទទួលខុសត្រូវជំនួសជនជាប់ចោទនៅក្នុងពេលសវនាការបាននោះទេ។ មេធាវីក៏អាចការពារកូនក្ដីបានដែរ នៅចំពោះមុខក្រុមប្រឹក្សាវិន័យព្រមទាំងការពារគ្រប់ជនទាំងអស់។ បន្ថែមពីនេះទៀតមេធាវីម្នាក់មិនអាចការពារក្ដីទាំងដើមចោទ និងចុងចម្លើយបាននោះទេ។

## ២.២.ការចូលខ្លួនរបស់ភាគី

គ្រប់ភាគីទាំងឡាយដែលបាន ពាក់ព័ន្ធទៅនឹងបទល្មើសត្រូវតែចូលបង្ហាញខ្លួនតាមដីកាកោះហៅរបស់ចៅក្រមនៅចំពោះមុខតុលាការក្នុងពេលសវនាការ។ ការចូលខ្លួនរបស់ភាគីនីមួយៗជាហេតុដើម្បីធ្វើការស្រាយបំភ្លឺរាល់សកម្មភាពទាំងឡាយដែលខ្លួនប្រព្រឹត្ត ឬរាល់សកម្មភាពដែលភាគីទាំងអស់បានឃើញនៅពេលមានបទល្មើសណាមួយកើតមានឡើង។

### ២.២.១.ការចូលខ្លួនរបស់ជនជាប់ចោទ

ចំពោះការចូលខ្លួនរបស់ជនជាប់ចោទ ជនជាប់ចោទត្រូវធ្វើការចូលបង្ហាញខ្លួននៅពេលសវនាការដែលជាការការកំនត់របស់ប្រធានតុលាការដោយផ្ទាល់[59]។ នៅពេលដែលជនជាប់ចោទចូលបង្ហាញខ្លួនត្រូវតែមានមេធាវីតំណាងឲ្យខ្លួនយើងម្នាក់ ហើយមេធាវីនោះត្រូវតែជាមេធាវីដែលខ្លួនបានជ្រើសរើសដោយផ្ទាល់ផងដែរ។ ជនជាប់ចោទអាចសុំឲ្យតុលាការចាត់តាំងមេធាវីម្នាក់ឲ្យខ្លួនបានផងដែរក្នុងករណីពិសេស ប្រសិនបើជនជាប់ចោទពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការស្វែងរកមេធាវីមកការពារខ្លួននៅពេលសវនាការ។ នៅក្នុងនីតិវិធីនៃការបង្ហាញខ្លួននោះ ជនជាប់ចោទត្រូវបានឃុំគ្រងដោយកងកម្លាំងការពាររហូតដល់សាមីខ្លួនបានបង្ហាញខ្លួននៅចំពោះមុខតុលាការ[60]។ កងកម្លាំងត្រូវតែធ្វើការការការពារសុវត្ថិភាពដល់ជនជាប់ចោទកុំឲ្យមានការធ្វើបាបពីសំណាក់ជនណាមួយឡើយ។

[59] មាត្រា៣០០នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[60] មាត្រា៣០២នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

### ២.២.២.ការចូលខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្នុងពេលសវនាការ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីធ្វើតាមការប្រកាសសាមញ្ញនៅចំពោះក្រឡាបញ្ជី។ ការប្រកាសចុះនេះត្រូវតែនិទ្ទេសនៅក្នុងកំណត់ហេតុនៃសវនាការ។ ចំពោះការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនអាចទទួលបានសិទ្ធនោះទេ ក្រោយពីសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាលើអង្គសេចក្តីបានទ ជនរងគ្រោះដែលបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរួចហើយនៅពេលស៊ើបសួរមិចចាំបាច់បំពេញទម្រង់ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សារជាថ្មីទៀតទេនៅមុខតុលាការ[61]។ ពេលដែលដើមបណ្តឹងរដ្ឋប្បវេណីចូលខ្លួននៅក្នុងសវនាការក៏អាចអមមេធាវីតំណាងម្នាក់ដែលខ្លួនបានជ្រើសរើសផងដែរ។ចំពោះមេធាវី សហព័ទ្ធ ញាតិលោហិតក៏អាចតំណាងជំនួសឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅពេលសវនាការដែរ។ ចំណែកឯអ្នកតំណាងមិនមែនជាមេធាវីត្រូវតែមានលិខិតប្រគល់សិទ្ធជាលាយលក្ខណ៍អក្សរដោយដើមបណ្តឹងរដ្ឋប្បវេណី[62]។

### ២.២.៣.ការចូលខ្លួនរបស់អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី

អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណីត្រូវចូលបង្ហាញខ្លួនតាមដីកាកោះរបស់តុលាការ។ ការចូលខ្លួនរបស់អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណីចំពោះមុខតុលាការ នៅក្នុងពេលសវនាការត្រូវមានអមដោយមេធាវីផ្ទាល់ខ្លួនម្នាក់។ អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណីត្រូវតែឆ្លើយរាល់សំនួរដែលតុលាការបានសួរនៅក្នុងពេលសវនាការព្រមទាំងទទួលជំនួសរាល់សកម្មភាពដែលជនត្រូវចោទបានប្រព្រឹត្តទៅលើជនរងគ្រោះ។ មេធាវី សហព័ទ្ធ ឬញាតិលោហិតក៏អាចតាំងខ្លួនជាអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផងដែរ។ អ្នកតំណាងដែលមិនមានមុខងារជាមេធាវីត្រូវតែមានលិខិតប្រគល់សិទ្ធពីជនជាប់ចោទជាលាយលក្ខណ៍អក្សរ[63]។

### ២.២.៤.ការចូលខ្លួនរបស់សាក្សី

សាក្សីត្រូវធ្វើការចូលខ្លួននៅក្នុងសវនាការតាមការកោះហៅរបស់តុលាការដែល បានកំនត់ពេលវេលាមួយច្បាស់លាស់។ តុលាការអាចបញ្ជាកងកម្លាំងដើម្បីធ្វើការបង្ខំសាក្សីឲ្យចូលបង្ហាញខ្លួនក្នុងសវនាការសំរាប់ធ្វើការស្រាយបំភ្លឺដល់ភាគីទាំងសងខាងនៅក្នុងអង្គសវនាការ។

ការចូលខ្លួនរបស់សាក្សី ជាសារៈប្រយោជន៍សំខាន់ក្នុងការឆ្លើយបំភ្លឺនូវហេតុការដែលខ្លួនបានឃើញផ្ទាល់ភ្នែកហើយមានភាពច្បាស់លាស់។ ដើម្បីឲ្យមានភាពងាយស្រួលដល់តុលាការនៅក្នុងការវិនិច្ឆ័យលើអង្គហេតុ។

---

[61] មាត្រា៣១១នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[62] មាត្រា៣១៣នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[63] មាត្រា៣១៤នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាចក្រកម្ពុជា

## ២.៣.កិច្ចដេញដោល

ការពិភ្សាដេញដោលបានធ្វើការប្រព្រឹត្តទៅនៅក្នុងពេលសវនាការជាសាធារណៈ។ ក្នុងករណីដែលតុលាការយល់ឃើញថាកិច្ចដេញដោលជាសាធារណៈក្នុងពេល សវនាការអាចប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់នោះតុលាការនឹងធ្វើតាមសេចក្តីសម្រេចមានសំអាងហេតុច្បាស់លាស់ អាចបង្គាប់ឲ្យមានការពិភាក្សាដេញដោលទាំងស្រុងឬមួយផ្នែកប្រព្រឹត្តទៅនៅបន្ទប់សម្ងាត់។ បន្ទាប់ពីកិច្ចពីភាក្សាដេញដោលចប់ តុលាការនឹងធ្វើការសម្រេចតុលាការដែលបានសម្រេចបង្គាប់ឲ្យធ្វើការពិភាក្សាដេញដោលជាសម្ងាត់មិនអាចធ្វើការតវ៉ាបាននោះទេ[64]។

ប្រធានសវនាការជាអ្នកដឹកនាំការពិភាក្សាដេញដោលនៅពេលសវនាការ។ ចំពោះប្រធានសវនាការត្រូវរ៉ាប់រងឲ្យមានសិទ្ធិដល់ខាងការការពារបានប្រព្រឹត្តទៅដោយសេរី។ ប្រធានសវនាការក៏មានសិទ្ធិបដិសេដចេញពីកិច្ចពិភាក្សាដេញដោលដែលមាន គោលបំណងធ្វើការអូសបន្លាយការពិភាក្សាដេញដោលឲ្យអត់ប្រយោជន៍គ្មានរួមវិភាគទានអ្វីដល់ការបង្ហាញឲ្យឃើញពីការពិត។ ប្រធានត្រូវនាំគ្នារ៉ាប់រងឲ្យមានសណ្តាប់ធ្នាប់ល្អនៅពេលសវនាការ អាចហាមឃាត់អនីតិជនខ្លះឬទាំងអស់មិនឲ្យចូលទៅបន្ទប់សវនាការអាចបង្គប់ឬដេញបុគ្គលគ្រប់រូបដែលបង្កឲ្យមានការច្របូកច្របល់ដល់របៀបរៀបរយនៃការពិភាក្សាដេញដោល។

នៅក្នុងពេលសវនាការអាច ប្រើប្រាស់កងកម្លាំងការពារនៅពេលបំពេញមុខងារ[65]។ ក្រឡាបញ្ជីត្រូវហៅឈ្មោះជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី អ្នកជំនាញ ព្រមទាំងអ្នកផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់បុគ្គលទាំងអស់នោះ។ ក្នុងករណីដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ដែលតំណាងដោយសហព័ទ្ធ ឬខ្សែលោហិតផ្ទាល់ក្រឡាបញ្ជី ត្រូវពិនិត្យផ្ទៀងផ្ទាត់ពីសុពលភាពនៃការទទួលបានសិទ្ធដែលបានពីជនរងគ្រោះ និងជនជាប់ចោទ។ ក្រឡាបញ្ជីត្រូវសរសេរកំណត់ហេតុសវនាការដោយរៀបរាប់ពីដំណើរការប្រព្រឹត្តទៅនៃសវនាការ និងសួរចម្លើយជនពាក់ព័ទ្ធនៅក្នុងសវនាការ។ ចំពោះកំណត់ហេតុទាំងឡាយដែលបានពីការសួរចម្លើយជនរងគ្រោះ និងជនសង្ស័យត្រូវតែធ្វើការចុះហត្ថលេខាដោយក្រឡាបញ្ជី និងចុះទិដ្ឋាការក្រោយពីការផ្ទៀងផ្ទាត់ដោយប្រធានសវនាការក្នុងរយៈពេល១០ថ្ងៃក្រោយពេលដែលបានប្រកាសសាលក្រម។

- ភាគីនីមួយៗត្រូវតែអង្គុយទៅតាមកន្លែងដែលគេបានរៀបចំទុក

[64] មាត្រា៣១៧នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[65] មាត្រា៣១៨នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

- ប្រធានសវនាការប្រាប់ដល់ជនជាប់ចោទឲ្យដឹងពីបទដែលគេបានធ្វើការចោទប្រកាន់មកលើខ្លួន
- ប្រធានសវនាការសួរចម្លើយទៅកាន់ជនជាប់ចោទ ទាំងការដាក់បន្ទុក និងការដោះបន្ទុក
- ព្រះរាជអាជ្ញា មេធាវី និងភាគីអាចត្រូវបានអនុញ្ញាតឲ្យធ្វើការលើកសំនួរសួរដល់ជនជាប់ចោទ។ ចំណែកឯសំនួរផ្សេងៗទៀតត្រូវសួរតាមរយៈប្រធានសវនាការ
- ប្រធានសវនាការស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី
- ព្រះរាជអាជ្ញា មេធាវីនិងភាគីដែលពាក់ព័ន្ធក៏អាចលើកសំនួរដល់ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីផងដែរ។ ក្រៅពីសំនួររបស់តំណាងអយ្យការ និងមេធាវីចំពោះសំនួរផ្សេងទៀតត្រូវសួរតាមរយៈដោយប្រធានសវនាការ
- តុលាការក៏អាចធ្វើការស្ដាប់ចម្លើយរបស់អ្នកបានប្ដឹងបរិហារបានដែរ សំរាប់យកធ្វើជាពត៌មានបន្ថែមងាយស្រួលក្នុងការវិនិច្ឆ័យទៅលើបទល្មើសផងដែរ[66]
- មុនពេលឲ្យសាក្សីចូលទៅផ្ដល់ចម្លើយត្រូវតែឲ្យសាក្សីចូលទៅស្បថស្របតាមសាសនា ឬតាមជំនឿរបស់បុគ្គលនោះ(សាសនាព្រះពុទ្ធ សាសនាគ្រីស្ដ ឬសាសនាឥស្លាម)។
- បន្ទាប់មកប្រធានសវនាការធ្វើការសួរសាក្សីនីមួយៗថាតើសាក្សីជាញាតិលោហិត ឬជាញាតិពន្ធរបស់ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណីឬជាអ្នកស៊ីឈ្នួលបម្រើជនជាប់ចោទដែរឬទេ[67]។ ប្រធានសវនាការធ្វើការស្ដាប់ចម្លើយរបស់សាក្សី។ បន្ទាប់ពីការសួរចម្លើយរបស់ប្រធានសវនាការដល់សាក្សី ព្រះរាជអាជ្ញា មេធាវី និងភាគីក៏ត្រូវបានអនុញ្ញាតឲ្យលើកសំណួរដល់សាក្សីផងដែរ។ ភាគីអាចសុំឲ្យតុលាការស្ដាប់ចម្លើយក្នុងឋានៈជាសាក្សីដល់បុគ្គលដែលមានវត្តមាន នៅពេលសវនាការ ប៉ុន្តែមិនបានកោះហៅឲ្យបានត្រឹមត្រូវនោះទេ។ ក្នុងករណីដែលសាក្សីមិនព្រមចូលខ្លួនតាមការកោះហៅរបស់តុលាការពេលសវនាការ តុលាការអាចប្រើកងកម្លាំងសាធារណៈដើម្បីបង្ខំសាក្សីឲ្យចូលខ្លួន[68]។

តែប្រសិនបើជនពាក់ព័ន្ធជាមនុស្សគ ថ្លង់ ក្រឡាបញ្ជីសរសេរសំនួរសំរាប់ឲ្យសាមីខ្លួនអានបន្ទាប់មកឲ្យសាមីខ្លួនឆ្លើយសំនួរជាការសរសេរជំនួសការនិយាយ។ តែករណីពិសេសមិនអាចអានបានទេត្រូវរកអ្នកបកប្រែដោយត្រូវឲ្យស្បថតាសាសនានិងជំនឿរបស់ខ្លួនជួយដល់តុលាការ និងបកប្រែសំនួរចម្លើយឲ្យមានភាពស្មោះ

[66] មាត្រា៣២៩នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
[67] មាត្រា៣២៨នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[68] មាត្រា៣១៥នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

ត្រង់[69]។ ប្រសិនបើសាមីខ្លួនពុំអាចនិយាយភាសាខ្មែរបានត្រូវរកអ្នកបកប្រែជំនួសហើយត្រូវស្បថតាមរបៀបសាសនា និងជំនឿរបស់ខ្លួនថាជួយតុលាការ និងបកប្រែឲ្យបានស្មោះត្រង់[70]។

ចំពោះអ្នកបកប្រែមិនអាចជ្រើសចេញពីព្រះរាជអាជ្ញា ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ គូរភាគី និងសាក្សីនោះទេ។ ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចធ្វើការសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងលិខិតស្នាមទាំងឡាយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់បង្ហាញឲ្យឃើញពីការពិត។ ចំពោះសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរត្រូវចុះ ការដោយប្រធានសវនាការ និងក្រឡាបញ្ជីហើយភ្ជាប់ក្នុងសំណុំរឿង[71]។ ការដាក់សេចក្ដីសន្និដ្ឋានត្រូវធ្វើមុនពេលបិទការពិភាក្សាដេញដោល។ នៅពេលដែលការពិភាក្សាដេញដោលមិនអាចបញ្ចប់នៅក្នុងសវនាការទេ តុលាការអាចធ្វើការបន្តសវនាការនៅពេលក្រោយតាមការបរិច្ឆេទដែលខ្លួនបានកំណត់[72]។

ក្រោយពីកិច្ចពិភាក្សាដេញដោលចប់ ប្រធានសវនាការបានប្រគល់សិទ្ធិនិយាយជាបន្តបន្ទាប់គ្នារវាង៖

- ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនជាប់ចោទដើម្បីធ្វើកំនត់សម្គាល់ខ្លីៗព្រះរាជអាជ្ញា សំរាប់ធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំ
- មេធាវីរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី មេធាវីរបស់ជនជាប់ចោទសំរាប់ធ្វើសេចក្ដីសម្រេចសន្និដ្ឋានការពារសិទ្ធិរបស់កូនក្ដី
- មេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីធ្វើសេចក្ដីសន្និដ្ឋានការពារ[73]

បន្ទាប់ពីកិច្ចដេញដោលបានបញ្ចប់ តុលាការត្រូវថយខ្លួនចូលទៅក្នុងបន្ទប់ដើម្បីពិភាក្សាសម្រេចអំពីអង្គហេតុខាងលើ។ ប្រសិនបើគ្មានទទឡ្ហីករណ៍ណាមួយច្បាស់លាស់នោះដែលត្រូវលើកមកសំអាងហេតុនោះតុលាការក៏មិនអាចធ្វើការប្រកាសសាលក្រមបានភ្លាមៗនោះទេ[74]។ តុលាការនឹងត្រូវលើកការប្រកាសសាលក្រមនៅពេលក្រោយ។

---

[69] មាត្រា៣១៣នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[70] មាត្រា៣៣០នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[71] មាត្រា៣៣៤នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាចក្រកម្ពុជា
[72] មាត្រា៣៤០នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[73] មាត្រា៣៣៥នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[74] មាត្រា៣៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

## ២.៤.សាលក្រម

សាលក្រម ជាសេចក្ដីសម្រេចចុងក្រោយរបស់តុលាការបន្ទាប់ពីកិច្ចពិភាក្សាដេញដោលបានបញ្ចប់សំរាប់បង្ហាញអំពីអង្គហេតុណាមួយបញ្ជាក់ពីភាពឈ្នះ ឬចាញ់របស់ភាគីទាំងសងខាង។ បន្ទាប់ពីតុលាការបានពិភាក្សាគ្នារួចមកតុលាការនឹងធ្វើការប្រកាសអង្គហេតុក្រោយពេលបានស្ដាប់ភាគីដើមបណ្ដឹង នឹងចុងចម្លើយបានតទល់គ្នានៅពេលសវនាការ។ សាលក្រមជាសេចក្ដីសម្រេចចុងក្រោយសំរាប់ភាគីដើមបណ្ដឹងរដ្ឋប្បវេណី និង ជនជាប់ចោទ ដែលត្រូវប្រកាសពីកំរិតទោសរបស់ខ្លួន ឬការរួចផុតពីការទទួលខុសត្រូវទាំងផ្នែកព្រហ្មទណ្ឌព្រមទាំងផ្នែករដ្ឋប្បវេណី។ សាលក្រមត្រូវតែធ្វើការប្រកាសជាសាធារណៈនៅពេលថ្ងៃពិភាក្សាកិច្ចដេញដោល ឬនៅពេលក្រោយសវនាការ ចំពោះការបរិច្ឆេទនៃការប្រកាសសាលក្រមត្រូវធ្វើការប្រាប់ដល់ភាគីដែលមានវត្តមាននៅក្នុងពេលសវនាការ។

នៅក្នុងសេចក្ដីសម្រេចចុងក្រោយរបស់តុលាការត្រូវកំណត់នូវពិរុទ្ធភាព ព្រមទាំងប្រកាសពីកំរិតទោសដែលបានកំណត់ដោយច្បាប់ចំពោះពិរុទ្ធជន។ តែករណីដែលតុលាការយល់ឃើញថារាល់បញ្ហាទាំងអស់មិនមែនជាបទល្មើស ឬរកឃើញថាជនជាប់ចោទពុំមានពិរុទ្ធភាព នោះតុលាការអាចចេញសាលក្រមដោយសម្រេចឲ្យជនជាប់គ្មានទោស[75]។ តែបើករណីដែលតុលាការបានរកឃើញជនជាប់ចោទមានពិរុទ្ធភាពដោយត្រូវដាក់ពន្ធនាគារនោះតុលាការអាចចេញដីកាបង្គាប់ឲ្យឃុំខ្លួនភ្លាម ប្រសិនបើជនជាប់ចោទមានវត្តមាននៅក្នុងពេលសវនាការ។ សាលក្រមត្រូវតែចុះហត្ថលេខាដោយប្រធានតុលាការ និងក្រឡាបញ្ជីមុនពេលប្រកាស។
ចំពោះសាលក្រមដែលត្រូវប្រកាសត្រូវតែចុះនិរទ្ទេសដូចជា៖

- កាលបរិច្ឆេទនៃសវនាការ
- កាលបរិច្ឆេទនៃការប្រកាសសាលក្រម
- ឈ្មោះ និងឋានៈរបស់ចៅក្រមជំនុំជម្រះ
- ឈ្មោះ និងឋានៈតំណាងអយ្យការ
- ឈ្មោះ និងឋានៈរបស់ក្រឡាបញ្ជី
- ឈ្មោះទីលំនៅ កាលបរិច្ឆេទ ទីកន្លែងកំណើត មុខរបររបស់ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី
- ឈ្មោះមេធាវីការពារក្ដី។

[75] ទ្រឹស្ដីនីតិវិធីព្រហ្មទណ្ឌ ដោយសាស្ត្រា អៀង សំណាង

ក្រោយពេលប្រកាសសាលក្រមរួច ត្រូវតែតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីយ៉ាងយូរបំផុតរយៈពេល ៨ថ្ងៃ។ ក្រឡាបញ្ជីត្រូវតែរក្សាច្បាប់ដើមរបស់សាលក្រមជានិច្ច។ សាលក្រមត្រូវតែធ្វើការប្រកាសនៅពេលសវនការជាសាធារណៈ ។

### ២.៤.១.សាលក្រមចំពោះមុខ

សាលក្រមចំពោះមុខ គឺមានន័យថានៅពេលជនជាប់ចោទបានចូលបង្ហាញខ្លួនក្នុងសវនាការ នោះនៅពេលចៅក្រមប្រកាសសាលក្រមនោះសាលក្រមនោះត្រូវចាត់ទុកជាសាលក្រមចំពោះមុខ។ ចំពោះការចាកចេញរបស់ជនជាប់ចោទមុនសវនាការបានបញ្ចប់ ហើយនៅពេលប្រកាសសាលក្រមក៏ត្រូវបានចាត់ទុកជាសាលក្រមចំពោះមុខផងដែរ។

ក្នុងករណីប្រសិនបើជនជាប់ចោទអាចចូលបង្ហាញខ្លួននៅចំពោះមុខតុលាការដោយសារបញ្ហា សុខភាពនោះតុលាការត្រូវទៅសួរចម្លើយដល់កន្លែងដែលជនជាប់ចោទនោះបានស្នាក់នៅ ហើយសាលក្រមដែលបានប្រកាសនៅពេលនោះសាលក្រមក៏ជាសាលក្រមចំពោះមុខជនជាប់ចោទដែរ។

ម្យ៉ាងទៀតអាចចាត់ទុកជាសាលក្រមចំពោះផងដែរ ប្រសិនបើនៅពេលប្រកាសសាលក្រមមានវត្តមានដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬអ្នកតំណាងស្របច្បាប់ណាម្នាក់។

### ២.៤.២.សាលក្រមដែលចាត់ថាចំពោះមុខ

សាលក្រមដែលចាត់ថាចំពោះមុខ គឺជាប្រភេទសាលក្រមដែលតុលាការបានប្រកាសនៅពេលបញ្ចប់នីតិវិធីតែពុំមានវត្តមានរបស់ជនជាប់ចោទនៅក្នុងសវនាការសាលក្រមត្រូវបានចាត់ថាចំពោះមុខ។ ប្រសិនបើជនជាប់ចោទបានទទួលដំណឹងអំពីការកោះហៅ ឬដីកាបញ្ជូនទៅជម្រះក្តីប៉ុន្តែបែរជាពុំមានវត្តមាននៅពេលសវនាការនោះសាលក្រមដែលបានប្រកាសដោយតុលាការនោះត្រូវចាត់ជា ប្រភេទសាលក្រមដែលចាត់ថាចំពោះមុខ។ សាលក្រមដែលចាត់ថាជាសាលក្រមចំពោះមុខត្រូវតែជូនដំណឹងដល់ជនជាប់ចោទផងដែរ។

ករណីបើជនជាប់ចោទអវត្តមានតែបានបង្ហាញនូវ មូលហេតុច្បាស់លាស់អំពីការខកខានរបស់ខ្លួនហើយតុលាការក៏បានទទួលដឹងលឺត្រឹមត្រូវនោះតុលាការអាចលើករឿងនេះ ទៅជំនុំជម្រះនៅពេលសវនាការក្រោយទៀតបានផងដែរ។

### ២.៤.៣.សាលក្រមកំបាំងមុខ

សាលក្រមកំបាំងមុខ មានន័យថានៅពេលដែលតុលាការប្រកាសជនជាប់ចោទមិនចូលក្នុងសវនាការហើយមិនបានទទួលដំណឹងពីសវនាការ។

ក្នុងករណីដែលជនជាប់ចោទមិនបានបង្ហាញខ្លួននៅពេលសវនាការនោះ ហើយព្រមទាំងមិនបានទទួលដំណឹងអំពីសវនាការឬសាមុីខ្លួនមិនបានដឹងដំណឹងពីដីកាបញ្ជូនទៅជំនុំជម្រះ សាលក្រមត្រូវប្រកាសដោយកំបាំងមុខ។ ហើយសាលក្រមដែលប្រកាសដោយកំបាំងមុខនោះត្រូវតែធ្វើការជូនដំណឹងទៅដល់ជនជាប់ចោទ។

ក្នុងករណីមួយចំនួនក៏អាចចាត់ទុក ជាសាលក្រមកំបាំងមុខផងដែរប្រសិនបើពេលដែលប្រកាសសាលក្រម ពុំមានវត្តមានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ឬអ្នកតំណាងស្របច្បាប់ណាម្នាក់។

### ២.៤.៤.ការប្រកាសសាលក្រម

បន្ទាប់ពីចៅក្រមបានស្ដាប់ភាគីព្រមទាំងសាក្សីទាំងសងខាងរួចហើយ នោះចៅក្រមជំនុំជម្រះសុំឲ្យភាគីទាំងពីរធ្វើសេចក្ដីសន្និដ្ឋានតាមក្រោយករណីមានភស្ដុតាងច្បាស់លាស់។ ហើយព្រះរាជអាជ្ញាធ្វើសេចក្ដីសន្និដ្ឋានអំពីទណ្ឌកម្ម បន្ទាប់មកទៀតមេធាវីខាងជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយ។ ការប្រកាសសាលក្រមត្រូវបានធ្វើឡើងនៅអំឡុងពេលសវនាការដែលធ្វើការពិភាក្សាដេញដោលបានបញ្ចប់ ឬនៅពេលដំណើរការសវនាការលើកក្រោយ កាលបរិច្ឆេទបើកសវនការត្រូវបានធ្វើការកំណត់ដោយប្រធានសាលាដំបូង។

ចំពោះសាលក្រមដែលត្រូវប្រកាស ត្រូវតែប្រកាសនៅពេលសវនាការជាសាធារណៈនៅចំពោះជនជាប់ចោទ ជនរងគ្រោះនិងសាធារណៈជនទូទៅដោយប្រធានសាលាបំបូងជាអ្នកប្រកាសដោយធ្វើការអានជាសម្លេងខ្លាំងៗហើយលឺៗ ថែមទៀតផង[76]។ ករណីនេះនៅពេលប្រកាសសាលក្រមបើខាងដើមបណ្ដឹងរដ្ឋប្បវេណីជាអ្នកឈ្នះក្ដីនោះ ពិរុទ្ធជន ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណីត្រូវធ្វើសងនៃការខូចខាតដល់ជនរងគ្រោះឲ្យសមទៅតាមទំហំដែលបានខូចខាត។

### ២.៤.៥.អានុភាពនៃសាលក្រម

សាលក្រមមានអានុភាពនៅពេលដែលសាលក្រមនោះបានចូលជាស្ថាពរ។ សាលក្រមដែលបានប្រកាសដោយប្រធានតុលាការ នៅពេលចប់នីតិវិធីសវនាការមានអានុភាពនៅពេលដែលពុំមានបណ្ដឹងទាស់ពីជនជាប់ចោទ រយៈពេល១៥ថ្ងៃបន្ទាប់ពីថ្ងៃប្រកាសសាលក្រម។ តុលាការបានទុករយៈពេល១៥ថ្ងៃដើម្បីទុករយៈពេលឲ្យជនជាប់ចោទធ្វើបណ្ដឹងទាស់នឹងសាលក្រម។ ករណីដែលគ្មានការប្ដឹងទាស់ពីជនជាប់ចោទក្នុងរយៈពេល ១៥ថ្ងៃនោះទេ សាលក្រមនឹងចូលជាស្ថាពរ។

[76] មាត្រា៣៥៩នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់តាមការស្រាវជ្រាវ និងបកស្រាយនូវប្រធានបទស្តីអំពី «**ដំណើរការរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូងរាជធានីភ្នំពេញ**» ខាងលើនេះរួចមកវាបាននាំស្មារតីយើងខ្ញុំឲ្យយល់បានកាន់តែច្បាស់អំពីនីតិវិធី និងដំណាក់កាលផ្សេងៗនៃរឿងក្តីព្រហ្មទណ្ឌនៅក្នុងសាលាដំបូងរាជធានីភ្នំពេញ។ ការសិក្សាទៅលើប្រធានបទដ៏សំខាន់មួយនេះបានបង្ហាញផ្លូវដល់យើងខ្ញុំ ដែលជាអនាគតអ្នកច្បាប់នៅប្រទេសកម្ពុជាឲ្យដឹងកាន់តែច្បាស់អំពីដំណាក់កាលនីមួយៗ នៃរឿងក្តីព្រហ្មទណ្ឌដោយផ្អែកទៅលើក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

តាមការបកស្រាយខាងលើនេះ គឺយើងធ្វើការសិក្សាទៅលើដំណាក់កាលនីមួយៗនៃបណ្តឹងព្រហ្មទណ្ឌ សមត្ថកិច្ចរបស់មន្ត្រីតុលាការ និងអំណាចតុលាការចាប់តាំងពីដំណាក់កាលមុនសវនាការរហូតដល់ការអនុវត្តនូវសាលក្រមតែម្តងដោយបានលើកយកនូវគោលការណ៍សំខាន់របស់ក្រមនីតិវិធីព្រហ្មទណ្ឌ យកមកបង្ហាញជូនដើម្បីជាអំណះអំណាងផងដែរ ព្រោះថាកាស្រាវជ្រាវមួយនេះគឺជាការស្រាវជ្រាវបែបនីតិសាស្ត្រសុទ្ធសាធតែម្តង។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ដំណាក់កាលនៃការអនុវត្តនូវនីតិវិធីនីមួយគឺត្រូវបានកំណត់យ៉ាងជាក់លាក់នៅក្នុងក្រមនោះដើម្បីឲ្យមន្ត្រីរបស់តុលាការមានការងាយស្រួលនៅក្នុង ការអនុវត្តនូវនីតិវិធីទាំងឡាយដោយសុក្រឹត្យភាព ព្រមទាំងយុត្តិធម៌ផងដែរ។ លើសពីនេះទៅទៀតដោយសារតែមានការលំបាកក្នុងការកំណត់នូវនីតិវិធី រដ្ឋបានបង្កើតនូវក្រមនីតិព្រហ្មទណ្ឌនេះឡើង ដើម្បីជំនួយដល់ស្ថាប័នតុលាការព្រមទាំងមន្ត្រីទាំងមូលដើម្បីធ្វើការគោរពតាម។ ការកំណត់នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិអំពីសមត្ថកិច្ចរបស់មន្ត្រីតុលាការរួមមានចៅក្រមជំនុំជម្រះ ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីនគរបាលយុត្តិធម៌ដែលជាតួអង្គសំខាន់ៗនៅក្នុងដំណើរការនីតិធីនៃបណ្តឹងព្រហ្មទណ្ឌនៅសាលាដំបូងជាធានីភ្នំពេញ។ លើសពីនេះទៅទៀតយើងខ្ញុំបានដឹងកាន់តែច្បាស់អំពីតួនាទីរបស់សាលាដំបូង និងមន្ត្រីរបស់សាលាដំបូងដែលជាបណ្តុំនៃអ្នកស្វែងរកនូវយុត្តិធម៌ជូនដល់ប្រជាពលរដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាតែម្តង។

ជាចុងក្រោយ ក្រមនីតិវិធីព្រហ្មទណ្ឌបានដើរតួយ៉ាងសំខាន់នៅក្នុងបណ្តឹងព្រហ្មទណ្ឌដោយសារក្រមដ៏សំខាន់មួយនេះបានបង្ហាញផ្លូវដល់ មន្ត្រីតុលាការក្នុងការឈានទៅរកនីតិវិធីនីមួយៗដែលមានលក្ខណៈពិបាកក្នុងការចងចាំ។ តាមការសន្និដ្ឋានរបស់យើងខ្ញុំទាំងពីររូបក្រមនីតិវិធីព្រហ្មទណ្ឌគឺប្រៀបដូចជាត្រីវិស័យដែលមន្ត្រីតុលាការទាំងឡាយមិនអាចខ្វះបាន ដោយសារតែក្រមនេះបានកំណត់នូវនីតិវិធីយ៉ាងច្បាស់លាស់សំរាប់ជំនួយដល់មន្ត្រីតុលាការនៅក្នុងការដោះស្រាយនូវបណ្តឹងព្រហ្មទណ្ឌ។

# អនុសាសន៍

# អនុសាសន៍

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវទៅលើមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌ យើងខ្ញុំបានយល់កាន់តែច្បាស់អំពីដំណើរការរឿងក្តីនៅសាលាដំបូងរាជធានីភ្នំពេញ។ ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់យ៉ាងច្បាស់អំពីដំណាក់កាលនីមួយៗនៃរឿងក្តីទាំងមុនសវនាការហូតដល់ក្រោយសវនាកា។ ដូចនេះតាងនាមយើងខ្ញុំជានិស្សិតផ្នែកនីតិសាស្រ្ត សូមផ្តល់នូវអនុសាន៍ដ៏សួចស្តើងមួយដើម្បីចូលរួមលើកកំពស់ផ្នែកច្បាប់នៅព្រះរាជាណាចក្រកម្ពុជា។

ក.យើងខ្ញុំសូមសំណូមពរដល់ក្រសួងអប់រំ យុវជន និងកីឡា ឲ្យលោកធ្វើការផ្សព្វផ្សាយបន្ថែមអំពីនីតិវិធីព្រហ្មទណ្ឌដើម្បីឲ្យប្រជាជនទូទៅយល់ដឹងឲ្យកាន់តែច្បាស់អំពីដំណើរការរឿងក្តីនៅក្នុងតុលាការ ជៀសវាងមាននូវជនខិលខូចមួយចំនួនធ្វើការបោកប្រាស់ទៅដល់ប្រជាពលរដ្ឋដែលលោកមិនបានយល់ដឹងពីនីតិវិធី នៅក្នុងរឿងព្រហ្មទណ្ឌ។

ខ.យើងខ្ញុំសូមសំណូមពរដល់ខាងក្រសួងអប់រំយុវជននិងកីឡាឲ្យលោកធ្វើការបើកឲ្យមាននូវកម្មសិក្សាជូនដល់និស្សិតច្បាប់ទៅកាន់តុលាការគ្រប់ជាន់ថ្នាក់ ដើម្បីឲ្យយើងខ្ញុំបានឃើញអំពីទិដ្ឋភាពជាក់ស្តែងនៅក្នុងសវនាការ។

គ.យើងខ្ញុំសូមសំណូមពរដល់សាលាវិជ្ជាជីវៈនៃមន្រ្តីតុលាការធ្វើការប្រឡងជ្រើសរើសមន្រ្តីបម្រើការនៅក្នុងតុលាការដោយផ្អែកទៅលើសមត្ថភាពផ្នែកច្បាប់ និងសីលធម៌ ព្រមទាំងជៀសវាងនូវអំពើពុករលួយដើម្បីឲ្យស្ថាប័នតុលាការទាំងមូលក្លាយទៅជាស្ថាប័នដែលស្វែងរយុត្តិធម៌ជូនប្រជាពលរដ្ឋពិតប្រាកដ។

ឃ.យើងខ្ញុំសូមសំណូមពរដល់ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ព្រមទាំងសាកលវិទ្យាល័យនានាដែលស្ថិតនៅក្នុងព្រះរាជាណាក្រកម្ពុជាដែលមាននូវមហាវិទ្យាល័យច្បាប់ គួរតែបង្កើតឲ្យមាននូវតុលាការសប្បនិម្មិត ក៏ដូចជាសភាសប្បនិម្មិត ដើម្បីឲ្យនិស្សិតធ្វើការអនុវត្តនូវទ្រឹស្តីទៅក្នុងទិដ្ឋភាពជាក់ស្តែង។

ង.យើងខ្ញុំសូមសំណូមពរដល់ក្រសួង និងស្ថាប័នរដ្ឋទាំងឡាយគប្បីគួរតែធ្វើការចូលរួមផ្សព្វផ្សាយអំពីនីតិវិធីព្រហ្មទណ្ឌ និងវិធានបទដ្ឋានគតិយុត្តទាំងអស់ដើម្បីឲ្យពលរដ្ឋខ្មែរយល់ដឹងឲ្យកាន់តែច្បាស់អំពីផ្នែកច្បាប់នេះ ព្រោះថាប្រជាពលរដ្ឋកម្ពុជាមួយចំនួនធំពុំសូវបានស្វែងយល់អំពីផ្នែកច្បាប់នេះទេ ដែលជាហេតុនាំឲ្យកើតមាននូវភាពអសកម្មនៅក្នុងសង្គម។

# ឯកសារពិគ្រោះ

# ឯកសារពិគ្រោះ

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត


រដ្ឋសភា. (2015). *រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា.* ភ្នំពេញ: ក្រសួងយុត្តិធម៌.

ក្រសួងយុត្តិធម៌. (2007). *ក្រមនីតិវិធីព្រហ្មទណ្ឌ.* ភ្នំពេញ.

ក្រសួងយុត្តិធម៌) .2014). *ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ.* ភ្នំពេញ.


## សៀវភៅ


បណ្ឌិត អ៊ុន សក្តដា. (2008). *ប្រវត្តិគំនិតនយោបាយ.* ភ្នំពេញ

បណ្ឌិត ឈុន ណារ៉េត. (2012). *សេចក្តីផ្តើមវិទ្យាសាស្ត្រនយោបាយ.* ភ្នំពេញ.

លោក ឥន យឿន. (n.d.). *មូលដ្ឋានច្បាប់ និង ស្ថាប័នច្បាប់* (3rd ed.). លោក នៅ សារ៉េត.

ព្រះបរមរាជវាំង. (n.d.). ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ.

លោក ខាន់ សុខា លោក ស្រី ឌី លីឡា. (n.d.). មេរៀននីតិវិធីព្រហ្មទណ្ឌ៖ នគរបាលយុត្តិធម៌. ភ្នំពេញ

លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត និងលោកសាស្ត្រាចារ្យ ជា ម៉េត . (2016). នីតិវិធីព្រហ្មទណ្ឌ. ភ្នំពេញ.

សាស្ត្រាចារ្យ អៀង សំណាង. (n.d.). គម្រូពាក្យបណ្តឹង. ភ្នំពេញ.

សាស្ត្រាចារ្យ អៀង សំណាង) .2015). *ទ្រឹស្តីនីតិវិធីព្រហ្មទណ្ឌ* (1st ed.). ភ្នំពេញ.

អំណោយរបស់ស្ថានទូតបារាំង. (n.d.). សៀវភៅនីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល

លោក អាត ច័ន្ទដារា និង លោក សុខ ប៊ុនឃៀង(2014). *គោលការណ៍ទូទៅនៃនីតិក្រមទាំងបួន.*


## គេហទំព័រ


Law. (n.d.). judicial independence | Definition, Scope, & Facts | Britannica. Retrieved August 14, 2020, from https://www.britannica.com/topic/judicial-independence

CCHCR Cambodia. (2013, August). នីតិវិធីមុនការជំនុំជម្រះ និងការជុំនុំជម្រះ: សៀវភៅមគ្គុទេសក៍ពីនីតិវិធីព្រហ្មទណ្ឌនៅកម្ពុជា. Retrieved from https://cchrcambodia.org/admin/media/report/report/khmer/2013_08_26_tmp_Procedure_Handbook_August_2013_khm.pdf

LAC. (1985). គោលការណ៍មូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ. Retrieved from http://lac.org.kh/wp-content/uploads/2017/11/1985-គោលការណ៍ជាមូលដ្ឋានស្តីពី-ឯករាជ្យភាពរបស់តុលាការ.pdf

OHCHR. (2014, March 1). សេចក្តីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌនៅកម្ពុជា: សេចក្តីពន្យល់ចំពោះករណីយុត្តិសាស្ត្រ អ.វ.ត.ក និងអន្តរជាតិសម្រាំង. Retrieved from https://cambodia.ohchr.org/~cambodiaohchr/sites/default/files/Annotated%20Cambodian%20Code%20of%20Criminal%20Procedure%20%5bKH%5d%20%5bMaster%20-%20Fiinal%5d.pdf

លោក ផុន វណ្ណា. (2015, July 25). ជំនួយស្មារតី: តម្កល់រឿងទុកឥតចាត់ការ. Retrieved from https://salatraju.com/index.php/post?p=33

វិទ្យាស្ថានខ្មែរដើម្បីលិទ្ធិប្រជាធិបតេយ្យ. (n.d.). ការពិចារណាពិស្តារផ្នែកគតិយុត្ត សៀវភៅសិក្សាផ្នែកទី៣: ប្រព័ន្ធតុលាការ. Retrieved May 15, 2020, from https://lorkremlaw.files.wordpress.com/2014/09/e19e94e19f92e19e9ae19e96e19f90e19e93e19f92e19e91e19e8fe19ebbe19e9be19eb6e19e80e19eb6e19e9ae19e93e19f83e19e96e19f92e19e9ae19f87e19e9a.pdf

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
អធិការដ្ឋាននគរបាលខណ្ឌមានជ័យ
ប៉ុស្តិ៍នគរបាលរដ្ឋបាល.....

## កំណត់ហេតុ ស្តាប់ចម្លើយ

លេខ:..........

កម្មវត្ថុ:..........

នៅ..........
ខែ.......... ថ្ងៃទី.......... វេលាម៉ោង.......... និង.......... នាទី
យើង.......... ជាមន្ត្រីនគរបាលយុត្តិធម៌
បន្តស៊ើបអង្កេតនៅក្នុងបទល្មើស..........
ជំនួយដោយលោក..........
យើងបានអោយនាំខ្លួនឈ្មោះ.......... ដែលជាអ្នក
បានឆ្លើយឲ្យយើងដឹងដូចខាងក្រោម:

**អំពីអត្តសញ្ញាណជនសង្ស័យ:**

- គោត្តនាម និង នាម.......... ឈ្មោះហៅក្រៅ..........
- ភេទ.......... អាយុ.......... ជនជាតិ.......... សញ្ជាតិ..........
- ថ្ងៃ ខែ ឆ្នាំកំណើត..........
- ស្រុកកំណើត..........
- ទីលំនៅបច្ចុប្បន្ន..........
- អត្តសញ្ញាណប័ណ្ណលេខ.......... ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ..........
- ផ្តល់នៅ..........
- លិខិតឆ្លងដែនលេខ.......... ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ..........
- ផ្តល់នៅ..........
- មុខរបរ..........
- កំរិតវប្បធម៌..........
- ប្រពន្ធ ឬប្តីឈ្មោះ..........
- ចំនួនកូនប៉ុន្មាននាក់.......... ០១
- ឪពុកឈ្មោះ.......... អាយុ ៦៦ ឆ្នាំ
- មុខរបរ..........
- ម្តាយឈ្មោះ.......... អាយុ.......... ឆ្នាំ
- មុខរបរ..........



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្តឹង

**ដើមចោទ:** ខ្ញុំបាទឈ្មោះ.......................................................មានអាសយដ្ឋានបច្ចុប្បន្ន.......................................................
តំណាងដោយលោក .........................តួនាទីជា ........................... ទូរស័ព្ទទំនាក់ទំនង ...........................................................។

**ចុងចម្លើយ:** ឈ្មោះ .................. ភេទ.............ថ្ងៃខែឆ្នាំកំណើត ............. កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ................ ចុះថ្ងៃទី ................ និង.................... ថ្ងៃខែឆ្នាំកំណើត ..................... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ............. ចុះថ្ងៃទី .......... មានទីលំនៅបច្ចុប្បន្ននៅភូមិ..........ឃុំ/សង្កាត់......... ស្រុក/ខណ្ឌ.................. ខេត្ត/ក្រុង .........................។

**សូមគោរពជូន**
**លោកប្រធានសាលាដំបូង**................

**កម្មវត្ថុ:** ប្តឹងសុំឲ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារដូចខាងក្រោម:

១. .......................................................
២. .......................................................

**យោង៖** - .......................................................
- .......................................................

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបអំពីដំណើររឿងដូចតទៅ៖ ............................... មានទីលំនៅបច្ចុប្បន្ននៅភូមិ...............ឃុំ/សង្កាត់.......... ស្រុក/ខណ្ឌ......................... ខេត្ត/ក្រុង
..........................................................................................................................................................................
..........................................................................................................................................................................

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាសម្រេចតាមសំណូមពររបស់ខ្ញុំបាទ ដូចមានក្នុងកម្មវត្ថុខាង លើដោយក្តីក្តីអនុគ្រោះ។

សូម **លោកប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ធ្វើនៅ...........................ថ្ងៃទី.............. ខែ............ ឆ្នាំ២០.......

ស្នាមមេដៃស្តាំ

ឈ្មោះ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

# ដីកាបញ្ជាឲ្យចូលខ្លួន[1]

លេខ..១០១....អ.យ.ប

**យើង [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញ មាត្រា ៣៧[2] , ៩៤[3] និងមាត្រា ១១៤[4] នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ: នស/ របក/ ០៨០៧/ ០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០០៧។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ២៥៣៥ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០១៧ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាកោះចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៧ លើឈ្មោះ ហួត យីនវុទ្ធី ហៅ ជុន ច័ន្ទបុត្រ ភេទ ប្រុស របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ លិខិតជូនដំណឹងចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧ របស់ឈ្មោះ ហួត វុទ្ធី ហៅ ជុន ច័ន្ទបុត្រ ភេទ ប្រុស អាយុ ៥៤ឆ្នាំ។

## បញ្ជា

*បង្គាប់ឲ្យកម្លាំងមានសមត្ថកិច្ចនាំខ្លួនបុគ្គលៈ*

១-នាម-គោត្តនាម [redacted] ហៅ [redacted] ភេទ ប្រុស (២៥-៥-១៩៦២) ជនជាតិ ខ្មែរ កាន់លិខិតឆ្លងដែនលេខ N0415701 ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៦ ទីកន្លែងកំណើត ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្ន ស្នាក់នៅស្ថានីយ៍[redacted] អគារ POC លេខ ១៨៤ ផ្លូវលេខ ២១៧ សង្កាត់ ទំនប់ទឹក ខណ្ឌ ចំការមន រាជធានីភ្នំពេញ មុខរបរ អនុប្រធានវិទ្យុអាស៊ីសេរីផ្នែកភាសាខ្មែរ ជា-នីតិជន។

២-មកបង្ហាញខ្លួននៅ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ រហូតដល់មានសេចក្តីសម្រេចថ្មី ដើម្បីសាកសួរពីដំណើររឿង ផ្តល់សេចក្តីប្រកាសដោយភូតកុហក បន្លំខ្លួនចូលពន្ធនាគារ ប្រព្រឹត្តនៅមណ្ឌលអប់រំកែប្រែទី១ ស្ថិតនៅភូមិ កំរៀង សង្កាត់ ព្រៃវែង ខណ្ឌ ដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៧។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ២០១៧

**ជ.ព្រះរាជអាជ្ញា**

[redacted]

ព្រះរាជអាជ្ញារង

១ ដីកានេះអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឲ្យចូលបង្ហាញខ្លួនភ្លាម
២ អំណាចរបស់ព្រះរាជអាជ្ញា
៣ ករណីស៊ើបអង្កេតជាក់ស្តែង
៤ ករណីស៊ើបអង្កេតបឋម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

ចង្អុរស៊ើបសួរ
លេខ ១៩៦ "ស" ព្រ.ទ

# ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៨៧៧ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣២៥៦ អ.យ.ជ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ៣៣៤៣ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ដែលទាក់ទងនឹង៖

## ជនត្រូវចោទ

-ឈ្មោះ [redacted] ភេទប្រុស អាយុ ៣៩ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ បុគ្គលិកក្រុមហ៊ុនលក់ការ៉ូ ទីកន្លែងកំណើតភូមិតាក្តុល សង្កាត់មិត្តភាព ស្រុកតាខ្មៅ ខេត្តកណ្តាល អាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ៥ ផ្លូវលេខ៣១៣ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ត្រូវបានដាក់ស្ថិតក្រោមការត្រួតពិនិត្យពីបទ **គំរាមកំហែងថានឹងសម្លាប់ និង ជេរប្រមាថជាសាធារណៈ** តាមបញ្ញត្តិមាត្រា ២៣៣ និងមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅមុខផ្ទះលេខ៥ ផ្លូវលេខ៣១៣ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៨។

បញ្ជូនសំណុំរឿងនេះទៅតំណាងអយ្យការ ដើម្បីសន្និដ្ឋាន ឬផ្តល់យោបល់ទៅតាមនីតិវិធី។

ថ្ងៃ សុក្រ ៩ រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩
ចៅក្រមស៊ើបសួរ

[redacted]

បានចម្លងអនុវត្ត
ក្រឡាបញ្ជី

ណារ៉ា.ឃើន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គំរូ
បន្ទប់ "ដ" ជាន់ទី៣

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ: ១២៨០
ចុះថ្ងៃទី ១៨-០៣-២០១៦

# ដីកាកោះ

យើង [illegible] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

អញ្ជើញឈ្មោះ គុ ភ័ន់ចាន់ ជា ជនសង្ស័យ

មានអាស័យដ្ឋាន ផ្ទះលេខA២៣ ភូមិទួលតាចាន់ សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

អោយចូលទៅកាន់ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

នៅថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៦ វេលាម៉ោង ០៩ និង០០នាទី

ដើម្បី សាកសួរ

ពីដំណើររឿង ពាក់ព័ន្ធនឹងអំពើពេស្យាចារ

សាមីខ្លួនត្រូវអញ្ជើញតាមដីកានេះ ឲ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែល ទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៦

ជ.ព្រះរាជអាជ្ញា

យើង [illegible] ព្រះរាជអាជ្ញារង

បានប្រគល់លិខិតអញ្ជើញនេះឲ្យឈ្មោះ [illegible]

ទីនៅលំនៅសព្វថ្ងៃ [illegible] A23 [illegible]

នៅថ្ងៃទី 6 ខែ 05 ឆ្នាំ 2016 រួចហើយ ដោយយើងបានទុកចុងដីកានេះ មួយច្បាប់ឲ្យសាមីខ្លួន ហើយប្រាប់ថាឲ្យសាមីខ្លួនប្រគល់ចុងដីកាដល់ក្រឡាបញ្ជី នៅពេល ខ្លួនចូលដល់តុលាការ ឬអយ្យការ។

| | |
|---|---|
| **អ្នកទទួលលិខិត** | **អ្នកប្រគល់លិខិត** |
| ហត្ថលេខា ឬស្នាមមេដៃ | |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ 476 ច-ដ.ច.ន

# ដីកាបង្គាប់ឱ្យចាប់ខ្លួន

យើង [redacted] ចៅក្រមជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៦២២៦ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧។

-បានឃើញមាត្រា ៣៥៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១៩៨៣-ច- ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចសេចក្ដីដូចខាងក្រោម:

១-ប្រកាសពិរុទ្ធភាពលើឈ្មោះ [redacted] ភេទប្រុស អាយុ៥៥ឆ្នាំ ជាតិខ្មែរ

ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧។

បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា២៣១ នៃច្បាប់ស្ដីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។

២-ផ្ដន្ទាទោសលើឈ្មោះ [redacted] ដាក់ពន្ធនាគារកំណត់រយៈពេល០២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦,០០០,០០០(**ប្រាំមួយលាន**)រៀល។

៣-បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] មកអនុវត្តទោសតទៅ។

៤-បង្គាប់ឱ្យឈ្មោះ [redacted] សងសំណងរដ្ឋប្បវេណីជាប្រាក់ដើមចំនួន ៨៥០,០០០(ប៉ែតសិបប្រាំម៉ឺន)ដុល្លារអាមេរិក និងការខូចខាតចំនួន ៨០,០០០(ប្រាំបីម៉ឺន)ដុល្លារអាមេរិក ទៅឈ្មោះ [redacted]។

ការទាមទារលើសពីនេះត្រូវច្រានចោល។

៥-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ។ ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

## យល់ឃើញថា

-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ៥៥ឆ្នាំ ជាតិខ្មែរ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់រយៈពេល ០២(ពីរឆ្នាំ) និងពិន័យជាប្រាក់ចំនួន ៦,០០០,០០០ (**ប្រាំមួយលាន**)រៀល ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា២៣១ នៃច្បាប់ស្ដីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។

-ឈ្មោះ [redacted] ភេទប្រុស អាយុ៥៥ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិទួលទ្រា ឃុំព្រែកក្អែង ស្រុកល្វាឯម ខេត្តកណ្ដាល មុខរបរ ឃោជា ទីលំនៅផ្ទះលេខ១២៦ ផ្លូវលំ ភូមិទួលទ្រា ឃុំព្រែកក្អែង ស្រុកល្វាឯម ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] មានកូន០៥នាក់ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ សម្រេចបង្គាប់ឱ្យចាប់ខ្លួនតាមសាលក្រមលេខ ១៩៨៣-ច- ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ ត្រង់ចំណុចទី៣។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ.១១០.៣៤...ត.ព្រ

# ដីកាបង្គាប់ឱ្យចូលខ្លួន

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ មាត្រា១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ២៣៥១ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៤៦៩ អ.យ.ជ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

ចោទប្រកាន់លើឈ្មោះ ភេទស្រី អាយុ ៦០ឆ្នាំ សញ្ជាតិខ្មែរ និងអាមេរិកកាំង ពីបទ ដឹកនាំកុបកម្ម, ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងផ្តើមគំនិតក្នុងអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចទីលានប្រជាធិបតេយ្យ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ តាមបញ្ញត្តិមាត្រា ៤៥៩, ៤៩៥, ២៨ និង ២១៨ នៃក្រមព្រហ្មទណ្ឌ។

បង្គាប់មកឈ្មោះ ភេទស្រី អាយុ ៦០ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ៤៣ ផ្លូវលំ ចាក់បេតុង សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ មុខរបរ តំណាងរាស្ត្រជាប់ឆ្នោតនៃគណបក្សសង្គ្រោះជាតិ។

ឱ្យចូលមកកាន់សាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៤ វេលាម៉ោង ៨:០០នាទី ព្រឹក នៅជាន់ទី៣ បន្ទប់ "គ"។

ដើម្បី សួរចម្លើយបន្ថែម

ពីបទ ដឹកនាំកុបកម្ម, ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងផ្តើមគំនិតក្នុងអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស

សាមីខ្លួនត្រូវយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើ មកជាមួយផងប្រសិនបើមាន ។
ក្នុងករណីមិនចូលខ្លួនតាមកាលកំណត់ខាងលើនេះទេ **យើងនឹងចេញដីកាបង្គាប់ឱ្យនាំខ្លួន**។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤

**ចៅក្រមស៊ើបសួរ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

# ដីកាបង្គាប់ឲ្យដោះលែង

លេខ ៧៦៦១ "គ" ដ.ឃ.ង យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៥៦៥២ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៧។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣៥២៨ អ.យ.ប ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧។

បានឃើញ សំណុំរឿងស៊ើបសួរ លេខ ៣៩៦១ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧។

បានឃើញ ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ លេខ ៤៩៩៥ "គ"ដ.ព.ស ចុះថ្ងៃអាទិត្យ ១៤រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

**បង្គាប់**

-ឱ្យប្រធានមណ្ឌលអប់រំកែប្រែទី៣ "មព៣" ដោះលែងជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ៦៨ឆ្នាំ ត្រូវបានតំណាងអយ្យការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ សន្និដ្ឋិភាពជាមួយបរទេស ប្រព្រឹត្តនៅប្រទេសកម្ពុជា និងទីកន្លែងផ្សេងទៀត កាលពីអំឡុងឆ្នាំ១៩៩៣ ដល់ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៤៣ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានឃុំខ្លួនតាម៖

-ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន លេខ ៥២០៣ "គ" ដ.ព.ស ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៧

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧២៥៨ "គ" ដ.ឃ.ង ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៧

-ដីកាសម្រេចពន្យាររយៈពេលឃុំខ្លួនបណ្តោះអាសន្ន លេខ ១២៨០ "គ" ដ.ព.ស ថ្ងៃចន្ទ ៤រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៨

-ដីកាបង្គាប់ឱ្យពន្យាររយៈពេលឃុំខ្លួនបណ្តោះអាសន្ន លេខ ១៨១៥ "គ"ដ.ឃ.ង ចុះថ្ងៃចន្ទ ៤រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៨

-ដីកាសម្រេចពន្យាររយៈពេលឃុំខ្លួនបណ្តោះអាសន្នលេខ ៤៧៨៧ "គ"ដ.ព.ស ចុះថ្ងៃព្រហស្បតិ៍ ៤រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨

-ដីកាបង្គាប់ឱ្យពន្យាររយៈពេលឃុំខ្លួនបណ្តោះអាសន្នលេខ ៦៩៩៩ "គ" ដ.ឃ.ង ចុះថ្ងៃព្រហស្បតិ៍ ៤រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨

ប្រសិនបើឈ្មោះនេះមិនត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀតទេ។

ថ្ងៃអាទិត្យ ១៤រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៨
ចៅក្រមស៊ើបសួរ

អាសយដ្ឋានៈ អគារលេខ ២៥, ២៦ និង ២៧ ផ្លូវលេខ ២១៧ សង្កាត់វាលវង់ ខណ្ឌ ៧ មករា, ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥)-២៣ ៨៨ ៥០ ៦០
Adress: #25, 26 and 27, Street 217, Sangkat Vealvong, Khan 7makara, Phnom Penh, Cambodia Fax-Phone : (855) - 23 88 50 60

36/6

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខ ៨៧៧
ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨
លេខ៖.១៤៣៦.អ.យ.យ

## ដីកាសន្និដ្ឋានស្ថាពរ

**យើង [redacted] តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៤៤០៣ អ.យ.យ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញសំណុំរឿងស៊ើបសួរលេខ ៣៣៨៣ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាបញ្ជូនឱ្យឆ្លើយដើម្បីបញ្ចប់ការស៊ើបសួរលេខ ១៩២ "ស" ព្រ.ទ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាបញ្ជូនរឿងទៅពិនិត្យលេខ ១៩៦ "ស" ព្រ.ទ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

### ក្រោយពីបានពិនិត្យឯកសារខាងលើ

**ឃើញថា៖**

-នាមត្រកូល-នាមខ្លួន [redacted] ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត ភូមិតាក្តុល សង្កាត់មិត្តភាព ស្រុកតាខ្មៅ ខេត្តកណ្តាល សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ៥ ផ្លូវលេខ៣៣១ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ មុខរបរ បុគ្គលិកក្រុមហ៊ុនលក់ការ៉ូ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (រស់) ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០២នាក់ ជានីតិជន ទោសពីមុន គ្មាន ។

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **គំរាមកំហែងថានឹងសម្លាប់ និងជេរប្រមាថជាសាធារណៈ**ប្រព្រឹត្តនៅចំណុចផ្ទះលេខ៥ ផ្លូវលេខ៣៣១ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧-មករា-២០១៨ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**ឃើញថា**[1] ៖ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល២១ និង៣០នាទី ឈ្មោះ ជា សារុធ បាននាំគ្នាផឹកស៊ីច្រៀងខារ៉ាអូខេ ក្នុងសម្លេងខ្លាំងៗ ស្ថិតនៅមុខផ្ទះលេខ៥ ផ្លូវលេខ៣៣១

---

[1] រៀបរាប់សង្ខេបអង្គហេតុ និងរាល់ចំណាត់ការនៃនីតិវិធីតាមលំដាប់ (ឧទាហរណ៍ អង្គហេតុដែលបានកើតឡើង ចំណាត់ការរបស់មន្រ្តីនគរបាលយុត្តិធម៌ អយ្យការ ចៅក្រមស៊ើបសួរ)

សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ បណ្តាលអោយចៅរបស់ឈ្មោះ [redacted] ដែលមានផ្ទះនៅជាប់នោះ យំដោយសារឮឮសំលេងធុងបាស់ ហើយឈ្មោះ នួន ស្រីពៅ ក៏ទៅប្រាប់អ្នកផឹកស៊ីអោយបន្ថយសំលេងធុងបាស់ ស្រាប់តែឈ្មោះ [redacted] ស្រែកថាគ្រាន់តែចាក់ធុងបាសប៉ុណ្ណឹងចាំអោយបិទលឺ ដូចនេះឈ្មោះ [redacted] ក៏បានសួរនាំឈ្មោះ [redacted] ក៏ត្រូវឈ្មោះ [redacted] ជេរថាមីចោកម៉ែងថោកជាងអាចម៍ រួចក៏ស្រែកប្រាប់ប្រពន្ធអោយទៅយកកាំភ្លើងម៉ាកK៥៤ មកបាញ់ឈ្មោះ នួន ស្រីពៅ ចោលជាច្រើនដង ហើយក៏ត្រូវអ្នកជិតខាងនៅទីនោះបំបែកចូលផ្ទះរៀងៗខ្លួនទៅ។

**ឃើញ៖**

-របាយការណ៍សំយោគលេខ ០៦៦/១៨ រ.ក.ប ចុះថ្ងៃទី៣-មីនា-២០១៨ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ បានសន្និដ្ឋានថា៖ ជនសង្ស័យឈ្មោះ [redacted] ភេទប្រុស អាយុ៣៨ឆ្នាំ (ក្រៅឃុំ) ពិតជាបានប្រព្រឹត្តអំពើ គំរាមថានឹងសម្លាប់ (ទំនាស់ប្រើពាក្យសំដីគំរាមមានអាវុធ) ទៅលើឈ្មោះ [redacted] ភេទស្រី អាយុ៤១ឆ្នាំ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៨ វេលាម៉ោង២១និង៣០នាទី នៅ ចំណុចផ្ទះលេខ៥ ផ្លូវលេខ៣៣១ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រាកដមែន ។

-កំណត់ហេតុស្តាប់ចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] បានឆ្លើយនៅគ្រប់ដំណាក់កាលនីតិវិធីប្រហាក់ប្រហែលគ្នាថា៖ ខ្លួនសូមរក្សាចម្លើយដែលបានឆ្លើយនៅតំណាងអយ្យការទុកនៅដដែល ដោយកាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៨ ឈ្មោះ ជា សាវុធ និងប្រពន្ធឈ្មោះ [redacted] បានផឹកស៊ីនៅលើផ្លូវមុខផ្ទះ និងបានចាក់ធុងបាស់លឺៗធ្វើអោយចៅរបស់ខ្លួនដែលទើបចេញ ពីពេទ្យយំយ៉ាងខ្លាំង ខ្លួននឹងអ្នកជិតខាងអោយទៅប្រាប់ឈ្មោះ [redacted] អោយបន្ថយសំលេងបន្តិច តែក៏ត្រូវឈ្មោះនោះស្រែកមកវិញថា គ្រាន់តែអញចាក់ធុងបាសប៉ុណ្ណឹងចាំបាច់អោយអញបិទ អញចង់ចាក់បីយប់បីថ្ងៃ ដុតគោស៊ីក៏គ្មានទើសក្បាលអាណាដែរ លឺដូចនេះ ខ្លួនក៏ចេញទៅប្រាប់ដោយផ្ទាល់ថា អូនហេ បងមិនមែនអោយបិទទេ គ្រាន់តែអោយបន្ថយសំលេង លឺខ្លួនប្រាប់ ដូចនេះឈ្មោះ ជា [redacted] ក៏ស្រែកជេរខ្លួនខ្លាំងៗថា មីឆ្កែ មីម៉ែងថោកជាងអាចម៍ទៅទៀត មិនបានប្រហែលបាតជើងអញផង ក្រៅពីនេះនៅមានពាក្យជេរ និងប្រមាថជាច្រើនទៀត ហើយប្រពន្ធរបស់ឈ្មោះ [redacted] ក៏បានស្រែកជេរខ្លួនដែរនូវពាក្យអាក្រក់ជាច្រើនថា មីអាប មីព្រាយ មីមេធ្មប់ មីម៉ែងហ្នឹងល្អតែសំបងក្រៅទេ។ ភ្លាមនោះ ឈ្មោះ ជា សាវុធ បានអោយប្រពន្ធទៅយកកាំភ្លើងម៉ាក K54 ហើយស្រែកថា យកមកអោយបងយកមកបាញ់មីហ្នឹងចោលឈ្មោះ [redacted] បានស្រែកបែបនេះខ្លាំងៗជាច្រើនដង ហើយប្រពន្ធគាត់ មិនបានចូលទៅយកទេ ឃើញដូចនេះឈ្មោះ [redacted] ក៏បានរត់ឡើងទៅលើឡៅតឿផ្ទះ របស់គាត់ទៅយកកាំភ្លើងមកខ្លួនឯង ពេលនោះអ្នកជិតខាងម្នាក់ឈ្មោះ [redacted] ជាអ្នកផឹកស៊ីជាមួយក៏ស្ទុះទៅបិទ ទ្វាររបស់គាត់ដោយក៏បសោរពីក្រៅមិនអោយគាត់ចេញមកព្រោះខ្លាចឈ្មោះ [redacted] យកកាំភ្លើងមកបាញ់ខ្លួនព្រោះពេលនោះប្តី និងកូនខ្លួនមិនបាននៅផ្ទះ ហើយឈ្មោះ [redacted] នេះបានអង្រួនទ្វារផ្ទះ និងស្រែកឲ្យឈ្មោះ ជា សំអៀង បើកទ្វារឲ្យដោយស្រែកថា បើកទ្វារអោយអញ អញបាញ់មីនោះចោល។ ពេលដែលឃើញប្តីមិនអាចចេញមកក្រៅបាន ប្រពន្ធរបស់ឈ្មោះ [redacted] បានយកកំប៉ុងប៊ីយ៉ែ ដែលមិនទាន់គាស់គប់មកលើខ្លួនតែខ្លួនគេចផុត ទើបឈ្មោះ ទូច សុផាត និងជា សំអៀង នាំខ្លួន ចូលផ្ទះ ព្រោះខ្លាចជា [redacted] មកបាញ់សំលាប់។ លុះដល់ព្រឹកឡើងខ្លួនបាន មកប៉ុស្តិ៍នគរបាលរដ្ឋបាលគោកឃ្លាង ប៉ុន្តែមិនមានចំណាត់ការ ទើបខ្លួនដាក់ពាក្យបណ្តឹងមកតុលាការ នៅពេលដែលតុលាការកំពុងមានចំណាត់ការឈ្មោះ [redacted] ក៏នៅតែនិយាយពាក្យឌឺដងដៀមដាម លឺៗដោយមិនខ្លាចនឹងចំណាត់ការតុលាការពេលដែលផឹកស៊ីស្រវឹង បើចាប់អញដាក់គុកបានអញកោរសក់មួយចំហៀងក្បាលអោយមើល។ ដោយទង្វើ និងពាក្យសម្តី

របស់ឈ្មោះ [redacted] ធ្វើអោយខ្លួននិងក្រុមគ្រួសាររស់នៅក្នុងសភាពភយខ្លាច ព្រោះឈ្មោះ [illegible] អាចបាញ់សម្លាប់ខ្លួនពេលណាក៏បានដែរ ព្រោះផ្ទះនៅជាប់គ្នាដោយហេតុថា ខ្លួនជឿជាក់ថាឈ្មោះ [redacted] ពិតជាមានអាវុធ ម៉ាក K54 ដូចឈ្មោះនេះបានគម្រាម ពិតប្រាកដ។

-កំណត់ហេតុស្តាប់ចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] បានឆ្លើយនៅតំណាងអយ្យការះ កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោងប្រហែល៧យប់ ខ្លួនទៅផ្ទះឈ្មោះ [redacted] នៅភូមិគោកឃ្លាំង សង្កាត់គោកឃ្លាំង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដើម្បីអោយលុយថ្លៃទិញដីអោយគាត់ និងបានអង្គុយលេងនៅផ្ទះឈ្មោះ [redacted] មួយសន្ទុះស្រាប់តែអ្នកជិតខាងផ្ទះរបស់ [redacted] នាំគ្នាផឹកស៊ីគ្នាប្រហែលប្រាំមួយទៅប្រាំពីរនាក់ មានការចាក់ធុងបាសនិងច្រៀងខារ៉ាអូខេលឺខ្លាំងៗ ឮមកដល់ផ្ទះឈ្មោះ [redacted] បណ្តាលអោយចៅរបស់ [redacted] ដែលមានអាយុជាងមួយខួបយំ មិនឈប់ដោយសារឮសំឡេងធុងបាសនោះ។ រយៈពេលជាងមួយម៉ោងឈ្មោះ [redacted] បានពរចៅចេញទៅក្រៅ ហើយបានដើរចេញពីផ្ទះទៅកន្លែងតុផឹកស៊ីដែលចាក់ធុងបាសនោះ ហើយខ្លួនអង្គុយមុខផ្ទះ មើលគាត់ដើរទៅតុផឹកស៊ីនោះ គាត់បានប្រាប់អ្នកផឹកស៊ីនោះអោយបន្ថយសំលេងធុងបាស់បន្តិច តែត្រូវគេមិនព្រម ក៏បានជេរបញ្ជោរគ្នាទៅវិញទៅមក តែខ្លួនមិនចាប់អារម្មណ៍ថាអ្នកណាជាអ្នកជេរមុននោះទេ ដោយភាគីម្ខាងទៀតពីរអ្នកប្តី ប្រពន្ធដែលខ្លួនមិនស្គាល់ឈ្មោះ បានស្រែកដាក់ឈ្មោះ [redacted] អញមិនខ្លាចអ្នកណាទេ គ្រាន់តែផឹកស៊ីចាក់ធុងបាសប៉ុណ្ណឹង អញចង់ផឹកស៊ី២ ៣ថ្ងៃក៏គ្មានទើសក្បាលអាណាដែរ ហើយឈ្មោះ [redacted] បានតបវិញថា អញគ្រាន់តែប្រាប់អោយបន្ថយសំលេងទេ មិនបានអោយបិទទេ ហើយភាគីម្ខាងទៀតដែលជាប្តីបានស្រែកថា អញមិនអត់ទេ មើលចិញ្ចៀនអញ ហើយបានប្រើអោយប្រពន្ធទៅយកលុយ បីម៉ឺនយកមកបោកលើតុអោយវាមើលតែប្រពន្ធមិនបានទៅយកទេ ហើយឈ្មោះ [redacted] ៖បានតបកាលពីមុនក៏ធ្លាប់ជំពាក់អញដែរ ហើយភាគីខាងប្រពន្ធនោះ បានតបវិញជំពាក់ពីកាលឈ្មោះ [redacted] បានឆ្លើយថា ជំពាក់ប្រាំពាន់មុននោះ ហើយភាគីប្តីតបវិញថា អញមិនបានជំពាក់ដែរទេ ឈ្មោះ [redacted] បានតបវិញថា ហែងទិញផ្ទះអញអោយលុយមិនគ្រប់ផង ស្រាប់តែភាគីជាប្តីខឹងច្រលោត បានអោយប្រពន្ធទៅយកកាំភ្លើងខ្លីនៅក្នុងផ្ទះអោយអញបាញ់មីនឹង អោយងាប់មួយ រួចបានបញ្ជាក់ប្រាប់ប្រពន្ធថាកាំភ្លើងខ្លី៥៤ នៅក្នុងផ្ទះលឺដូចនេះធ្វើអោយខ្លួនភ័យ ក៏បានទៅទាញនិងរុញឈ្មោះ [redacted] អោយចូលក្នុងផ្ទះ តែមិនទាន់ដល់ក្នុងផ្ទះផង ក៏ត្រូវភាគីខាងប្រពន្ធនោះយក បានយកកំប៉ុងគប់មកលើឈ្មោះ [redacted] តែមិនត្រូវ រួបខ្លួនក៏រុញឈ្មោះ [redacted] ចូលក្នុងផ្ទះបាត់ទៅចំនែកភាគីខាងប្តីប្រពន្ធនោះ ក៏ត្រូវអ្នកផឹកស៊ីនៅទីនោះចាប់រុញចូលផ្ទះអស់ទៅហើយ ក៏បានបញ្ចប់រឿងនោះត្រឹមនេះទៅ។

-កំណត់ហេតុស្តាប់ចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] បានឆ្លើយនៅតំណាងអយ្យការះ ខ្លួនបានស្គាល់ឈ្មោះ [redacted] ព្រោះជាអ្នកជិតខាងគ្នា មិនមានជាប់សាច់ញាតិគ្នាទេ កាលពីថ្ងៃខែមិនចាំ ឆ្នាំ២០១៨ មុនពេលកើតហេតុខ្លួននៅឈរមុខផ្ទះ ស្រាប់តែឈ្មោះ [redacted] បានពឹងអោយខ្លួនទៅប្រាប់អ្នកបើកបាស ដែលខ្លួនហៅថា [redacted] ហើយខ្លួនក៏បានដើរទៅប្រាប់ ឪអាពេជ្រអោយបន្ថយសម្លេងបាស ក្រោយពីប្រាប់ខ្លួនក៏បានដើរទៅផ្ទះខ្លួនវិញ រួចចូលក្នុងផ្ទះបាត់ទៅ។ ចំពោះការឈ្លោះគ្នាខ្លួនមិនដឹងទេ ព្រោះខ្លួនចូលផ្ទះបាត់ហើយ គ្រាន់តែដឹងថាពិតជាមានការឈ្លោះគ្នាមែន នៅថ្ងៃនោះ។

-កំណត់ហេតុស្តាប់ចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] បានឆ្លើយនៅតំណាងអយ្យការះ ខ្លួនមិនស្គាល់ឈ្មោះ [redacted] ព្រោះជាអ្នកជិតខាងគ្នា កាលពីថ្ងៃខែមិនចាំ មុនពេលកើតហេតុខ្លួនកំពុងលក់អីវ៉ាន់នៅផ្ទះ និងបានលក់ស្រាបៀរទៅអោយអ្នកជិតខាងឈ្មោះ [redacted] ឈ្មោះ [redacted] និងប្តី

-ជនត្រូវចោទជានីតិជន ហើយពុំមានសញ្ញាណាណាមួយដែលនាំឲ្យសង្ស័យពីបញ្ហាស្មារតីរបស់គេឡើយ ដូច្នេះជាសមត្ថជនដែលត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន ។ 36/1

-អំពើរបស់ជនត្រូវចោទបានធ្វើឲ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងបានធ្វើឲ្យប៉ះពាល់ទៅលើរូបរាងកាយនិងកិត្តិយស របស់អ្នកដទៃ ដែលច្បាប់បានការពារ និងត្រូវឲ្យផ្ដន្ទាទោស ។

-មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើឈ្មោះ [illegible] ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ (កំពុងនៅក្រៅឃុំ) ពីបទ **គំរាមកំហែងថានឹងសម្លាប់ និងជេរប្រមាថជាសាធារណៈ** ប្រព្រឹត្តនៅចំនុចផ្ទះលេខ៥ ផ្លូវលេខ៣៣១ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ ២០១៨ ដែលមានចែងអោយផ្ដន្ទាទោសតាមបញ្ញត្តិ មាត្រា២៣៣ និងមាត្រា៣០៧ នៃក្រមបទល្មើសព្រហ្មទណ្ឌ ។

<u>**សម្រេច**</u>

ប្ដឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេច ៖

☑ បញ្ជូនជនត្រូវចោទឈ្មោះ

[illegible] ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ (កំពុងនៅក្រៅឃុំ) មានសារធាតុដូចខាងលើ ទៅជំនុំជំរះ។

ថ្ងៃ សុក្រ ០៣ កើត ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦២

ធ្វើនៅអយ្យការ ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១៩

**តំណាងអយ្យការ**

ព្រះរាជអាជ្ញារង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ១០ "គ" ល.ក្រ

## លិខិតឲ្យដំណឹងអំពីសាលក្រម

យើង [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ប្រាប់មកឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៤៩ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ស្នាក់នៅផ្ទះលេខ៥៧៦ ផ្លូវជាតិលេខ២ ភូមិព្រែកតាគង់២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ជាជនជាប់ចោទ ឱ្យបានដឹងថា សំណុំរឿងព្រហ្មទណ្ឌលេខ៣៥១៣ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៤៩ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតសង្កាត់លេខ៣ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្ន ស្នាក់នៅផ្ទះលេខ៥៧៦ ផ្លូវជាតិលេខ២ ភូមិព្រែកតាគង់២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ សម សារី (ស្លាប់) ម្តាយឈ្មោះ [redacted] (ស្លាប់) ប្រពន្ធឈ្មោះ [redacted] (រស់) មានកូនចំនួន៦(ប្រាំមួយ) នាក់ ជាទីតិជន ។

ជាប់ចោទពីបទ ប្រមាថចំពោះអង្គព្រះមហាក្សត្រ ប្រព្រឹត្តនៅរាជធានីភ្នំពេញ និងទីកន្លែងផ្សេងទៀត កាលពីថ្ងៃទី០៦, ថ្ងៃទី០៧ និងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា៤៣៧(ស្ទួន) នៃច្បាប់ស្តីពីវិសោធនកម្មក្រមព្រហ្មទណ្ឌ នោះ សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចចេញសាលក្រមព្រហ្មទណ្ឌលេខ១២៩៧ "គ" ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ ដោយបានសម្រេចសេចក្តីដូចខាងក្រោម ៖

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៤៩ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៤(បួន) ឆ្នាំ និងពិន័យជាប្រាក់ចំនួន១០,០០០,០០០(ដប់លាន)រៀល ពីបទ ប្រមាថចំពោះអង្គព្រះមហាក្សត្រ ប្រព្រឹត្តនៅរាជធានីភ្នំពេញ និងទីកន្លែងផ្សេងទៀត កាលពីថ្ងៃទី០៦, ថ្ងៃទី០៧ និងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា៤៣៧(ស្ទួន) នៃច្បាប់ស្តីពីវិសោធនកម្មក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យកម្លាំងមានសមត្ថកិច្ច ចាប់ខ្លួន-ឃុំខ្លួន ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៤៩ ជនជាតិខ្មែរ មកដាក់ពន្ធនាគារ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ ចាត់ទុកចំពោះមុខជនជាប់ចោទឈ្មោះ សម វង្សី និងប្រកាសជាសាធារណៈនៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ ។

គូភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

សាមីខ្លួនមានសិទ្ធិចូលមកប្តឹងឧទ្ធរណ៍ក្នុងរយៈពេល០១(មួយ)ខែ គិតពីថ្ងៃបានទទួលលិខិតជូនដំណឹងនេះ ។

ថ្ងៃសុក្រ ១៤រោច ខែចេត្រ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩

បានឃើញ
ចៅក្រមជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]